សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# សន្តិកម្មតាមច្បាប់ និងខ្លឹមសារនៃ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ជន ហុកលី**
**តែ ប៊ុនហុង**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ម៉ូលី បញ្ញា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ


ឧឧឧ✵ឧឧឧ

ខ្ញុំបាទនិស្សិត **ជន ហុកលី** និង **តៃ ម៉ុនហុង** ជានិស្សិតអាហារូបករណ៍ថ្នាក់នីតិសាស្រ្ត ឆ្នាំទី៤ ជំនាន់ទី២៤ ក្រុម$L_4B_1$ ក្នុងឆ្នាំសិក្សា ២០១៨-២០១៩។

**សូមសម្តែងនូវសេចក្តីថ្លែងអំណរគុណ និងភាពកតញ្ញូដ៏ជ្រាលជ្រៅដល់**

- អ្នកមានគុណរបស់ពួកខ្ញុំទាំងពីររូប ដែលពួកលោកបានចិញ្ចឹមបីបាច់មើលថែរក្សារូបខ្ញុំទាំងពីររូប ឱ្យបានដឹងក្តី រួមទាំងបានទំនុកបម្រុងពួកខ្ញុំបាទទាំងស្មារតី សម្ភារៈ និងថវិកា ឱ្យទទួលបាននូវចំណេះដឹង និងទទួលបានលទ្ធផលផ្លែផ្កាដូចបច្ចុប្បន្ន។
- **ក្រសួងអប់រំយុវជន និងកីឡា** ដែលបានផ្តល់នូវអាហារូបករណ៍ ដល់រូបខ្ញុំបាទទាំងទ្វេ ក្នុងការទទួលបាននូវចំណេះដឹងពី **សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** រហូតដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត។
- **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធិបុរស ព្រឹទ្ធបុរសរង លោក/លោកស្រីសាស្រ្តាចារ្យ**រួមទាំងបុគ្គលទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានចូលរួមចំណែកក្នុងការប្រឹងប្រែងអស់ពីកម្លាំងកាយនិងចិត្តក្នុងការពង្រឹងវិន័យនិងផ្តល់ការអបរំ សីលធម៌ រួមទាំងចំណេះដឹងផ្សេងៗដល់រូបពួកខ្ញុំបាទ។
- លោកស្រីសាស្រ្តាចារ្យ **ម៉ូលី បញ្ញា** ជាអនុប្រធានការិយាល័យស្រាវជ្រាវនិងជាសាស្រ្តាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងជាសាស្រ្តាចារ្យណែនាំការសរសេរសារណានេះ ដោយលោកស្រីបានបង្ហាត់បង្រៀន និងបានចំណាយពេលដ៏មានតម្លៃក្នុងការណែនាំពន្យល់ ផ្តល់ជាយោបល់រួមទាំងបទពិសោធន៍ល្អៗ និងកែសម្រួលនូវការធ្វើសារណានេះបញ្ចប់ដោយរលូន។

ជាចុងក្រោយបង្អស់នេះ រូបខ្ញុំបាទទាំងពីររូប សូមប្រសិទ្ធិពរជ័យសិរីមង្គលទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ ដល់អ្នកមានគុណទាំងឡាយខាងលើ ព្រមទាំងបានសម្រេចនូវគោលបំណង ជោគជ័យគ្រប់បែបយ៉ាងក្នុងការបំពេញការងារ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាក្នុងថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រកន្លងមក រួមទាំងតាមការស្វែងយល់អំពីការស្រាវជ្រាវនានា ដែលទាក់ទងទៅនឹងវិធានគតិយុត្តនៃនីតិរដ្ឋប្បវេណី ពួកខ្ញុំបានចាប់អារម្មណ៍យ៉ាងខ្លាំងទាក់ទងទៅនឹងចំណុចសន្តតិកម្មតាមច្បាប់ ដែលជាផ្នែកមួយនៃនីតិគ្រួសារ។ លើសពីនេះទៅទៀតពួកខ្ញុំបាទ ក៏បានឃើញអំពីចំណុចស្មុគស្មាញជាច្រើនផងដែរនៃក្រមរដ្ឋប្បវេណី ដោយមិនអាចគ្រាន់តែអានអាចយល់នោះបានទេ ពោលគឺតម្រូវឱ្យមានការសិក្សាទៅលើបទបញ្ញត្តិនីមួយៗឱ្យបានច្បាស់លាស់ដែលបញ្ញត្តិនីមួយៗមានភាពប្រទាក់ក្រឡាគ្នា។ មិនត្រឹមតែប៉ុណ្ណោះក្នុងក្រមរដ្ឋប្បវេណីគន្ថីទី៨ នេះក៏មាននូវចំនុចដែលក្នុងជីវភាពរស់នៅប្រចាំថ្ងៃតែងតែជួបជាញឹកញាប់ ដែលបង្កឱ្យមានទំនាស់ក្នុងការចែកមតិកក្នុងរង្វង់ញាតិរបស់ខ្លួន នៅពេលគ្មានមតកសាសន៍ធ្វើឡើង ជាមូលហេតុនាំឱ្យពួកខ្ញុំបាទ មានចំណាប់អារម្មណ៍ក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងសារណានេះឡើងក្នុងគោលបំណង សម្រាប់ទុកជាឯកសារចំពោះផលប្រយោជន៍និស្សិតជំនាន់ក្រោយ ក៏ដូចជាប្រជាពលរដ្ឋទូទៅផងដែរ។

ម៉្យាងវិញទៀត មូលហេតុដែលជម្រុញឱ្យពួកខ្ញុំស្រាវជ្រាវពីប្រធានបទ សន្តតិកម្មតាមច្បាប់ និងខ្លឹមសារនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នេះគឺដើម្បីដំកល់ទុកជាឯកសារជំនួយស្មារតី សម្រាប់និស្សិតទាំងឡាយ ដែលមានគោលបំណងក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទសន្តតិកម្មនេះ។ ប្រធានបទនេះពិតជាមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់អ្នកច្បាប់ក្នុងការស្វែងយល់ដោយសារតែគ្រួសារណាក៏ដោយក៏តែងតែមាននូវបញ្ហាជៀសមិនផុតឡើយ ជាពិសេសគឺទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់បុគ្គលដែលបានស្លាប់ទៅ។ ហេតុដូច្នេះហើយការសិក្សាអំពីប្រធានបទនេះពិតជាមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់អ្នកច្បាប់ដើម្បីចូលរួមក្នុងការដោះស្រាយជម្លោះគ្រួសារក្នុងសង្គម។

ដូច្នេះហើយរូបយើងខ្ញុំបាទសង្ឃឹមយ៉ាងខ្លាំងថា ការសិក្សាស្រាវជ្រាវពីសន្តតិកម្មតាមច្បាប់នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ពិតជាបានចូលរួមចំណែកដល់ការចែករំលែកចំណេះដឹង ពីការបែងចែកចំណែកមតិក ក៏ដូចជាចូលរួមក្នុងការកាត់បន្ថយនូវជម្លោះ តាមរយៈការចែករំលែកនូវចំណេះដឹងច្បាប់ដល់ប្រជាពលរដ្ឋក្នុងសង្គមកម្ពុជា ដើម្បីឱ្យក្លាយជាសង្គមមួយពោរពេញដោយការអត់ឱនយោគយល់គ្នា ជាពិសេសក្នុងរង្វង់គ្រួសារ។ ដោយមូលហេតុថាយើងខ្ញុំបាទមានរយៈពេលនៃការស្រាវជ្រាវមានកំណត់ ដូចនេះលទ្ធផលនៃការស្រាវជ្រាវនេះពិតជាមានកង្វះខាតផ្សេងៗ ដោយមិនបានវិភាគគ្រប់ជ្រុងជ្រោយនោះទេ ព្រមទាំងមាននូវឧបសគ្គក្នុងការស្វែងរកនូវសេចក្តីសម្រេចរបស់តុលាការផងដែរនោះ។ យើងខ្ញុំបាទក៏សង្ឃឹមថានឹងមានការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះឱ្យបានស៊ីជម្រៅនិងទូលាយជាងនេះ។ យើងខ្ញុំក៏សូមធានាថាសារណាដែលបានសរសេរឡើងនេះគឺពុំបានចម្លងពីស្នាដៃរបស់បុគ្គលណាមួយឡើយ។ យើងខ្ញុំបាទក៏សូមធ្វើការអធ្យាស្រ័យចំពោះរាល់

នូវកំហុសអចេតនាផ្សេងៗទាក់ទងនឹង អក្ខរាវិរុទ្ធ ខ្លឹមសារ និងវេយ្យាករណ៍ ដែលពុំត្រឹមត្រូវ ហើយក៏ត្រៀមលក្ខណៈក្នុងការទទួលយកមតិរិះគន់ពីលោក លោកស្រីសាស្ត្រាចារ្យទាំងអស់។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ... ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់**

**១.១ ការកំណត់អំពីខ្លឹមសារនៃសន្តតិកម្មតាមច្បាប់** ... ៣

**១.១.១ និយមន័យនៃសន្តតិកម្មតាមច្បាប់** ... ៣

**១.១.២ ចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់** ... ៤

**១.២ លក្ខខណ្ឌនៃការទទួលបានសិទ្ធិ និងផ្តាច់សិទ្ធិជាសន្តតិជន** ... ៤

**១.២.១ លក្ខខណ្ឌនៃការទទួលបានសិទ្ធិជាសន្តតិជន** ... ៥

១.២.១.១ ករណីសន្តតិជនស្ថិតក្នុងស្ថានភាពជាទារកក្នុងគភ៌ ... ៥

១.២.១.២ ករណីសន្តតិជនជារូបវន្តបុគ្គល ... ៥

**១.២.២ លក្ខខណ្ឌនៃការផ្តាច់សិទ្ធិជាសន្តតិជន** ... ៧

១.២.២.១ ករណីអភ័ព្វបុគ្គល ... ៧

១.២.២.២ ករណីបុគ្គលត្រូវបានផ្តាច់ពីមត៌ក ... ៧

**១.៣ អំពីអានុភាពនៃសន្តតិកម្មតាមច្បាប់** ... ៨

**១.៣.១ ពេលវេលាបើកសន្តតិកម្មតាមច្បាប់** ... ៨

១.៣.១.១ ករណីបានទទួលមរណភាព ... ៨

១.៣.១.២ ករណីបាត់ខ្លួន ... ៨

**១.៣.២ ទីកន្លែងបើកសន្តតិកម្មតាមច្បាប់** ... ៩

**ជំពូកទី២**

**អំពីរបបបែងចែកមត៌កនៃសន្តតិកម្មតាមច្បាប់**

**២.១ ការកំណត់អំពីលំដាប់នៃសន្តតិជន** ... ១០

**២.១.១ សន្តតិជនលំដាប់ទី១** ... ១០

**២.១.២ សន្តតិជនលំដាប់ទី២** ... ១២

**២.១.៣ សន្តតិជនលំដាប់ទី៣** ............................................................ ១២

**២.១.៤ សន្តតិជនជំនួស**............................................................ ១៣

**២.១.៥ សន្តតិជនជានិច្ច** ............................................................ ១៤

**២.២ ការកំណត់អំពីចំណែកដែលសន្តតិជនត្រូវទទួលបាន** ............................................................ ១៥

**២.២.១ ករណីមានតែញាតិ**............................................................ ១៥

២.២.១.១ បច្ឆាញាតិ............................................................ ១៥

២.២.១.២ បុព្វញាតិ............................................................ ១៦

២.២.១.៣ សាខាញាតិ ............................................................ ១៧

**២.២.២ ករណីមានសន្តតិជនជានិច្ច** ............................................................ ១៨

២.២.២.១ មានតែសន្តតិជនជានិច្ច ............................................................ ១៨

២.២.២.២ បច្ឆាញាតិ ............................................................ ១៨

២.២.២.៣ បុព្វញាតិ ............................................................ ១៩

២.២.២.៤ សាខាញាតិ............................................................ ២១

**២.៣ អំពីការសម្រួលចំណែករបស់សន្តតិជនតាមច្បាប់** ............................................................ ២១

**២.៣.១ អ្នកទទួលផលប្រយោជន៍ពិសេស**............................................................ ២២

២.៣.១.១ អ្នកទទួលផលប្រយោជន៍ពិសេស ............................................................ ២២

២.៣.១.២ ករណីដែលទទួលផលប្រយោជន៍ពិសេសនោះលើសពីតម្លៃនៃចំណែកមត៌ក ............................................................ ២២

**២.៣.២ ករណីមានប្រទានកម្ម**............................................................ ២៤

**២.៣.៣ ករណីមានវិភាគទាន** ............................................................ ២៤

**២.៤ អំពីភាគបម្រុង**............................................................ ២៥

**២.៤.១ សញ្ញាណទូទៅនៃភាគបម្រុង** ............................................................ ២៥

២.៤.១.១ ជនដែលមានសិទ្ធិលើភាគបម្រុង ............................................................ ២៦

២.៤.១.២ ការកំណត់អំពីចំណែកនៃភាគបម្រុង............................................................ ២៦

**២.៤.២ វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង** ............................................................ ២៦

២.៤.២.១ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ............................................................ ២៧

២.៤.២.២ លំដាប់នៃការកាត់បន្ថយ ..................................................................... ២៩

**២.៤.៣ ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយចំណែកដើម្បីបង្គ្រប់ភាគបម្រុង** .....៣២

២.៤.៣.១ ការបោះបង់ចោលភាគបម្រុង ............................................................. ៣៣

២.៤.៣.២ ករណីជាសហាសន្តតិជន ..................................................................... ៣៣

## ជំពូកទី៣

## ការអនុវត្តនៃសន្តតិកម្មតាមច្បាប់

**៣.១ ការយល់ព្រមទទួលយក និងការបោះបង់ចោលសន្តតិកម្ម** ................................. ៣៤

**៣.១.១ ការយល់ព្រមទទួលយកសន្តតិកម្ម** ....................................................... ៣៤

៣.១.១.១ ទទួលយកទាំងស្រុង ................................................................. ៣៦

៣.១.១.២ ទទួលយកមានកម្រិត ................................................................. ៣៧

**៣.១.២ ការបោះបង់ចោលសន្តតិកម្ម** ........................................................... ៣៨

**៣.២ របបនៃការគ្រប់គ្រង និងនីតិវិធីនៃការបែងចែកសន្តតិកម្មតាមច្បាប់** .................. ៣៨

**៣.២.១ ការគ្រប់គ្រងមត៌ក** ............................................................................. ៣៩

**៣.២.២ ការបែងចែកមត៌ក** ............................................................................. ៤០

៣.២.២.១ តាមការព្រមព្រៀងគ្នា ............................................................................. ៤០

៣.២.២.២ តាមផ្លូវតុលាការ ..................................................................................... ៤២

**៣.២.៣ អានុភាព និងការធានាកាតព្វកិច្ច** ........................................................... ៤៣

៣.២.៣.១ អានុភាពនៃសន្តតិកម្ម ............................................................................. ៤៣

៣.២.៣.២ ការធានាកាតព្វកិច្ច ................................................................................. ៤៤

**៣.២.៤ ការសម្រួលរវាងម្ចាស់បំណុល** ................................................................. ៤៥

**៣.៣ អំពីស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់** .............................................. ៤៦

**៣.៣.១ អំពីនត្ថិភាពនៃសន្តតិជន** ......................................................................... ៤៦

៣.៣.១.១ នីតិបុគ្គលមត៌ក ..................................................................................... ៤៦

៣.៣.១.២ ចំណែកចំពោះជនដែលមាននិស្ស័យពិសេស ................................................ ៤៧

៣.៣.១.៣ មត៌កដែលក្លាយជារបស់រដ្ឋ ......................................................................... ៤៧

**៣.៣.២ អំពីបដិទាននៃសន្តតិកម្ម** ......................................................................... ៤៨

**សេចក្តីសន្និដ្ឋាន**......................................................................................................៥៣
**អនុសាសន៍**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានប្រវត្តិសាស្ត្រយូរលង់ណាស់មកហើយ។ ត្បិតតែធ្លាប់បានឆ្លងកាត់នូវប្រវត្តិសាស្ត្រដ៏ជូរចត់ អស់រយៈពេលបីសតវត្សរ៍រួចមកហើយ ដែលបណ្តាលឱ្យហេដ្ឋារចនាសម្ព័ន្ធ រូបវន្ត នយោបាយ សេដ្ឋកិច្ច វប្បធម៌ និងវិស័យផ្សេងៗ។ ក្រោយពីទទួលបានសន្តិភាព និងទទួលបានឱកាសក្នុងការអភិវឌ្ឍប្រទេសរួចមក ប្រទេសកម្ពុជាបានធ្វើដំណើរទៅឆ្ពោះ ទៅកាន់ការអភិវឌ្ឍគ្រប់វិស័យ រួមទាំងវិស័យយុត្តិធម៌ផងដែរ។

ក្នុងសហសម័យនៃភាពទំនើបនេះ កម្ពុជាក៏បានធ្វើទំនើបកម្មនូវច្បាប់ផ្សេងៗ ដើម្បីឱ្យមានភាពសមស្របទៅតាមតថភាពនៃសង្គម ត្បិតតែមានចន្លោះខ្វះខាតពិតមែន ប៉ុន្តែក៏មានការសិក្សាស្រាវជ្រាវនិងតាក់តែងច្បាប់សំខាន់ៗជាច្រើន ដូចជា ក្រមរដ្ឋប្បវេណី ក្រមនីតិព្រហ្មទណ្ឌជាដើម។ ដែលក្នុងន័យនេះ ទើបរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងពីការទទួលស្គាល់នូវកម្មសិទ្ធិឯកជន មិនថារូបវន្តបុគ្គល ឬនីតិបុគ្គលឡើយ មានន័យថាកម្មសិទ្ធិករដែលជាអ្នកមានសិទ្ធិក្នុងការចាត់ចែង ប្រើប្រាស់ និងអាស្រ័យផលពីទ្រព្យរបស់ខ្លួនយ៉ាងមានសេរីភាពគ្រប់ពេលទាំងអស់ ព្រមទាំងក្រោយពេលទទួលមរណភាព ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់។ ការចាត់ចែងទ្រព្យសម្បត្តិបែបនេះដោយការផ្ទេរទ្រព្យសម្បត្តិពីបុគ្គល ដែលទទួលមរណភាពសញ្ញាណនេះ ពាក្យបច្ចេកទេសច្បាប់ គឺហៅថា សន្តតិកម្ម។

សន្តតិកម្មនេះមិនមែនទើបតែមានទេ វាមានប្រវត្តិយូរលង់ណាស់មកហើយ ដោយហេតុថាបុព្វបុរសខ្មែរបានមានគំនិត ក្នុងការបន្តឱ្យកូនទទួលបន្តនូវកេរ្តិ៍មរតករបស់ខ្លួន គ្រប់គ្រងបន្តពីវង្សត្រកូលមួយ ទៅវង្សត្រកូលមួយទៀត។ រហូតមកដល់មានការតាក់តែងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧នេះ សន្តតិកម្មក៏មានចែងអំពីចំនុចនេះដែរ នៅក្នុងគន្ថីទី៨។

នៅក្នុងពិភពលោក របបសន្តតិកម្មគឺមានគោលការណ៍ពីរប្រភេទធំៗ គឺគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ និងគោលការណ៍ជម្រះបញ្ជី។ គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ មានន័យថា សន្តតិជនត្រូវទទួលបន្តនូវមត៌កទាំងអស់ ដោយបូករួមនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជនផងដែរ មុននឹងធ្វើការបែងចែក ឬធ្វើការសងបំណុល ហើយអនុញ្ញាតឱ្យសន្តតិជនមានសិទ្ធិទទួលយកទាំងស្រុង ឬទទួលយកដោយមានកម្រិត ឬក៏លះបង់សន្តតិកម្មតែម្តង។ចំណែកឯគោលការណ៍ជម្រះបញ្ជីវិញ គឺតម្រូវឱ្យជម្រះសិទ្ធិ និងកាតព្វកិច្ចជាមុនសិន ហើយសន្តតិជនគឺអាចតែទទួលបានមត៌កក្នុងករណី ដែលសល់តែទ្រព្យសកម្មតែប៉ុណ្ណោះ ហើយករណីសល់តែទ្រព្យអកម្មច្រើនពេកនោះតម្រូវឱ្យប្រកាសក្ស័យធននៃមត៌ក ដើម្បីជៀសវាងកុំឱ្យសន្តតិជនទទួលបន្ទុកកាតព្វកិច្ចនោះ។ ទៀតសោតនីតិវិធីនេះមានលក្ខណៈស្មុគស្មាញ ចំណាយថវិកា និងពេលវេលាច្រើន ជាហេតុនាំឱ្យក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យកនូវគោលការណ៍ទទួលបន្ត

ដោយស្វ័យប្រវត្តិតែម្តង ដោយអនុញ្ញាតឱ្យមានការទទួលយកទាំងស្រុង ឬទទួលយក ដោយមានកម្រិត ឬក៏លះបង់ចំណែកមតិករបស់ខ្លួន។

សន្តតិកម្មដែលមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្រើននិងច្បាស់ពីទំនាក់ទំនងញាតិរវាងមតកជន និងទាយាទ ព្រមទាំងអ្នកដែលទទួលបន្តជំនួស។ សន្តតិកម្មត្រូវបានបែងចែកជាពីរប្រភេទ គឺសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍។ សន្តតិកម្មតាមមតកសាសន៍គឺ ជាសន្តតិកម្មដែលធ្វើឡើងតាមរយៈឆន្ទៈរបស់មតកជនក្នុងការបែងចែកមតិករបស់ខ្លួន។ ឯសន្តតិកម្មតាមច្បាប់វិញ គឺជាសន្តតិកម្មដែលផ្អែកលើបញ្ញត្តិច្បាប់ដែលមានចែងជាធរមានពោលគឺក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ទោះបីជាមានការចែងយ៉ាងក្បោះក្បាយពីការស្នងមតិកនេះក៏ដោយ ក៏ប្រជាពលរដ្ឋមានការយល់ដឹងមានកម្រិតនៅឡើយ។ ម្យ៉ាងវិញទៀតដោយបានឃើញនៅការសិក្សាស្រាវជ្រាវច្រើនស្តីពីសន្តតិកម្ម ប៉ុន្តែមិនទាន់សម្បូរការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅនៅឡើយពីសន្តតិកម្មតាមច្បាប់។ ដោយហេតុតែឃើញថាសន្តតិកម្ម ពិតជាមានសារៈសំខាន់ណាស់នៅក្នុងជីវភាពប្រចាំថ្ងៃ ជាពិសេសសម្រាប់អ្នកច្បាប់ដែលចាំបាច់ត្រូវតែស្វែងយល់ឱ្យបានច្បាស់លាស់។ ការស្រាវជ្រាវនេះគឺមានគោលបំណងបង្ហាញនូវទស្សនទានអំពីសន្តតិកម្មតាមច្បាប់ ដែលត្រូវបានយកទៅបកស្រាយ និងធ្វើការអនុវត្តក្នុងប្រទេសកម្ពុជា និងបានកម្រឹតនូវវិសាលភាពត្រឹមតែប្រព័ន្ធច្បាប់របស់កម្ពុជាតែប៉ុណ្ណោះ។

ដើម្បីពន្យល់អំពីប្រធានបទ សន្តតិកម្មតាមច្បាប់ និងខ្លឹមសារនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ឱ្យបានគ្រប់ជ្រុងជ្រោយ ស៊ីជម្រៅ និងច្បាស់លាស់នោះ យើងខ្ញុំបែងចែកការសិក្សាស្រាវជ្រាវដូចខាងក្រោម៖

**ជំពូកទី១៖ សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់**

**ជំពូកទី២៖ អំពីរបបបែងចែកមតិកនៃសន្តតិកម្មតាមច្បាប់**

**ជំពូកទី៣៖ ការអនុវត្តនៃសន្តតិកម្មតាមច្បាប់**

# ជំពូកទី១

# សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់

មុនសិក្សាទៅលើឱ្យបានស៊ីជម្រៅទៅលើសន្តតិកម្មតាមច្បាប់ យើងគប្បីស្វែងយល់អំពីនិយមន័យ និងចរិតលក្ខណៈ រួមទាំងអត្ថិភាព និងនត្ថិភាពនៃសន្តតិជនដែលត្រូវទទួលសិទ្ធិក្នុងការស្នងមតិក ព្រមទាំងអានុភាពនៃសន្តតិតាមច្បាប់។ ដោយចំនុចទាំងនេះនឹងសិក្សានៅក្នុងជំពូកទី១នេះ។ ក្នុងជំពូកទី១ "សញ្ញាណទូទៅនៃសន្តតិកម្មតាមច្បាប់"នេះ ត្រូវបានបែងចែកជាបីផ្នែក ដែលក្នុងនោះមានដូចជា ចំណុច ១.១ បកស្រាយអំពី "ការកំណត់អំពីខ្លឹមសារនៃសន្តតិកម្មតាមច្បាប់" ចំណុច ១.២ បកស្រាយអំពី "លក្ខខណ្ឌនៃការទទួលបានសិទ្ធិ និងផ្តាច់សិទ្ធិជាសន្តតិជន" និង ចំណុច ១.៣ គឺ "អំពីអានុភាពនៃសន្តតិកម្មតាមច្បាប់"។

## ១.១ ការកំណត់អំពីខ្លឹមសារនៃសន្តតិកម្មតាមច្បាប់

ក្នុងចំណុច ១.១នេះ យើងនឹងសិក្សាទៅលើ "និយមន័យនៃសន្តតិកម្មតាមច្បាប់" ក្នុងចំណុច ១.១.១ និងចំណុច ១.១.២ "ចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់" ដើម្បីធ្វើឱ្យយល់បានកាន់តែស៊ីជម្រៅថែមទៀត ក្នុងការបកស្រាយអំពីសន្តតិកម្មតាមច្បាប់។

### ១.១.១ និយមន័យនៃសន្តតិកម្មតាមច្បាប់

ពាក្យ "សន្តតិកម្ម" ត្រូវបានឱ្យនិយមន័យថាជា ការផ្ទេរទ្រព្យសម្បត្តិទាំងឡាយណារបស់បុគ្គលណាម្នាក់ ដែលបានទទួលមរណភាព ទៅឱ្យបុគ្គលម្នាក់ ឬច្រើននាក់ ក្នុងឋានៈជាសន្តតិជនរបស់បុគ្គលដែលទទួលមរណភាពនោះ ដែលអាចជាការផ្ទេរតាមឆន្ទៈរបស់បុគ្គលដែលស្លាប់នោះ ឬតាមផ្លូវច្បាប់[1]។ ក្នុងន័យនេះ ពាក្យ "ទ្រព្យសម្បត្តិ" នៃសន្តតិជន សំដៅទៅលើទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម (បំណុល)[2]។ អ្នកដែលបានទទួលមរណភាពខាងលើ ត្រូវបានហៅថា "មតកជន"[3] រីឯ អ្នកដែលត្រូវទទួលសន្តតិកម្មពីមតកជននោះ គឺហៅថា "សន្តតិជន"[4]។ មួយវិញទៀត សន្តតិជនអាចជាបុគ្គលតែម្នាក់ ឬបុគ្គលច្រើននាក់ ដែលអាចជាកូន ចៅ ប្រពន្ធ ឪពុក ម្តាយ ជីដូន ជីតា និងបងប្អូនបង្កើត។ល។

ពាក្យ "សន្តតិកម្មតាមច្បាប់" សំដៅលើការផ្ទេរទ្រព្យសម្បត្តិទាំងឡាយណារបស់បុគ្គលណាម្នាក់ ដែលបានទទួលមរណភាព ទៅឱ្យបុគ្គលម្នាក់ ឬច្រើននាក់ ដែលមិនមានបន្សល់ទុកលិខិត

---

[1] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២១

[2] មាត្រា ១១៤៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧; នីតិសន្តតិកម្ម រៀបរៀងដោយ សាស្ត្រាចារ្យ "**ជ័យ វិទ្ធី**", ទំព័រ ២

[3] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ១៧

[4] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ២១

បណ្តាំពីមតកជន ហើយរាល់ការបែងចែកចំណែកមតិកនោះ គឺត្រូវអនុវត្តទៅតាមច្បាប់ទាំងអស់ ដោយមិនពិចារណាទៅលើឆន្ទៈរបស់មតកជនកាលនៅរស់នោះទេ [5] ។ មូលហេតុដែលនាំឱ្យមាន សន្តតិកម្មតាមច្បាប់នោះ មានពីរដូចតទៅៈ

ទី១ មតកជន ពុំបានបន្សល់ទុកលិខិតបណ្តាំដែលបង្ហាញឆន្ទៈរបស់ខ្លួន ចំពោះការបែងចែក ចំណែកមតិកទៅឱ្យសន្តតិជនណាមួយ ក្នុងទំហំ ឬកម្រិតនៃទ្រព្យសម្បត្តិប៉ុណ្ណានោះទេ អាចក្នុង ករណីទទួលមរណភាពដោយគ្រោះថ្នាក់ចៃដន្យ ឬភ្លាមៗតែម្តង។ ទី២ ពិតជាមានករណីបានធ្វើ លិខិតបណ្តាំដោយមតកជនដែរ ប៉ុន្តែលិខិតបណ្តាំនោះគ្មានសុពលភាពគតិយុត្តអ្វីទេ ដែលបណ្តាល មកពីវាមិនត្រឹមត្រូវ ឬមិនស្របច្បាប់។

### ១.១.២ ចរិតលក្ខណៈនៃសន្តតិកម្មតាមច្បាប់

សន្តតិកម្មតាមច្បាប់ដែលបានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មានចរិតលក្ខណៈចាប់ បង្ខំឱ្យអនុវត្ត និងអនុញ្ញាតឱ្យមានការគោរពទៅលើឆន្ទៈរបស់បុគ្គលឯកជនផងដែរ។ ក្នុងន័យនៃ ចរិតលក្ខណៈចាប់បង្ខំឱ្យអនុវត្ត សំដៅថា សន្តតិជនទាំងអស់ពុំអាចធ្វើការទាមទារសន្តតិកម្ម ឬធ្វើ ការផ្លាស់ប្តូរលំដាប់នៃសន្តតិកម្មដែលច្បាប់បានកំណត់រួចហើយនោះទេ គឺត្រូវគោរពតាមបញ្ញត្តិច្បាប់។ ក្នុងន័យចរិតលក្ខណៈដែលគោរពតាមឆន្ទៈនៃបុគ្គលឯកជនសំដៅលើសន្តតិជននៅតែមានសិទ្ធិ ក្នុងការទទួលបានភាគនៃវិភាគទានដែលខ្លួនបានជួយទំនុកបំរុងទៅលើមតកជន ឬបានសហការ ក្នុងការបង្កើន ឬថែរក្សាផ្នែកសេដ្ឋកិច្ចនៃមតកជន តាមការទាមទារទៅតុលាការ។

ជាងនេះទៅទៀត សន្តតិជននៅតែមានសិទ្ធិក្នុងការយល់ព្រមទទួល ឬបដិសេធដោយការ បោះបង់ក្នុងការទទួលចំណែកមតិករបស់មតកជន ទោះបីជាទទួលបានដោយផ្នែក ឬទាំងអស់នៃ ចំណែកមតិកក៏ដោយ។ ការធ្វើបែបនេះ ដើម្បីតែធ្វើការរក្សាការពារផលប្រយោជន៍របស់សន្តតិជន ព្រោះចំណែកមតិកដែលសន្តតិជនត្រូវទទួលបាន អាចជាកាតព្វកិច្ចច្រើនជាងផលប្រយោជន៍ទៅ វិញ ដែលនាំឱ្យសន្តតិជនក្ស័យធន។

## ១.២ លក្ខខណ្ឌនៃការទទួលបានសិទ្ធិ និងផ្តាច់សិទ្ធិជាសន្តតិជន

ក្រោយពីបានយល់អត្ថន័យ និងចរឹតលក្ខណៈនៃសន្តតិកម្មតាមច្បាប់មក យើងនឹងសិក្សាឱ្យ កាន់តែស៊ីជម្រៅថែមទៀតទៅលើលក្ខខណ្ឌណាខ្លះ ដែលនាំឱ្យសន្តតិជនអាចទទួលបានសិទ្ធិ ដើម្បី បានឋានៈជាសន្តតិជន ដែលបកស្រាយក្នុងចំណុច ១.២.១។ ទន្ទឹមគ្នានេះដែរ យើងនឹងសិក្សាទៅ លើលក្ខខណ្ឌណាខ្លះ ដែលនាំឱ្យសន្តតិជនណាមួយបាត់បង់សិទ្ធិទទួលបានចំណែកមតិកពីមតក

[5] មាត្រា ១១៩៥ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ជន ដែលបកស្រាយក្នុងចំណុច ១.២.២ ដូច្នេះទើបយើងអាចឈានទៅដល់ការកំណត់ចំណែកមតិកបាន។

### ១.២.១ លក្ខខណ្ឌនៃការទទួលបានសិទ្ធិជាសន្តតិជន

លក្ខខណ្ឌចម្បងបំផុត នៃការទទួលបានសិទ្ធិជាសន្តតិជននោះ គឺសន្តតិជនរូបនោះត្រូវតែជាបុគ្គលដែលនៅរស់រានមានជីវិតដល់ថ្ងៃចាប់ផ្តើមសន្តតិកម្ម[6] ទោះស្ថិតនៅក្នុងស្ថានភាពជាទារកក្នុងគភ៌ ចំនុច ១.២.១.១ ឬជារូបវន្តបុគ្គល ១.២.១.២។

#### ១.២.១.១ ករណីសន្តតិជនស្ថិតក្នុងស្ថានភាពជាទារកក្នុងគភ៌

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិឱ្យទារកក្នុងគភ៌របស់ម្តាយ ក៏អាចទទួលបានសិទ្ធិជាសន្តតិជនបានដែរ តែលក្ខខណ្ឌនោះគឺត្រូវតែរស់រានមានជីវិតក្រោយពេលកើត[7]។ ជាគោលការណ៍ ទារកក្នុងគភ៌នឹងត្រូវទទួលបានសន្តតិកម្មគិតចាប់ពីពេលបើកសន្តតិកម្ម ដោយមិនមែនចាប់គិតពីថ្ងៃកើតនោះទេ[8]។ ការតាក់តែងច្បាប់បែបនេះ បានធ្វើឱ្យទារកក្នុងគភ៌ក៏ទទួលបានផលប្រយោជន៍ដែលខ្លួនគួរតែទទួលបានផងដែរ ដោយក្នុងឋានៈជាសន្តតិជននៃសន្តតិកម្ម។

#### ១.២.១.២ ករណីសន្តតិជនជារូបវ័ន្តបុគ្គល

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិអំពីបុគ្គលដែលក្លាយជាម្ចាស់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនបាន លុះត្រាតែជារូបវន្តបុគ្គលដែលមានជីវិតក្រោយពីការកើត[9]។ រូបវន្តបុគ្គលក្នុងន័យនេះ សំដៅទៅលើមនុស្សពិតតាមធម្មជាតិដែលផ្ទុយទៅនឹងនីតិបុគ្គល[10]។ ជាការពិតណាស់ សន្តតិជនដែលជារូបវន្តបុគ្គល មិនត្រឹមមានជីវិតរស់រាននោះទេ សន្តតិជនក៏ត្រូវមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ និងលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច នៃសន្តតិកម្មផងដែរ ពោលគឺមិនមែនជាបុគ្គលដែលច្បាប់បានហាមឃាត់[11]។ មួយវិញទៀត ដើម្បីធ្វើការគ្រប់គ្រងចាត់ចែងទៅលើចំណែកមតិក ដែលជាចំណែករបស់ខ្លួនបាន សន្តតិជននោះក៏តម្រូវឱ្យមានអាយុយ៉ាងហោចណាស់១៨ឆ្នាំផងដែរ[12]។

[6] មាត្រា ១១៤៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[7] មាត្រា ៩ កថាខណ្ឌទី ២ និង កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[8] មាត្រា ៩ កថាខណ្ឌទី ២ និង កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[9] មាត្រា ៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[10] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ១៩

[11] មាត្រា ១១៤៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[12] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ប៉ុន្តែក្នុងករណីដែលក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានលើកលែងដល់សន្តតិជន ដែលមិនទាន់គ្រប់អាយុ១៨ឆ្នាំ ក៏អាចមានសិទ្ធិក្នុងការចាត់ចែងចំណែកមតិកបានដែរ ដូចជាករណីអត្តាធីនភាពដែលបានមកពីតុលាការ ដោយមូលហេតុអាចឯករាជ្យលើខ្លួនឯងបាន តាមរយៈការស្នើសុំរបស់សាមីខ្លួន ឬការយល់ឃើញថាមានផលប្រយោជន៍ចំពោះអនីតិជននោះ[13]។ លក្ខខណ្ឌផ្សេងទៀតក្នុងការទទួលអត្តាធីនភាពដោយពុំចាំបាច់មានការប្រកាសពីតុលាការគឺ អនីតិជនទាំងឡាយណាដែលបានរៀបអាពាហ៍ពិពាហ៍រួច ឬបានរៀបអាពាហ៍ពិពាហ៍ហើយតែលែងលះគ្នាវិញ ក៏អានុភាពនៃអត្តាធីនភាពនៅតែមានដដែល។

ក្នុងករណីដែលសន្តតិជនជាជនបរទេស ដែលមិនមានសញ្ជាតិខ្មែរ ហើយត្រូវទទួលបានចំណែកមតិកតាមសន្តតិកម្ម ឬតាមអច្ច័យទានដែលជាដីធ្លី ហើយមិនមែនជាអគារសហកម្មសិទ្ធិចាប់ពីជាន់ទី១ឡើងទៅ គឺពុំអាចទទួលបានចំណែកសន្តតិកម្មនោះបានឡើយ។ ប្រសិនបើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ សុទ្ធតែពុំមានសញ្ជាតិខ្មែរនោះទេ ដីធ្លីដែលជាចំណែកមតិក ត្រូវបម្លែងក្លាយជាទ្រព្យរបស់នីតិបុគ្គល ធ្វើការគ្រប់គ្រងចាត់ចែងចំណែកមតិកនោះដោយសន្តតិជនទាំងអស់នោះក្នុងនាមជានីតិបុគ្គលនោះ។ ក្នុងរយៈពេល ៣ (បី) ខែ នីតិបុគ្គលនោះត្រូវធ្វើការលក់ចំណែកមតិកដែលជាដីធ្លីនោះ ដោយមានការយល់ព្រមទាំងអស់គ្នា ឬដោយមានកម្រិតពីសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ។ រីឯថ្លៃដែលទទួលបានពីការលក់ចំណែកមតិកក្នុងនាមជានីតិបុគ្គលនោះ នឹងក្លាយជាចំណែកមតិក ធ្វើការចែកឱ្យសន្តតិជនដែលមិនមានសញ្ជាតិខ្មែរទាំងអស់នោះ រីឯនីតិបុគ្គលខាងលើ នឹងត្រូវបញ្ចប់ភារកិច្ច ហើយត្រូវរំលាយចោល។

ផ្ទុយទៅវិញ ប្រសិនបើដីធ្លីដែលគ្រប់គ្រងចាត់ចែងដោយសន្តតិជន ដែលមិនមានសញ្ជាតិខ្មែរទាំងអស់ក្នុងនាមជានីតិបុគ្គល មិនបានលក់ដីធ្លី ក្នុងរយៈពេល៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ យល់ព្រមទាំងស្រុង ឬបានយល់ព្រមដោយមានកម្រិតក្នុងការចាត់ចែងលក់ ដូច្នេះសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ដែលមានសញ្ជាតិខ្មែរ នឹងទទួលបានចំណែកមតិកដែលជាដីធ្លីនោះ រីឯនីតិបុគ្គលនោះត្រូវចាត់ទុកថាគ្មានអត្ថិភាព[14]។ ក្នុងករណីសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ពុំមានសញ្ជាតិខ្មែរ ចំណែកមតិកដែលជាដីធ្លីនោះ នឹងក្លាយជាកម្មសិទ្ធិរបស់រដ្ឋ[15]។

---

[13] មាត្រា ២១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[14] មាត្រា ១១៥៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[15] សៀវភៅ សន្តតិកម្ម រៀបរៀងដោយ មេធាវី "អ៊ីវ ប៉ូលី" ឆ្នាំ២០១០, ទំព័រ ៨

### ១.២.២ លក្ខខណ្ឌនៃការផ្តាច់សិទ្ធិជាសន្តតិជន

ក្រោយពីបានសិក្សាទៅលើលក្ខខណ្ឌក្នុងការទទួលបានសិទ្ធិជាសន្តតិជនហើយ ឥឡូវយើងនឹងធ្វើការសិក្សាទៅលើលក្ខខណ្ឌដែលនាំឱ្យសន្តតិជនបាត់បង់សិទ្ធិជាសន្តតិជនម្តង ដែលអាចជាករណីអភ័ព្វបុគ្គល ចំណុច ១.២.២.១ ឬក្នុងករណីបុគ្គលត្រូវបានផ្តាច់ពីមរតក ចំណុច ១.២.២.២ ដោយមតកជនកាលនៅរស់រានមានជីវិត។

#### ១.២.២.១ ករណីអភ័ព្វបុគ្គល

ពាក្យ "អភ័ព្វបុគ្គល" សំដៅលើបុគ្គលទាំងឡាយណាដែលបាត់បង់សិទ្ធិជាសន្តតិជន និងមិនអាចទទួលបានចំណែកមតិកអ្វីទាំងអស់ ដោយសារបុគ្គលទាំងនោះបានប្រព្រឹត្ត ឬស្ថិតនៅក្នុងលក្ខខណ្ឌដូចខាងក្រោម ដោយយោងតាមមាត្រា ១១៥០នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧៖

ទី១ បុគ្គលដែលទទួលទោស ឬដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតលើមតកជន ឬលើជនដែលមានលំដាប់សន្តតិកម្មមុន ឬលំដាប់ស្មើគ្នាទោះបីជាដោយផ្ទាល់ក្តី ឬ ប្រយោលក្តី។

ទី២ បុគ្គលដែលដឹងអំពីការសម្លាប់មតកជនតែមិនរាយការណ៍ ឬមិនបានប្តឹង។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះមិនអាចវិនិច្ឆ័យអំពើល្អ ឬអាក្រក់បាន ឬករណីអ្នកសម្លាប់ជាសហព័ទ្ធ ឬញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ។

ទី៣ បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬកែប្រែមតកសាសន៍ ស្តីពីសន្តតិកម្មដោយការឆបោក ឬគំរាមកំហែង។

ទី៤ បុគ្គលដែលបានធ្វើឱ្យមតកជនធ្វើ លុបចោល ឬកែប្រែមតកសាសន៍ ស្តីពីសន្តតិកម្មដោយការឆបោក ឬគំរាមកំហែង។

ទី៥ បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬលាក់ទុកនូវលិខិតមតកសាសន៍ ស្តីពីសន្តតិកម្មរបស់មតកជន[16]។

#### ១.២.២.២ ករណីបុគ្គលត្រូវបានផ្តាច់ពីមត៌ក

បុគ្គលមួយប្រភេទទៀតដែលនឹងមិនបានទទួលចំណែកមតិកពីមតកជនដែរនោះ គឺបុគ្គលត្រូវបានផ្តាច់ពីមតិក ដោយសារតែមតកជនបានដាក់ពាក្យប្តឹងទៅតុលាការ ក្នុងការផ្តាច់មតិកពីសន្តតិជនរូបនោះកុំឱ្យមានសិទ្ធិទទួលចំណែកមតិកនៃសន្តតិកម្ម កាលពីមតកជននៅរស់។ ក្នុងន័យនេះ លក្ខខណ្ឌរបស់វាគឺតម្រូវឱ្យមានការបង្ហាញឆន្ទៈពីមតកជនពេលនៅរស់ និងការត្រួតពិនិត្យ

[16] មាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ភាពត្រឹមត្រូវ នៃពាក្យស្នើសុំរបស់មតកជននោះពីតុលាការ។ សកម្មភាពដែលច្បាប់បានចែងនោះមានដូចតទៅ៖

- ទី១ បុគ្គលដែលបានធ្វើបាប ចំពោះមតកជន
- ទី២ បុគ្គលដែលបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ
- ទី៣ បុគ្គលដែលអាចមើលថែទាំមតកជនពេលដែលមានជំងឺ ប៉ុន្តែបែរជាមិនមកថែទាំ
- ទី៤ បុគ្គលដែលបានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត
- ទី៥ បុគ្គលដែលបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរ គួរឱ្យកត់សម្គាល់ជាអាទិ៍[17]។

## ១.៣ អំពីអានុភាពនៃសន្តតិកម្មតាមច្បាប់

ក្នុងចំណុចនេះយើងនឹងបកស្រាយអំពីអានុភាពដែលជាផលគតិយុត្ត ដោយកើតអំពីសន្តតិកម្មតាមច្បាប់។ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានចែងអំពីការចាប់ផ្តើមសន្តតិកម្ម ដោយកំណត់ឱ្យច្បាស់នូវ "ពេលវាលាបើកសន្តតិកម្មតាមច្បាប់" ដែលសិក្សាក្នុងចំណុច ១.៣.១ និង "ទីកន្លែងបើកសន្តតិកម្មតាមច្បាប់" ដែលសិក្សាក្នុងចំណុច ១.៣.២។ ការកំណត់ដូច្នេះ ដើម្បីផ្តល់លក្ខណៈងាយស្រួលក្នុងការកំណត់រកតុលាការដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទចំពោះរឿងក្តីសន្តតិកម្ម ក្នុងករណីវិវាទបានកើតមានឡើង។

### ១.៣.១ ពេលវេលាបើកសន្តតិកម្មតាមច្បាប់

ជាគោលការណ៍ សន្តតិកម្មនឹងត្រូវបានចាប់ផ្តើមក្នុងករណី ដែលមតកជនត្រូវបានទទួលមរណភាព ចំណុច ១.៣.១.១ ឬក្នុងករណីដែលមតកជននោះបានបាត់ខ្លួន ចំណុច ១.៣.១.២។

#### ១.៣.១.១ ករណីបានទទួលមរណភាព

ជាទូទៅ លុះត្រាតែមតកជនបានទទួលមរណភាព ទើបច្បាប់អនុញ្ញាតឱ្យមានការបើកសន្តតិកម្មធ្វើការចែកចំណែកចំពោះទ្រព្យសម្បត្តិរបស់មតកជននោះ ផ្ទុយទៅវិញ ប្រសិនបើមិនមានមរណភាពរបស់មតកជនទេ គ្មានការបើកសន្តតិកម្មនោះទេ[18]។ ជាការពិតណាស់ មតកជនទទួលមរណភាពភ្លាម សន្តតិកម្មនឹងចាប់ផ្តើមភ្លាម ប៉ុន្តែមានតែសំបុត្រមរណភាពដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានទេ ទើបបញ្ជាក់អំពីការទទួលមរណភាពនៃមតកជនបាន។

#### ១.៣.១.២ ករណីបាត់ខ្លួន

ក្រៅពីករណីទទួលមរណភាពនៃមតកជន ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏បានផ្តល់នូវលក្ខខណ្ឌមួយទៀតក្នុងការចាប់ផ្តើមសន្តតិកម្មដែរ នោះគឺការបាត់ខ្លួន។ ការបាត់ខ្លួនសំដៅទៅលើ

[17] មាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[18] មាត្រា ១១៥៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

បុគ្គលមួយរូបដែលមិនមានវត្តមានក្នុងលំនៅដ្ឋានខ្លួន ព្រមទាំងមិនមានព័ត៌មានអ្វីទាំងអស់ពីបុគ្គលនេះ ឬក្នុងកាលៈទេសៈគ្រោះថ្នាក់បាត់បង់ជីវិតហើយពុំអាចដឹងបានថាបុគ្គលនោះស្លាប់ ឬរស់[19]។

ក្នុងករណីនេះ អ្នកដែលមានប្រយោជន៍ពាក់ព័ន្ធនៃបុគ្គលដែលបាត់ខ្លួន ដូចជាសហព័ទ្ធ អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល និងឪពុកម្តាយ អាចប្តឹងទៅតុលាការបាន ក្រោយរយៈពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលបាត់ខ្លួនដោយគ្មានដំណឹងច្បាស់លាស់ថាស្លាប់ ឬរស់នោះ[20]។ ប្រសិនបើបាត់ខ្លួនក្រោយរយៈពេល១ (មួយ) ឆ្នាំ ក្នុងសង្គ្រាម ឬនៅពេលនាវាលិច ឬជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងៗ ដែលគ្មានសង្ឃឹមថានៅរស់ អ្នកមានផលប្រយោជន៍ពាក់ព័ន្ធអាចប្តឹងទៅតុលាការបាន[21]។

ក្នុងករណីដែលតុលាការបានចេញសេចក្តីសម្រេចប្រកាសអំពីការបាត់ខ្លួន បុគ្គលនោះនឹងត្រូវចាត់ទុកថា បានទទួលមរណភាពដែលសេចក្តីសម្រេចប្រកាសនោះ មានតម្លៃស្មើនឹងសំបុត្រមរណភាព[22]។ អាស្រ័យហេតុនេះ ថ្ងៃដែលចេញសេចក្តីសម្រេចប្រកាសអំពីការបាត់ខ្លួន ត្រូវចាត់ទុកថ្ងៃចាប់ផ្តើមសន្តតិកម្ម។

### ១.៣.២ ទីកន្លែងបើកសន្តតិកម្មតាមច្បាប់

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានកំណត់យកលំនៅឋានរបស់មតកជនដែលបានស្នាក់នៅចុងក្រោយមកធ្វើជាទីកន្លែងចាប់ផ្តើមសន្តតិកម្មនៃមតកជន [23] ។ ក្នុងករណីដែលបុគ្គលមានលំនៅឋានច្រើន ការកំណត់លំនៅឋានចុងក្រោយរបស់មតកជនគឺជាគន្លឹះក្នុងការបើកសន្តតិកម្ម ដើម្បីឱ្យដឹងថាតុលាការណាដែលមានសមត្ថកិច្ចក្នុងការដោះស្រាយរឿងក្តីនោះ។ ដូច្នេះ មានតែកំណត់ហេតុនៃសៀវភៅស្នាក់នៅ ដែលបានកត់ត្រាដោយនគរបាលរដ្ឋបាលប៉ុណ្ណោះក្នុងការកំណត់ពីលំនៅឋានចុងក្រោយបាន។

[19] មាត្រា ៨១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[20] មាត្រា ៨១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[21] មាត្រា ៨១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[22] មាត្រា ៨៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[23] មាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

# ជំពូកទី២

# អំពីរបបបែងចែកមត៌កនៃសន្តតិកម្មតាមច្បាប់

# ជំពូកទី២
# អំពីរបបបែងចែកមត៌កនៃសន្តតិកម្មតាមច្បាប់

ក្រោយពីបានសិក្សាស្វែងយល់ពីចំណុច និងលក្ខណៈទូទៅនៃសន្តតិកម្មតាមច្បាប់រួចហើយ នោះនៅក្នុងជំពូកទី២ យើងនឹងធ្វើការបកស្រាយអំពីរបបនៃការបែងចែកមត៌ក នៃសន្តតិកម្មតាមច្បាប់ ដែលយើងបានបែងចែកជា៤ផ្នែក ដោយចំណុច ២.១ យើងនឹងសិក្សាលើ លំដាប់នៃសន្តតិជន ចំណុច ២.២សិក្សាទៅលើចំណែកដែលសន្តតិជននីមួយៗទទួលបាន ចំណុច ២.៣ យើងសិក្សាទៅលើការសម្រួលមត៌ក និងចំណុច ២.៤ យើងសិក្សាទៅលើភាគបម្រុង។

## ២.១ ការកំណត់អំពីលំដាប់នៃសន្តតិជន

យើងដឹងហើយថាសន្តតិកម្មតាមច្បាប់ គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ច របស់មតកជន ដែលបានទទួលមរណភាពឬបានបាត់ខ្លួន ទៅកាន់សន្តតិជនម្នាក់ឬច្រើននាក់ ទៅតាមបញ្ញត្តិច្បាប់ ដែលបានចែង។ ចំពោះលំដាប់សន្តតិជន គឺជាឋានានុក្រមបុគ្គលដែលមានសិទ្ធិត្រូវមកចូលរួមក្នុង ការទទួលបាននូវមត៌ករបស់មតកជន។ ប្រសិនបើយោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា លំដាប់សន្តតិជនត្រូវបានកំណត់ជា ៣ (បី) លំដាប់ ដែលសុទ្ធតែជាសាច់ញាតិ របស់មកតជន ដែលអាចជាបច្ឆាញាតិ បុព្វញាតិ និងសាខាញាតិ។ លំដាប់ទី១ គឺជាកូនរបស់មតកជនរួមទាំងកូនបង្កើត និងកូនសុំផងដែរ។ លំដាប់ទី២ គឺសំដៅលើបុព្វញាតិខ្សែផ្ទាល់របស់មតកជន ជាឪពុកម្តាយ ឬជីដូនជីតាជាដើម។ ចំណែកលំដាប់ទី៣ វិញគឺបងប្អូនបង្កើត ឬរួមតែម្តាយ ឬរួមតែឪពុក។ យើងអាចឃើញថាជន ដែលជាសន្តតិជនក្នុងក្របខណ្ឌនៃសន្តតិជនតាមច្បាប់ គឺជាសាច់ញាតិរបស់មតកជន។ ក្នុងជំពូកនេះ ក៏បានលើកឡើងនូវករណីសន្តតិកម្មជំនួស ដែលជាករណីសន្តតិជនទទួលមរណភាពជាដើម។ ក្រៅពីសន្តិជនតាមញាតិលោហិត និងសន្តតិកម្មជំនួសក៏មាន សន្តតិជនពិសេសមួយទៀតដែល ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានចែងដែរ គឺសន្តតិជនជាសហព័ទ្ធ។

### ២.១.១ សន្តតិជនលំដាប់ទី១

កូនរបស់មតកជន ជាសន្តតិជនលំដាប់ទី១ ទោះបីជាសន្តតិជននោះជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា[24] ។ មានន័យថាក្នុងកាលៈទេសៈណាក៏ដោយ ចំណែកមត៌ករបស់មតកជនគឺត្រូវបានទៅលើកូនរបស់មតកជនជានិច្ច។ ចំពោះពាក្យថា កូន មានន័យថា កូន ដែលមានបុគ្គភាពត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់[25] ដោយរាប់ទាំងកូន ដែលកើតក្រៅចំណង

[24] មាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[25] ទំព័រទី១៤ សេចក្តីកំនត់ក្រមរដ្ឋប្បវេណី ភាគ៦ : គន្លឹទី៨ និង៩ ក្រសួងយុត្តិធម៌

អាពាហ៍ពិពាហ៍(កូនឥតខាន់ស្លា) ក៏ត្រូវមានសិទ្ធិទទួលចំណែកមតិក និងកូនបង្កើតដែលមានចំណាងអាពាហ៍ពិពាហ៍ផងដែរ។ ឧទាហរណ៍៖ ក ដែលជាមតកជនមានកូនបង្កើតឈ្មោះ ខ និង គ ពីរនាក់ ព្រមទាំងមានកូនសុំ ឈ្មោះ ឃ ម្នាក់ផងដែរ ដូចនេះយើងអាចឃើញថា ខ គ និង ឃ អាចក្លាយជាសន្តតិជនលំដាប់ទី១។ ចំពោះកូនក្រៅអាពាហ៍ពិពាហ៍ទៀតសោត ទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយ ប្រសិនបើទំនាក់ទំនងនោះមិនត្រូវបានទទួលស្គាល់តាមច្បាប់នោះទេ បុត្តភាពតាមផ្លូវច្បាប់ក៏មិនអាចទទួលស្គាល់បានដែរ ដូច្នេះកូនដែលមិនត្រូវបានទទួលស្គាល់នោះមិនអាចទទួលបាននូវចំណែកមតិក និងក្លាយជាសន្តតិជនរបស់ឪពុកបានឡើយ។ ជាទូទៅសំបុត្រកំណើតគឺជា ភស្តុតាងមួយដ៏សំខាន់ក្នុងការបញ្ជាក់ពីទំនាក់ទំនងគតិយុត្តរវាងកូន និងឪពុកម្តាយ។ វាជាករណីយកិច្ចរបស់ឪពុកម្តាយ ដែលត្រូវសុំចុះសំបុត្រកំណើតកូន ទោះបីជាឪពុកម្តាយនោះបានរៀបអាពាហ៍ពិពាហ៍ ឬមិនបានរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ ការចុះអត្រានុកូលដ្ឋានជាតួនាទីរបស់មន្ត្រីអត្រានុកូលដ្ឋាន ដែលជាមេឃុំ ឬចៅសង្កាត់ស្ថិតក្នុងដែនដីឃុំ ឬសង្កាត់ដែលខ្លួនបានគ្រប់គ្រង [26]។ ឪពុក ឬម្តាយរបស់កូនត្រូវចុះសំបុត្រកំណើត នៅសាលាឃុំ ឬសង្កាត់នៃលំនៅឋានរបស់ឪពុកម្តាយក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃគិតពីថ្ងៃដែលកូននោះបានកើត[27]។ ក្នុងករណីដែលម្តាយឪពុកមិនអាចសុំចុះបានទេនោះ ញាតិដែលជានីតិជនដែលរស់នៅជាមួយឪពុកម្តាយនៃកូនត្រូវសុំចុះកំណើតរបស់កូននោះឱ្យបានឆាប់រហ័ស។ ឧទាហរណ៍ ករណីឪពុកនៅឆ្ងាយជាដើមហើយម្តាយរបស់កូននោះទៀតសោត មានសភាពខ្សោយ ដោយសារទើបសម្រាលកូន(សរសៃខ្ចី)។ ប្រសិនបើម្តាយឪពុក បានធ្វេសប្រហែសនឹងករណីយកិច្ចសុំចុះសំបុត្រកំណើតរបស់កូននោះ តាមពេលវេលាកំណត់ខាងលើត្រូវពិន័យស៊ីវិលជាប្រាក់មិនលើសពី ១០.០០០ (មួយម៉ឺន) រៀល [28]។

ចំពោះករណីកូនដែលបានសុំ តាមសុំកូនពេញលេញ ញាតិភាពតាមផ្លូវច្បាប់ជាមួយនឹងឪពុកម្តាយបង្កើតត្រូវបានបញ្ចប់តាមមាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ នោះកូននោះមិនអាចទទួលបានចំណែកមតិកពីឪពុកម្តាយបង្កើតនោះទេ ពោលគឺអាចត្រឹមតែទទួលបានពីឪពុកម្តាយចិញ្ចឹមតែប៉ុណ្ណោះ។ ចំណែកឯសុំកូនធម្មតាវិញ អាចទទួលសន្តតិកម្មពីឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង[29]។

---

[26] មាត្រា៨ នៃអនុក្រឹត្យលេខ១០៣អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០

[27] មាត្រា៩៨៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[28] មាត្រា៩៨៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[29] មាត្រា១០២៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

### ២.១.២ សន្តតិជនលំដាប់ទី២

នៅពេលដែលមតកជនមិនមានបច្ឆាញាតិផ្ទាល់ ដែលនឹងត្រូវក្លាយជាសន្តតិជននោះទេ បុព្វញាតិផ្ទាល់របស់មតកជននឹងក្លាយជាសន្តតិជន ដែលក្លាយជាសន្តតិជនលំដាប់ទី២។ មូលហេតុដែលគេបានកំណត់យកបុព្វញាតិផ្ទាល់ដែលជាឪពុកម្ដាយ ជីដូនជីតា របស់មតកជនជាសន្តតិជនលំដាប់ទី២ ដោយគេគិតថាអ្នកទាំងនោះគឺជាអ្នកដែលទទួលបានការគោរពពីមតកជន និងជាអ្នកបានមើលថែទាំ ចិញ្ចឹមបីបាច់មតកជន ដែលជាកូន ឬចៅ។ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានកំណត់ផងដែរថា អ្នកដែលជាបុព្វញាតិ ដែលមានលំដាប់ថ្នាក់ជិតជាងគេ[30] ទៅនឹងមតកជនជាអ្នកដែលមានអាទិភាពទទួលបានចំណែកមត៌ក។ នោះឪពុកម្ដាយរបស់មតកជននឹងក្លាយសន្តតិជនលំដាប់ទី២ មុនជីដូនជីតា។

ក្នុងករណីសន្តតិជនលំដាប់ទី២នេះ បើមានសន្តតិជនជំនួសនោះគឺមិនមានការទទួលស្គាល់ឡើយ ដោយហេតុថា កូនគឺជាអ្នកទទួលនូវមត៌ករបស់សន្តតិជន ហើយប្រសិនបើកូននេះជាបុព្វញាតិផ្ទាល់របស់មតកជន(បងប្អូនបង្កើត) នោះច្បាប់បានទទួលស្គាល់រួចជាស្រេចថាគាត់គឺជាសន្តតិជនលំដាប់ទី៣។

### ២.១.៣ សន្តតិជនលំដាប់ទី៣

ជាករណីបង្ការមួយផងដែរ នៅពេលដែលសន្តិតិជនមិនមានទាំងបច្ឆាញាតិ មិនមានទាំងបុព្វញាតិដែលនឹងត្រូវក្លាយជាសន្តតិជនស្នងមរតកនោះទេ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានចែងថាបងប្អូនរបស់មតកជននឹងក្លាយជាសន្តតិជនលំដាប់ទី៣[31]។ ទោះបីជាបងប្អូនបង្កើតរបស់មតកជនមានប៉ុន្មាននាក់ក៏ដោយ ក៏បងប្អូនបង្កើតម្នាក់ៗត្រូវទទួលបានចំណែកមត៌កស្មើៗគ្នាជានិច្ច។ ប៉ុន្តែចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្ដាយតែម្ខាងដូចគ្នាទៅនឹងមតកជន អាចទទួលបានតែ ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និងម្ដាយទាំងសងខាងដូចគ្នា។

ឧទាហរណ៍៖ លោក ក ជាមតកជនបានទទួលមរណភាពដោយគ្មានកូន ហើយឪពុកម្ដាយរបស់គាត់បានទទួលមរណភាពដូចគ្នា។ លោក ក មានបងប្អូនបង្កើត ចំនួន២នាក់គឺ ខ និង គ។ ឪពុករបស់លោក ក ពេលនៅរស់មានកូនផ្សេងម្នាក់ទៀតឈ្មោះ ឃ ដែលមានម្ដាយខុសគ្នាពីលោក ក។ ដូចនេះសន្តតិជនរបស់លោក ក គឺ ខ គ និង ឃ ហើយចំណែកមត៌ករបស់ ឃ គឺស្មើនឹងពាក់កណ្ដាលនៃចំណែកមត៌ករបស់ ខ និង គ ដែលជាបងប្អូនបង្កើតមានឪពុកម្ដាយរួមគ្នា។ នោះ ខ និង គ ទទួលបានចំណែកមត៌កម្នាក់ ២ ភាគ ៥ រីឯ ឃ ទទួលបានតែ១ ភាគ ៥ ប៉ុណ្ណោះ។

[30] មាត្រា១១៦១ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[31] មាត្រា១១៦០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

### ២.១.៤ សន្តតិជនជំនួស

ករណីដែលកូនរបស់មតកជនបានទទួលមរណភាព នៅមុនពេល ឬព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ឬបាត់បង់សិទ្ធិសន្តតិកម្ម ដោយមូលហេតុអភ័ព្វបុគ្គលនៃសន្តតិកម្ម(មាត្រា១១៥០នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា) ឬដោយការផ្តាច់មតិក កូនរបស់សន្តតិជននោះនឹងក្លាយជាសន្តតិជនជំនួស [32] ។ ក្នុងករណីដែលកូនរបស់មតកជនទទួលមរណភាពក្រោយពេលចាប់ផ្តើមសន្តតិកម្ម សន្តតិជនដែលស្លាប់នោះទទួលសន្តតិកម្មរបស់មតកជន ហើយកូនរបស់សន្តតិជនដែលស្លាប់នោះ នឹងទទួលសន្តតិកម្មបន្តទៀត ដោយសារតែមរណភាពរបស់សន្តតិជនដែលស្លាប់នោះ [33] ។ ចំពោះករណីសុំកូនវិញ នៅពេលដែលមតកជនបានសុំកូនដែលមានកូនរួចហើយតាមរយៈសុំកូនធម្មតានោះ កូនរបស់កូនសុំនោះមិនអាចក្លាយជាសន្តតិជនជំនួសបានឡើយ ដោយសារកូននោះមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ប៉ុន្តែលើកលែងក្នុងករណីដែលកូនរបស់កូនសុំធម្មតានោះ កើតក្រោយពេលដែលបានសុំកូន កូននោះអាចក្លាយជាសន្តតិជនជំនួសបាន ដោយហេតុថាកូនដែលកើតនោះជាបច្ឆាញាតិផ្ទាល់របស់មតកជន និងមិនអាចត្រូវបានហាមឃាត់ដោយវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។

ការទទួលបន្តនូវសន្តតិកម្មជំនួស ដោយមូលហេតុដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា១១៥៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ គឺដោយមូលហេតុអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬដោយការផ្តាច់មតិក នាំឱ្យកូនរបស់សន្តតិជនក្លាយជាសន្តតិជនជំនួសបន្តទៀត ហើយប្រសិនបើ កូន និង ចៅរបស់មតកជនបានទទួលមរណភាពទៀតនោះ ចៅទួតនឹងទទួលមរតកបន្តទៀត ដែលជាការទទួលមតិកជាបន្តបន្ទាប់គ្នា។ គេអនុវត្តបែបនេះជាបន្តបន្ទាប់ផងដែរ ប្រសិនបើចៅទួតមានមូលហេតុដូចគ្នានេះ។ ការអនុវត្តសន្តតិកម្មជំនួសបន្តបន្ទាប់បែបនេះអាចអនុវត្តបានចំពោះតែសន្តតិជនដែលជាកូនរបស់មតកជន ពោលគឺជាបច្ឆាញាតិផ្ទាល់របស់មតកជនតែប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងករណីដែលបងប្អូនបង្កើតដែលជាសន្តតិជនលំដាប់ទី ៣ ជាអ្នកទទួលបានមតិកវិញ ច្បាប់ទទួលស្គាល់សន្តតិកម្មជំនួសត្រឹមតែមួយតំណប៉ុណ្ណោះ ពោលគឺក្មួយរបស់មតកជនអាចក្លាយជាសន្តតិជនជំនួសបាន [34] ។ ប៉ុន្តែពុំមានករណីសន្តតិកម្មជំនួសដែលធ្វើឡើយដោយកូនរបស់ក្មួយប្រុស ឬក្មួយស្រីឡើយ។

---

[32] មាត្រា១១៥៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[33] ទំព័រទី១៥ សេចក្តីកំនត់ក្រមរដ្ឋប្បវេណី ភាគ៦ : គន្លឹះទី៨ និង៩ ក្រសួងយុត្តិធម៌

[34] មាត្រា១១៦០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ចំណែកមតិកនៃសន្តតិជន ត្រូវបានគេអនុវត្តដូចគ្នាទៅនឹងចំណែកមតិក ដែលបុព្វញាតិផ្ទាល់ទទួលបាន ដោយត្រូវបានចំណែកស្មើៗគ្នា លើកលែងតែក្នុងករណីដែលមានបច្ឆាញាតិផ្ទាល់ច្រើននាក់ ត្រូវបែងចែកស្មើៗគ្នារវាងបច្ឆាញាតិទាំងឡាយដែលជាសន្តតិជនជំនួស ដោយធៀបទៅនឹងចំណែកមតិករបស់បុព្វញាតិរបស់ពួកគេទទួលបាន។ ឧទាហរណ៍៖ លោក ក ដែលជាមតកជនមានកូនចំនួន ៤ នាក់ គឺ ខ គ ឃ និង ង។លោក ង បានទទួលមរណភាពមុនពេលចាប់ផ្ដើមសន្តតិកម្ម ដោយលោកបន្សល់ទុកកូនចំនួន ២ នាក់គឺ ច និង ឆ។ ករណីនេះ ខ គ ឃ និង ង ត្រូវទទួលបានចំណែកស្មើៗគ្នាម្នាក់ ១ ភាគ ៤។ នោះចំណែក ច និង ឆ ដែលជាអ្នកទទួលសន្តតិកម្មជំនួសពី ង ទទួលបានចំណែកស្មើគ្នាទៅលើចំណែកមតិក ១ ភាគ ៤ របស់ ង ដោយទទួលបាន ១ ភាគ ៨។

ប្រសិនបើយើងក្រឡេកមើក ក្នុងករណីសន្តតិជនលំដាប់ទី២វិញ ដែលបុព្វញាតិផ្ទាល់ត្រូវទទួលនូវមតិកនោះ ច្បាប់មិនបានទទួលស្គាល់នូវសន្តតិកម្មជំនួសឡើយ ដោយហេតុថាកូនរបស់សន្តតិជនគឺ ត្រូវជាបងប្អូនរបស់មតកជនរួចទៅហើយ ដែលជាសន្តតិជនលំដាប់ទី៣តាមច្បាប់។

បន្ទាប់ពីសន្តតិជនតាមញាតិលោហិតទាំង៣លំដាប់ និងសន្តតិជនជំនួសនោះ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ក៏បានបញ្ញត្តិនូវសន្តតិជនពិសេសមួយប្រភេទទៀតដែរគឺ ប្ដីឬប្រពន្ធរបស់មតកជន។

### ២.១.៥ សន្តតិជនជានិច្ច

ករណីដែលមតកជនមានសហព័ទ្ធ នោះសហព័ទ្ធនោះក៏អាចទទួលបាននូវចំណែកមតិករបស់មតកជនបានដែរ ទោះបីជាសហព័ទ្ធមិនមាននូវទំនាក់ទំនងញាតិលោហិតជាមួយមតកជនដូចនឹងសន្តតិជនដទៃក៏ដោយ ដែលករណីនេះក្រមរដ្ឋប្បវេណីបានទទួលស្គាល់សហព័ទ្ធនោះថាសន្តតិជនជានិច្ច[35]។ ទោះបីជាមាននូវសន្តតិជន ឬគ្មានសន្តតិជនផ្សេងៗទៀតក៏ដោយ ក៏សហព័ទ្ធត្រូវបានច្បាប់ទទួលស្គាល់សិទ្ធិសន្តតិកម្ម ហើយជាពិសេសត្រូវទទួលបាននូវមតិកដែលជាចំណែកនៃទ្រព្យដោយឡែក និងទ្រព្យរួមរបស់មតកជន។ ពាក្យថា ជានិច្ច នៅក្នុងន័យនេះសម្ដៅទៅលើការគ្មានការពាក់ព័ន្ធនឹងអត្ថិភាពរបស់សន្តតិជនផ្សេងព្រមទាំងលំដាប់សន្តតិកម្មឡើយ។ ជានិច្ចកាលសន្តតិជនជានិច្ចត្រូវទទួលបាននូវចំណែកមតិកជាមួយនឹងសន្តតិជនផ្សេងៗទៀត គ្រប់លំដាប់ទាំងអស់ ដោយមិនគិតថាជាបុព្វញាតិ បច្ឆាញាតិ ឬក៏ជាបងប្អូនបង្កើតឡើយ។ ប្រសិនបើមតកជនណាម្នាក់ គ្មានសន្តតិជនពីលំដាប់ទី១ ដល់លំដាប់ទី ៣ នោះទេ សហព័ទ្ធនឹងទទួលសន្តតិកម្មតែម្នាក់ឯង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១១៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧[36]។

---

[35] មាត្រា១១៦១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[36] ទំព័រទី២១ សេចក្ដីកំនត់ក្រមរដ្ឋប្បវេណី ភាគ៦ : គន្លឹទី៨ និង៩ ក្រសួងយុត្តិធម៌

## ២.២ ការកំណត់អំពីចំណែកដែលសន្តតិជនត្រូវទទួលបាន

### ២.២.១ ករណីមានតែញាតិ

ក្នុងកថាខណ្ឌនេះ យើងនឹងបកស្រាយករណីដែលសន្តតិជនត្រូវជាញាតិជាមួយនឹងមតកជនតែប៉ុណ្ណោះ។ ពាក្យ "ញាតិ" ក្នុងសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីសំដៅដល់ញាតិលោហិតក្នុង៦ថ្នាក់ សហព័ទ្ធ និងញាតិពន្ធក្នុង៣ ថ្នាក់។ តើញាតិនៃមតកជនណាខ្លះ ដែលអាចទទួលនូវចំណែកមតិកបាន?

#### ២.២.១.១ បច្ឆាញាតិ

ក្នុងករណីនេះគឺយើងសម្តៅដល់បច្ឆាញាតិដែលជាកូន របស់មតកជន ថាត្រូវទទួលបានចំណែកមតិកបានប៉ុន្មាន។ កូនរបស់សន្តតិជន ដែលជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវទទួលបានចំណែកមតិកពីមតកជនស្មើៗគ្នា[37] មិនថាកូននោះជាកូនសុំធម្មតា ឬពេញលេញនោះទេ។ ចំណែកមតិករបស់មតកជនត្រូវចែកឱ្យបានស្មើៗគ្នាទៅដល់សន្តតិជននីមួយៗ ប្រសិនបើមានសន្តតិជនច្រើន ប៉ុន្តែប្រសិនបើសន្តតិជនមានតែម្នាក់នោះមិនចាំបាច់បែងចែកឡើយ។ កូនក្រៅអាពាហ៍ពាហ៍ក៏ត្រូវមានចំណែកមតិកស្មើគ្នានឹងកូនកើតដោយមានចំណងអាពាហ៍ពិពាហ៍ដែរ[38]។

ឧទាហរណ៍ទី១៖ មតកជនមានកូនបង្កើតចំនួនម្នាក់គឺ ក និងកូនសុំ២នាក់ទៀតគឺ ខ និង គ។ ដូចនេះ កូនទាំង ៣ នាក់របស់មតកជនត្រូវទទួលបាននូវចំណែកមតិក ដោយម្នាក់ទទួលបាន ១/៣ (មួយភាគបី) នៃចំណែកមតិកសរុបទាំងអស់។




ឧទាហរណ៍ទី២៖ មតកជន ក មានកូនចំនួន៣នាក់គឺ ខ គ និង ឃ។ នៅពេលដែលបើកសន្តតិកម្ម ខ បានទទួលមរណភាព ហើយគាត់មានកូនចំនួន២នាក់ គឺ ខ១ និង ខ២។ ចំណែក គ វិញជាអភ័ព្វបុគ្គល តែគាត់មានកូនចំនួន៣នាក់ គឺ គ១ គ២ និង គ៣។ ក្នុងករណីនេះយើងឃើញថា ខ និង គ មិនអាចទទួលបានចំណែកមតិកបានទេ។ ករណីសន្តតិកម្មជំនួសនេះ ពេលដែលសន្តតិជនទទួលមរណភាព ឬបានបាត់បង់សិទ្ធិដោយបុព្វហេតុណាមួយផ្សេងៗនោះ(អភ័ព្វបុគ្គលជាអាទ៍) នោះចំណែកមតិកនឹងបានទៅលើកូនរបស់សន្តតិជនវិញ។ នោះកូនរបស់ ខ ចំនួន២នាក់ គឺ ខ១

[37] មាត្រា១១៥៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[38] ទំព័រទី១៥ សេចក្តីកំនត់ក្រមរដ្ឋប្បវេណី ភាគ៦ : គន្លឹទី៨ និង៩ ក្រសួងយុត្តិធម៌

និង ខ២ និងកូនរបស់ គ គឺ គ១ គ២ និង គ៣ ដែលត្រូវជាបច្ចាញាតិផ្ទាល់ត្រូវទទួលបានចំណែកមតិក ដោយចែកជា៖

- ចំណែក ១/៣(មួយភាគបី) របស់ ខ ត្រូវបែងចែកឱ្យកូន ចំនួន២នាក់ គឺ ខ១ និង ខ២
- ចំណែក ១/៣(មួយភាគបី) របស់ គ ត្រូវបងចែកឱ្យកូនចំនួន៣នាក់ គឺ គ១ គ២ និង គ៣
- ចំណែករបស់ ឃ គឺ ១/៣ (មួយភាគបី)




### ២.២.១.២ បុព្វញាតិ

ក្នុងករណីដែលមកតជនពុំមាននូវកូនក្នុងការស្នងមតិកនោះទេ ឪពុកម្តាយរបស់មតកជនដែលជាបុព្វញាតិនឹងត្រូវក្លាយជាសន្តតិជន [39] ។ ចំណែកនៃមតិករបស់សន្តតិជននីមួយៗត្រូវមានចំណែកស្មើៗគ្នា ពោលគឺម្នាក់ពាក់កណ្តាលនៃមតិករបស់មតកជន។ ករណីដែលមានឪពុកម្តាយច្រើននាក់(តាមរយៈសុំកូនធម្មតា)នោះចំណែកនៃសន្តតិជននីមួយៗត្រូវទទួលបានស្មើៗគ្នា [40]។




យើងបានបកស្រាយពីខាងលើរួចមកហើយថាអ្នកដែលជាបុព្វញាតិ ដែលមានលំដាប់ថ្នាក់ជិតជាងគេទៅនឹងមតកជនជាអ្នក ដែលមានអាទិភាពទទួលចំណែកមតិក មានន័យថាឪពុកម្តាយជាអ្នកទទួលបានមតិក ប៉ុន្តែក្នុងករណីដែលគ្មានឪពុកម្តាយទេនោះ ជីដូនជីតានឹងត្រូវក្លាយជាសន្តតិជនបន្ត ដោយត្រូវទទួលបានចំណែកមតិកស្មើៗគ្នា។

[39] មាត្រា១១៥៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[40] មាត្រា១១៥៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា




**២.២.១.៣ សាខាញាតិ**

នៅពេលដែលគ្មានបុព្វញាតិក្នុងការទទួលសន្តតិកម្មទេ នោះបងប្អូនបង្កើតរបស់មតកជនត្រូវក្លាយជាសន្តតិជន។ ក្នុងករណីបងប្អូនបង្កើតរួមឪពុកម្តាយ មានច្រើននាក់ កូនម្នាក់ៗត្រូវទទួលបានចំណែកស្មើៗគ្នា។ ប៉ុន្តែបើបងប្អូនបង្កើតដែលមានឪពុក ឬម្តាយតែម្ខាងរួមគ្នា (ដូចជាឪពុករួមជាមួយមតកជន តែមានម្តាយផ្សេងគ្នាជាដើម) ត្រូវទទួលបានចំណែក ១ភាគ២ នៃចំណែករបស់បងប្អូនបង្កើតដែលមានទាំងឪពុក និងម្តាយរួមគ្នា។




តាមគំនូសតាងខាងលើយើងអាចឃើញបានថា បងប្អូន គ និង ឃ ជាបងប្អូនបង្កើតជាមួយមតកជន នោះពួកគាត់ត្រូវទទួលបានចំណែកមតិក ១/២ (មួយភាគពីរ)ស្មើៗគ្នា។ ចំណែកឯ ច វិញ ដែលមានម្តាយខុសគ្នាពីមតកជន តែមានឪពុករួមគ្នា នោះគាត់អាចទទួលបានតែ ពាក់កណ្តាលនៃ គ និង ឃ ប៉ុណ្ណោះ។ ពោល គ និង ឃ ទទួលបាន ២/៥ (ពីរភាគប្រាំ) នៃចំណែកមតិក ឯ ច ទទួលបាន ១/៥ (មួយភាគប្រាំ)។

នៅពេលដែលសន្តតិជនដែលជាបងប្អូនបង្កើតរបស់មតកជនទទួលមរណភាព ឬផ្តាច់សិទ្ធជាសន្តតិជនដោយមូលហេតុណាមួយ នោះសន្តតិកម្មជំនួសនឹងត្រូវយកមកអនុវត្ត ដោយកូនរបស់សន្តតិជន (ជាក្មួយប្រុសឬក្មួយស្រីរបស់មតកជន)នឹងក្លាយជាសន្តតិជនជំនួស។ ករណីនេះ មតកជនមានបងប្អូនបង្កើតចំនួន២នាក់គឺ គ និង ឃ រួមទាំងបងប្អូនរួមឪពុកម្នាក់គឺ ច។ គ មានកូនចំនួន

២នាក់គឺ គ១ និង គ២ ឯអភ័ព្វបុគ្គល ច មានកូនចំនួន៣នាក់គឺ ច១ ច២ និងច៣។ យើងអាចគណនាបានថា៖

- ឃ ទទួលបាន ២/៥ (ពីរភាគប្រាំ)
- គ១ និងគ២ ត្រូវទទួលបានពាក់កណ្តាលស្មើគ្នានៃចំណែករបស់គ គឺ ២/១០(ពីរភាគដប់)
- ឯ ច១ ច២ និងច៣ ជាសន្តតិជនជំនួសរបស់ ច ត្រូវបានចំណែកស្មើគ្នាពីចំណែករបស់ ច គឺយក១/៥(មួយភាគប្រាំ) ចែកឱ្យ៣ ពោលគឺទទួលបាន១/១៥(មួយភាគដប់ប្រាំ)។ គ្មានធ្វើជំនួសឡើងដោយកូនរបស់ក្មួយស្រី ឬក្មួយប្រុសរបស់សន្តតិជនឡើយ។




### ២.២.២ ករណីមានសន្តតិជនជានិច្ច

ក្រមរដ្ឋប្បវេណីនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ២០០៧ ទទួលស្គាល់នូវសិទ្ធិសន្តតិកម្មរបស់សហព័ទ្ធ ដោយត្រូវចូលរួមមកបែងចែកមតិករបស់មតកជន ទោះជាក្នុងករណីមានឬក៏គ្មានសន្តតិជនទាំង៣លំដាប់ថ្នាក់ក៏ដោយ។

#### ២.២.២.១ មានតែសន្តតិជនជានិច្ច

យើងបានបកស្រាយខាងលើរួចមកហើយ ប្រសិនបើក្នុងករណីណាមួយដែលមតកជនគ្មាននូវសន្តតិជនផ្សេងទៀត នោះសហព័ទ្ធនឹងត្រូវទទួលបានចំណែកមតិកទាំងអស់តែម្នាក់ឯងគត់ លើកលែងក្នុងករណី ដែលសហព័ទ្ធធ្លាក់ទៅជាអភ័ព្វបុគ្គលឬបុគ្គល ដែលបានផ្តាច់ពីសន្តតិកម្ម[41]។ ខុសពីករណីខាងលើប្រសិនបើមាននូវសន្តតិជនដទៃតាមលំដាប់ណាមួយផងដែរ នោះយើងនឹងបែងចែកមតិកតាមករណីខាងក្រោម៖

#### ២.២.២.២ បច្ឆាញាតិ

ចំនុច ក នៃមាត្រា១១៦២នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីសន្តតិជនមានភាពស្មើគ្នា ក្នុងការទទួលបាននូវចំណែកមតិក ក្នុងករណីសហព័ទ្ធ និង

[41] ទំព័រទី២១ សេចក្តីកំនត់ក្រមរដ្ឋប្បវេណី ភាគ៦ : គន្លឹះទី៨ និង៩ ក្រសួងយុត្តិធម៌

កូនរបស់មតកជនជាសន្តតិជន។ ការកំណត់ដូច្នេះដោយសារតែការពិចារណាទៅដល់ ការចំណាយសម្រាប់ការរស់នៅ ជាអាទិ៍ក្រោយពេលដែលមតកជនទទួលមរណភាព [42]។ ជាគោលការណ៍ទ្រព្យសម្បត្តិប្ដីប្រពន្ធ រកបានក្នុងរយៈពេលនៃអាពាហ៍ពិពាហ៍ចាត់ទុកជាទ្រព្យរួម ហេតុនេះនៅពេលសហព័ទ្ធណាមួយទទួលមរណភាព សហព័ទ្ធម្ខាងទៀតត្រូវទទួលបាននូវទ្រព្យសម្បត្តិពាក់កណ្ដាលនៃទ្រព្យរួម ។

ឧទាហរណ៍៖ មកតជន ក មានសហព័ទ្ធម្នាក់ឈ្មោះ ខ ព្រមទាំងកូនបង្កើតចំនួន២នាក់ គឺ គ និង ឃ និងកូនសុំចំនួនម្នាក់គឺ ង ។ ក្នុងករណីនេះសហព័ទ្ធ និងកូនទាំងអស់ត្រូវទទួលបានចំណែកមតិកស្មើៗគ្នាដោយម្នាក់ទទួលបាន ១/៤(មួយភាគបួន)នៃមតិកទាំងអស់។ ករណីសន្តតិកម្មជំនួសក៏ត្រូវបានយកមកអនុវត្តផងដែរ ប្រសិនបើសន្តតិជនទទួលមរណភាពជាដើម ដោយចំណែកមតិករបស់សន្តតិជនត្រូវបែងបែកឱ្យកូនស្មើៗគ្នា។ ប្រសិន គ ទទួលមរណភាពដោយមានកូនចំនួន២នាក់ គឺគ១ និងគ២។ ឯ ង ជាអភព័ទ្ធបុគ្គលមានកូនចំនួន៣ នាក់គឺ ង១ ង២ និង ង៣។




នោះយើងអាចបែងចែកមតិកដូចខាងក្រោម៖

- សហព័ទ្ធ ខ ត្រូវទទួលបាន ១/៤(មួយភាគបួន)
- ឃ ត្រូវទទួលបាន ១/៤(មួយភាគបួន)
- ចំណែក ១/៤ របស់ គ ត្រូវចែកជា ២ គឺ ១/៨ ស្មើៗគ្នាដែលជាចំណែករបស់ គ១ និងគ២
- ចំណែក ១/៤ របស់ ង ត្រូវចែកជា ៣ គឺ ១/១២ ស្មើៗគ្នាដែលជាចំណែករបស់ ង១ ង២ និង ង៣។

### ២.២.២.៣ បុព្វញាតិ

ប្រសិនបើសហព័ទ្ធ និងបុព្វញាតិរបស់មតកជនជាសន្តតិជននោះ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា កំណត់ថាសហព័ទ្ធទទួលបាន ១/៣ (មួយភាគបី) ឯចំណែកឪពុកម្ដាយ

[42] ទំព័រទី២២ សេចក្ដីកំនត់ក្រមរដ្ឋប្បវេណី ភាគ៦ : គន្លឹទី៨ និង៩ ក្រសួងយុត្តិធម៌

វិញទទួលបាន២/៣(ពីរភាគបី)[43] ។ ប៉ុន្តែបើមកតជនមានតែឪពុក ឬម្តាយតែម្ខាងនៅរស់វិញនោះ សហព័ទ្ធ និងឪពុកឬម្តាយដែលនៅរស់នោះត្រូវទទួលបានចំណែកស្មើគ្នាគឺ ១/២ (មួយភាគពីរ)[44]។ វាជាករណីដែលកម្រមួយ ដែលមតកជនមានឪពុកម្តាយច្រើនរូប(តាមរយៈសុំកូនធម្មតា) ចំណែករបស់សហព័ទ្ធគឺនៅតែ ១/៣(មួយភាគបី)ដដែល តែចំណែករបស់ឪពុកម្តាយវិញនោះគឺ២/៣(ពីរភាគបី)ដោយតម្រូវឱ្យចែកគ្នាស្មើៗគ្នា។

ឧទាហរណ៍៖ មតកជន ក មានសន្តតិជនជា សហព័ទ្ធ ខ ព្រមទាំងឪពុក គ ម្តាយ ឃ និងឪពុកចិញ្ចឹម ង និងម្តាយចិញ្ចឹម ច។ នោះ ខ ត្រូវទទួលបានចំណែក ១/៣ នៃមតិកសរុប។ ឯចំណែកដែលនៅសល់ គឺ ២/៣ ត្រូវយកមកបែងចែកស្មើគ្នារវាង គ ឃ ង និង ច គឺ ២/១២ (ពីរភាគដប់ពីរ)។




ក្នុងករណីដែលមតកជនគ្មានឪពុកម្តាយជាសន្តតិជននោះ ជីដូនជីតាត្រូវទទួលចំណែកបន្តដោយ សហព័ទ្ធរបស់មតកជនត្រូវទទួលបានចំណែកមតិកពាក់កណ្តាលនៃមតិកសរុបទាំងមូល ដោយចំណែកសេសសល់ត្រូវបែងចែកឱ្យស្មើគ្នារវាងជីដូនជីតា។ ឧទាហរណ៍ខាងក្រោម យើងអាចឃើញថា ខ ត្រូវទទួលបានចំណែក ១/២(មួយភាគពីរ)នៃចំណែកសរុប។ ឯចំណែកសល់ ១/២ ទៀតត្រូវបែងចែកជា៤ គឺ១/៨(មួយភាគប្រាំបី)ស្មើៗគ្នាឱ្យ គ១ គ២ ឃ១ និងឃ២។




[43] មាត្រា១១៦២ ចំនុច២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[44] មាត្រា១១៦២ ចំនុចគ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

#### ២.២.២.៤ សាខាញាតិ

ក្នុងករណីដែលសន្តតិជនជាសហព័ទ្ធ និងបងប្អូនបង្កើត ឬសន្តតិជនជំនួស(ក្មួយប្រុស ឬក្មួយស្រី)នោះចំណែកមតិករបស់សហព័ទ្ធគឺ ១/២(មួយភាគពីរ) ចំណែកឯមតិករបស់សហសន្តតិជនខាងលើគឺ ១/២(មួយភាគពីរ) ត្រូវយកមកចែកឱ្យសហសន្តតិជនថ្នាក់ទី៣ទាំងនោះស្មើៗគ្នា[45]។ ក្នុងករណីនេះសន្តតិកម្មជំនួសក៏ត្រូវបានយកមកអនុវត្តផងដែរ តែអនុវត្តបានតែមួយថ្នាក់តែប៉ុណ្ណោះ។ ឧទាហរណ៍៖ ករណីសន្តតិជនលំដាប់ទី៣ ជាអ្នកទទួលមតិកជាមួយនឹងសហព័ទ្ធ។ មតកជន ក មានសន្តតិជន ជាសហព័ទ្ធ ខ និងបងប្អូនបង្កើត ង និងបងប្អូនរួមឪពុកចំនួន២នាក់គឺ ឆ និង ជ។




សន្តតិកម្មត្រូវបានបែងចែកជាចំណែកដូចខាងក្រោម៖

- ខ ត្រូវទទួលបានចំណែក ១/២ (មួយភាគពីរ)
- ចំណែកដែលនៅសល់ ពាក់កណ្តាលទៀត ត្រូវយកមកឱ្យ ង ឆ និង ជ ។ ប៉ុន្តែ ឆ និង ជ ត្រូវទទួលបានតែពាក់កណ្តាលនៃ ង ប៉ុណ្ណោះដោយហេតុថាជាបងប្អូនរួមតែឪពុក។ នោះ ង ត្រូវទទួលបាន ១/៤(មួយភាគបួន) ឯចំណែករបស់ ឆ និង ជ ត្រូវបាន ១/៨(មួយភាគប្រាំបី) ស្មើៗគ្នា។

ប្រសិនបើសន្តតិជនណាមួយទទួលមរណភាព ឬបាត់បង់សន្តតិកម្មដោយប្រការណាមួយនោះ កូនរបស់សន្តតិជននឹងត្រូវទទួលចំណែករបស់សន្តតិជននោះ។ ឧទាហរណ៍ថា ង ទទួលមរណភាព ដោយមានកូនបីនាក់ទទួលសន្តតិកម្មជំនួស នោះចំណែករបស់ ង ១/៤ នោះត្រូវបែងចែកជាបីស្មើៗគ្នាដល់កូនទាំងបីគឺ ១/១២(មួយភាគដប់ពីរ)។

### ២.៣ អំពីការសម្រួលចំណែករបស់សន្តតិជនតាមច្បាប់

ក្នុងចំណុច ២.៣ នៃជំពូកទី២នេះ នឹងធ្វើការសិក្សាទៅលើចំណុច ២.៣.១ ការទទួលផលប្រយោជន៍ពិសេស និងចំណុច ២.៣.២ស្តីពី ករណីប្រទានកម្ម រួមទាំងករណីដែលមានវិភាគទាននៅក្នុងចំណុច ២.៣.៣ផងដែរ។

[45] មាត្រា១១៦២ ចំនុច គ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ការសម្រួលចំណែកសន្តតិកម្ម គឺធ្វើឡើងដើម្បី ឱ្យមានសមភាពត្រឹមត្រូវជាក់ស្តែងនៃចំណែករបស់សហសន្តតិជន ដើម្បីឱ្យសមស្របទៅនឹងករណី មានអ្នកទទួលបានផលប្រយោជន៍ពិសេសផ្សេងៗដោយតម្រូវឱ្យសងមកវិញនូវ ចំណែកទាំងនោះ។

### ២.៣.១ អ្នកទទួលផលប្រយោជន៍ពិសេស

#### ២.៣.១.១ អ្នកទទួលផលប្រយោជន៍ពិសេស

យើងគួរយល់ន័យរបស់ "បុគ្គលដែលមានផលប្រយោជន៍ពិសេស" ដែលច្បាប់បានកំណត់ថាជាសន្តតិជនដែលបានទទួលប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ ឬដែលបានទទួលអច្ច័យទានពីមតកជននោះ[46]។ ឧទាហរណ៍ថា នៅពេល ដែលមតកជននៅរស់បានប្រគល់នូវប្រទានកម្មចំនួន៥០០ដុល្លារ ដល់សន្តតិជន ក ដែលនេះថាជាបុគ្គលដែលទទួលផលប្រយោជន៍ពិសេស។

ក្នុងចំណោមសហសន្តតិជនណាមួយ ដែលជាបុគ្គលទទួលបានផលប្រយោជន៍ពិសេសនេះ នៅពេលបើកសន្តតិកម្ម តម្លៃសរុបនៃមតិកដែលមតកជនមាន ត្រូវបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ហើយចំនួនទឹកប្រាក់ដែលសេសសល់ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬអច្ច័យទាននោះចេញ គឺជាចំណែកមតិករបស់បុគ្គលនោះ។ ឧទាហរណ៍៖ មតកជន បានបន្សល់ទុកមតិកចំនួន ៣០០០ដុល្លារហើយត្រូវចែកឱ្យសន្តតិជនចំនួន៣នាក់គឺ ក ខ និង គ ប៉ុន្តែ ក បានទទួលប្រទានកម្មចំនួន ៦០០ ដុល្លារពីមតកជនពីពេលនៅរស់។ នោះមតិកសរុបគឺចំនួនមតិក ដែលមតកជនមានពេលចាប់ផ្តើមសន្តតិកម្មចំនួន ៣០០០ដុល្លារ និងតម្លៃប្រទានកម្មចំនួន ៦០០ដុល្លារ ដែលឱ្យដល់ ក នោះមតិកសរុបគឺ ៣៦០០ដុល្លារ។ ចំណែកស្មើៗគ្នារបស់ ក ខ និង គ គឺ ៣៦០០ដុល្លារ ចែកឱ្យបីគឺ ១២០០ ដុល្លារ តែ ក ទទួលបានប្រទានកម្មចំនួន៦០០ដុល្លាររួចហើយ ដូច្នេះ ក អាចទទួលបានតែ ៦០០ ដុល្លារថែមទៀតប៉ុណ្ណោះហើយចំណែកមតិកដែលមានពេលចាប់ផ្តើមសន្តតិកម្មចំនួន៣៦០០ដុល្លារ ត្រូវបែងចែកទៅឱ្យ ខ និង គ ចំនួន១២០០ដុល្លារម្នាក់ៗ ឯ ក វិញទទួលបានតែ៦០០ដុល្លារ។

#### ២.៣.១.២ ករណីដែលទទួលផលប្រយោជន៍ពិសេសនោះលើសពីតម្លៃនៃចំណែកមត៌ក

បើតម្លៃនៃប្រទានកម្ម ឬអច្ច័យទាន ស្មើនឹងតម្លៃនៃចំណែកមតិក ឬ លើសនឹងចំណែកមតិក សហសន្តតិជននោះមិនអាចទទួលបានចំណែកមតិកនោះបានឡើយ[47]។

ឧទាហរណ៍៖ ករណីខាងលើដដែល ប្រសិនបើ ក ទទួលបានប្រទានកម្ម ១៥០០ដុល្លារ លើសចំណែកមតិក នោះ ក មិនអាចទទួលបានចំណែកមតិកទៀតទេ ដោយសារតែតម្លៃនៃប្រទានកម្មចំនួន១៥០០ដុល្លារ លើសនឹងចំណែកមតិករួចទៅហើយ (ទ្រព្យដែលចាត់ទុកជាមតិកគឺ៤៥០០

---

[46] មាត្រា១១៦៣ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[47] មាត្រា១១៦៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ដុល្លារ ពេលដែលតម្លៃនៃប្រទានកម្មស្មើនឹង១៥០០ដុល្លារ នោះចំណែកមតិក១៥០០ដុល្លារ ស្មើនឹងតម្លៃប្រទានកម្មមុនពេលទទួលមរណភាព) នោះ ក មិនអាចទទួលបានចំណែកមតិកទៀតទេ។

ទោះបីជាតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមតិកក៏ដោយ សហសន្តតិជននោះ ពុំចាំបាច់បង្វិលមកវិញ នូវទ្រព្យសម្បត្តិដែលទាក់ទងប្រទានកម្ម ដើម្បីសងសហសន្តតិជនផ្សេងទៀតឡើយលើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង[48]។ ផ្ទុយពីការចែងខាងលើ ក្រមរដ្ឋប្បវេណីចាស់បានយកនូវគោលការណ៍ខុសពីខាងលើដោយចែងថា ប្រសិនបើចំណែកមតិកតិចជាងតម្លៃទ្រព្យដែលត្រូវបង្វិលទៅវិញ ត្រូវសងវិញនូវចំនួនដែលខ្វះ[49]។ គេផ្តល់អាទិភាពដល់ឆន្ទៈរបស់មតកជនកាលពេលនៅរស់ ឬឆន្ទៈរបស់សហសន្តតិជន ក្នុងការសងទៅវិញនូវចំណែកលើស ទៅឱ្យរបបកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងដោះស្រាយ។

ក្នុងករណីខាងលើ ដែលមិនចាំបាច់ឱ្យបង្វិលនូវភាគលើសវិញទេ តម្លៃនៃចំណែកមតិកជាក់ស្តែងរបស់សហសន្តតិជនផ្សេងទៀតនៅពេលសន្តតិជនចាប់ផ្តើមសន្តតិកម្ម ត្រូវគណនាដោយបែងចែកមតិក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម នោះតាមសមាមាត្រនៃចំណែកមតិក របស់សន្តតិជនម្នាក់ៗ ដោយយោងតាមកថាខណ្ឌទី២ នៃមាត្រា១១៦៥ នៃក្រមរដ្ឋប្បវេណី។

ឧទាហរណ៍៖ មតកជនម្នាក់មានសន្តតិជនបីនាក់គឺ ក ខ និង គ ត្រូវទទួលសន្តតិកម្មស្មើគ្នានូវមតិកចំនួន១០០០ដុល្លារ ហើយប្រសិនបើនៅពេលដែលមតកជននៅរស់ ក បានទទួល ១០០០ដុល្លារ ហើយ ខ ក៏ទទួលបាន ៤០០ដុល្លារដែរតាមប្រទានកម្ម "ទ្រព្យដែលត្រូវបានចាត់ទុកជាមតិក" មានទាំងអស់ ២៤០០ដុល្លារ ដូច្នេះចំណែកមតិកដែលសន្តតិជនម្នាក់អាចទទួលបានគឺ មួយភាគបីនៃមតិកនោះដែលត្រូវជា ៨០០ដុល្លារ នៃទ្រព្យដែលត្រូវបានចាត់ទុកជាមតិក។ ក៏ប៉ុន្តែ ក បានទទួល ១០០០ដុល្លារ តាមប្រទានកម្មហើយ ដូច្នេះចំណែកមតិករបស់ ក គឺ សូន្យ ចំណែករបស់ ខ គឺ ៤០០ដុល្លារ(៨០០-៤០០) ហើយចំណែករបស់ គ គឺ ៨០០ដុល្លារ។ បូកសរុបទៅគឺ ១២០០ដុល្លារ ហើយចំនួននេះលើសចំនួនមតិក ១០០០ដុល្លារ ដែលមតិកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម។ ហេតុនេះហើយ ខ និងគ ត្រូវទទួលបាននូវចំណែកតាមសមាមាត្រ ៤០០ : ៨០០ នៃចំនួន ១០០០ដុល្លារ(៤០០/១២០០×១០០០= ៣៣៣,៣៣)។ បានសេចក្តីថា ខ បានទទួលចំណែក ៣៣៣ដុល្លារ ហើយ គ បានទទួលបានមតិក ៦៦៧ដុល្លារ។

[48] មាត្រា១១៦៥ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[49] មាត្រា៦០០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦០

ម្យ៉ាងទៀតក្នុងឧទាហរណ៍ខាងលើនេះប្រសិនបើមានតែ ក ទេ ដែលបានទទួល ៣០០០ ដុល្លារដោយប្រទានកម្មពេលមតកជននៅរស់នោះ តែ ខ មិនទទួលបានប្រទានកម្មទេ "ទ្រព្យដែលចាត់ទុកថាជាមតិក" ត្រូវមាន៩០០០ដុល្លារ។ ដូច្នេះ ក ខ និង គ ត្រូវទទួលបាន ១៣៣៣ដុល្លារម្នាក់។ ក្នុងករណីនេះ ភាគបម្រុងគឺ ៦៦៧ដុល្លារ(មាត្រា១២៣៣) ដូច្នេះ ខ និង គ អាចទាមទារឱ្យ ក កាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ១៦៧ដុល្លារ សម្រាប់ម្នាក់ៗបាន។ ក្នុងករណីនេះ ក ត្រូវបង្វិលសងវិញ ក៏ប៉ុន្តែប្រសិនបើ ខ ឬគ មិនបានទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងទេនោះ ក មិនបាច់បង្វិលវិញក៏បានដែរ។

### ២.៣.២ ករណីមានប្រទានកម្ម

ពាក្យ "ប្រទានកម្ម" សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងដែលជាអ្នកទទួល (បដិគ្គាហក) បានទទួលនូវទ្រព្យសម្បត្តិពី អ្នកឱ្យ (ទាយក) ដោយពុំគិតថ្លៃ[50]។ ក្នុងករណីដែល បដិគ្គាហក ឬអ្នកដែលទទួលផលប្រយោជន៍ពិសេស បានចាត់ចែងទ្រព្យសម្បត្តិ ដែលបានទទួលដោយប្រទានកម្មមុនពេលចាប់ផ្តើមសន្តតិកម្ម ឬក្នុងករណីដែលទ្រព្យនោះបានបាត់បង់ វិនាសមុនពេលចាប់ផ្តើមសន្តតិកម្ម ជាអាទិ៍ នោះវិធីក្នុងការគណនាតម្លៃនៃប្រទានកម្ម ត្រូវគណនាទៅតាមតម្លៃនៅពេលចាត់ចែង ឬនៅពេលដែលបានបាត់បង់ ឬវិនាស ទ្រព្យនោះ។ ប្រសិនបើតម្លៃកម្មវត្ថុនៃប្រទានកម្ម ឬតម្លៃវត្ថុមានការផ្លាស់ប្តូរ ដោយសារសកម្មភាពផ្សេងៗរបស់បដិគាហក ឬអ្នកទទួលប្រយោជន៍ពិសេសនោះ តម្លៃកម្មវត្ថុនៃប្រទានកម្ម ឬតម្លៃវត្ថុ ត្រូវគណនាដោយគិតក្នុងពេលចាប់ផ្តើមសន្តតិកម្មនោះ។ ការប្រាក់ និងផលចំណេញ ដែលកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួលពុំត្រូវបានគណនាចូលក្នុងតម្លៃនោះឡើយ[51]។

### ២.៣.៣ករណីមានវិភាគទាន

ការធ្វើឱ្យមានវិភាគទាននេះកើតឡើង គឺដោយសារតែ "មានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវាកម្មលើកិច្ចការរបស់មតកជន ឬដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬដោយការថែទាំព្យាបាលមតកជន ឬដោយវិធីផ្សេងទៀត[52]" ដែលវាជាគោលគំនិតដ៏ល្អ សម្រាប់សន្តតិជនណា ដែលបានបំពេញខ្លួនជាបុត្រល្អ។ ការផ្តល់នូវវិភាគទានពិសេស ដល់មតកជន ដូចជាការព្យាបាល ការថែទាំជាដើម គឺមិនគ្រប់គ្រាន់ទេ ដោយតម្រូវឱ្យមានការថែរក្សា ឬកំណើននៃទ្រព្យរបស់មតកជននោះ ដោយសារវិភាគទាននោះទៀតផងដែរ។ ឧទាហរណ៍ថា ដោយសារតែការជួយមើលថែទាំរបស់សន្តតិជន ទើប

---

[50] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ ១៩

[51] មាត្រា១១៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[52] មាត្រា១១៦៦ កថាខណ្ឌទី១ វាក្យខណ្ឌ១នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ធ្វើឱ្យមានការកាត់បន្ថយចំណាយផ្សេងៗ ក្នុងការជួលអ្នកមើលថែ ដែលនេះចាត់ទុកជាការថែរក្សាទ្រព្យសម្បត្តិរបស់មតកជន។ ក្នុងករណីដែលមានតម្លៃតប ឬតម្លៃថ្នូរមកវិញចំពោះសេវាកម្មទៅលើមតកជន នោះគេមិនចាត់ទុកវាជាវិភាគទានពិសេសទេ។

ក្នុងចំណោមសហសន្តតិជន បើមានបុគ្គលណាម្នាក់ធ្វើវិភាគទានពិសេស តម្លៃមតិកដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយដកនឹងវិភាគទានត្រូវចាត់ទុកជាមតិក ហើយចំនួនទឹកប្រាក់នៃចំណែកមតិក ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី១ (សន្តតិជន) និងផ្នែកទី២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងវិភាគទាន ត្រូវជាចំណែកមតិករបស់របស់ជន ដែលបានធ្វើវិភាគទានពិសេសនោះ[53]។ ឧទាហរណ៍ ក ខ និង គ ជាសហសន្តតិជន ដែលត្រូវទទួលមតិកចំនួន២០០០ដុល្លារដោយត្រូវទទួលបានចំណែកស្មើៗគ្នា។ ប៉ុន្តែ ក បានធ្វើវិភាគទានពិសេសលើកិច្ចការរបស់មតកជនអស់ចំនួន៥០០ដុល្លារ។ នោះទ្រព្យដែលចាត់ទុកជាមតិក ហើយតម្រូវឱ្យបែងចែកស្មើគ្នាគឺ១៥០០ដុល្លារ(២០០០-៥០០)។ ដូច្នេះចំណែកមតិករបស់ត្រូវបូកបន្ថែមនឹងតម្លៃវិភាគទានពិសេស៥០០ដុល្លារទៀត។ នោះ ក ទទួលបានមតិកចំនួន ១០០០ដុល្លារ ឯ ខ និង គ វិញទទួលបាន ៥០០ដុល្លារម្នាក់។

ការកំណត់តម្លៃនៃវិភាគទានត្រូវធ្វើឡើងដោយការពិភាក្សាគ្នាដោយសហសន្តតិជន ប៉ុន្តែបើមិនអាចពិភាក្សាបានទេនោះ តុលាការត្រូវជាអ្នកកំណត់តាមពាក្យស្នើសុំរបស់បុគ្គលដែលបានធ្វើវិភាគទាន។ ការពិចារណានេះត្រូវធ្វើឡើងដោយពិចារណាទៅលើ ពេល វិធី និងកម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមតិក និងស្ថានភាពផ្សេងៗទាំងអស់។ ជាទូទៅនៅពេលស្នើសុំឱ្យតុលាការធ្វើការបែងចែកមតិកនេះ គេច្រើនសុំឱ្យតុលាការកំណត់នូវវិភាគទានព្រមគ្នាតែម្តង។

## ២.៤ អំពីភាគបម្រុង

នៅក្នុងចំណុច២.៤នេះ យើងនឹងបកស្រាយអំពី សញ្ញាណទូទៅនៃភាគបម្រុង ស្ថិតនៅក្នុងចំណុច២.៤.១ រីឯចំណុច ២.៤.២នឹងបរិយាយពី វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ហើយចំពោះចំណុច ២.៤.៣វិញស្តីពី ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយចំណែកដើម្បីបង្គ្រប់ភាគបម្រុង។

### ២.៤.១ សញ្ញាណទូទៅនៃភាគបម្រុង

របបនៃភាគបម្រុងនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ គឺជាការធានានៃចំណែកមតិកដែលកំណត់ដោយច្បាប់ចំពោះជនទាំងឡាយណាដែលជាសន្តតិជន ដោយមូលហេតុថា ទោះបីជាមតកជនមានសិទ្ធិសេរីភាពក្នុងការធ្វើមតកសាសន៍ ក៏មិនអាចធ្វើអ្វីបំពានទៅលើសន្តតិជនបានដែរ ដោយច្បាប់បានទទួលស្គាល់ឱ្យសន្តតិជនធ្វើការបដិសេធនូវសេរីភាពក្នុងការ

[53] មាត្រា១១៦៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ធ្វើមតកសាន៍នេះ ពេលដែលសន្តតិជននោះទទួលរងការរំលោភបំពានសិទ្ធិលើភាគបម្រុងរបស់ខ្លួន។ របបនៃភាគបម្រុងមានតួនាទីក្នុងការសម្របសម្រួលសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ និងជាការធានាកុំឱ្យមាននូវការបំពានទៅលើ សិទ្ធិលើចំណែកមត៌ក។ មូលហេតុផ្សេងៗដែលអាចធ្វើឱ្យក្លាយជាការបំពានលើភាគបម្រុងនោះគឺ ករណីមានអច្ច័យទាន ឬ ប្រទានកម្មកំណត់មួយចំនួនពេលមតកជននៅរស់ ឬ ការទទួលបានផលប្រយោជន៍ពិសេស ឬការកំណត់ចំណែកមត៌កតាមមតកសាសន៍។

### ២.៤.១.១ ជនដែលមានសិទ្ធិលើភាគបម្រុង

ច្បាប់បានកំណត់អំពីអ្នកដែលមានសិទ្ធិលើភាគបម្រុង ដូចជាបច្ឆាញាតិផ្ទាល់ ឬឪពុកម្តាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជនផងដែរ។ សន្តតិជនដែលបានរៀបរាប់ខាងលើរួមទាំងសន្តតិជនជំនួសរបស់បច្ឆាញាតិផ្ទាល់ ក៏ជាបុគ្គលដែលមានសិទ្ធិលើភាគបម្រុងនេះដែរ[54]។ ជនក្រៅពីបុគ្គលខាងលើរួមមានសន្តតិជន ជាបងប្អូនបង្កើត និងសន្តតិជនជំនួសរបស់បងប្អូនបង្កើត(ក្មួយរបស់មតកជន) មិនមានសិទ្ធិលើភាគបម្រុងទេ។

### ២.៤.១.២ ការកំណត់អំពីចំណែកនៃភាគបម្រុង

ចំពោះចំណែកនៃភាគបម្រុងវិញ ដោយយោងតាមមាត្រា១២៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាគឺត្រូវបានបែងចែកដូចខាងក្រោម៖

- ១ ភាគ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជនក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្តាយ ឬជីដូនជីតាតែប៉ុណ្ណោះ។
- ១ ភាគ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេងៗ ដូចជាករណីមានតែបច្ឆាញាតិផ្ទាល់ និងសហព័ទ្ធ ជាសន្តតិជនជាដើម។ ឧទាហរណ៍ក្នុងករណី មានកូនតែម្នាក់ និងសហព័ទ្ធជាសន្តតិជន នោះភាគបម្រុងសម្រាប់អ្នកទាំងនោះគឺ ១ភាគ ២នៃមត៌ករបស់មតកជន។

ក្នុងករណីពិសេស ដែលអ្នកមានសិទ្ធិលើភាគបម្រុងច្រើននាក់ ត្រូវធ្វើការបែងចែកមត៌កដែលចាត់ទុកជាភាគបម្រុងនោះទៅតាមសមាមាត្រនៃចំណែកភាគបម្រុង។

## ២.៤.២ វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកដែលមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តសិទ្ធិនោះ(ប្រតិសិទ្ធិ) អាចទាមទារឱ្យកាត់បន្ថយអច្ច័យទាន ឬផលប្រយោជន៍ពិសេស ឬប្រទានកម្ម ឬចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីមកបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិត

[54] មាត្រា១២៣០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ[55]។ អ្នកមានសិទ្ធិលើភាគបម្រុង និងប្រតិសិទ្ធិរបស់ខ្លួន មានសេរីភាពក្នុងការទាមទារឬមិនទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ហើយក្នុងករណីដែលមិនមានការទាមទារគឺធ្វើឱ្យមតកសាសន៍ដែលកំណត់ដោយមតកជនមានសុពលភាព។ ការអនុវត្តសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង បានធ្វើឱ្យអ្នកដែលទទួលបានអច្ច័យទាន និងប្រទានកម្ម ជាអាទិ៍បាត់បង់អានុភាពដោយស្វ័យប្រវត្តិ ក្នុងកម្រិតនៃការបំពានភាគបម្រុង។ ក្នុងករណីដែលកម្មសិទ្ធិលើអចលនវត្ថុ បានក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង បណ្តាលឱ្យផ្នែកដែលស្មើនឹងភាគបម្រុង ត្រូវធ្លាក់ទៅលើជនដែលមានសិទ្ធិលើភាគបម្រុងដោយមិនចុះបញ្ជី។ ឯករណីមានការទាមទារគឺមិនចាំបាច់ធ្វើឡើងដោយមានបណ្តឹងនោះទេ ពោលគឺគ្រាន់តែបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ហើយ ប៉ុន្តែករណីដែលភាគីម្ខាងមិនយល់ព្រមនោះ មានតែការដាក់ពាក្យបណ្តឹង។

### ២.៤.២.១ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

ភាគបម្រុងត្រូវបានគណនាដោយយកទ្រព្យសម្បត្តិ ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា១១៦៣(ចំណែកមតិករបស់អ្នកទទួលផលប្រយោជន៍ពិសេស) និងតម្លៃនៃទ្រព្យសម្បត្តិប្រទានកម្មដែលបានកំណត់ក្នុងមាត្រា១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) នៃក្រមនេះហើយដកនូវប្រាក់សរុបនៃកាតព្វកិច្ចចេញ[56]។

ឧទាហរណ៍៖ ក្នុងករណី សហព័ទ្ធ ក របស់មតកជនទទួលបានចំណែកមតិកស្មើជាមួយនឹងកូន ខ និង គ ។ នៅពេលចាប់ផ្តើមសន្តតិកម្ម មតិករបស់មតកជនមានចំនួន ១០០០ដុល្លារ ក្នុងនោះ ខ ទទួលបានផលប្រយោជន៍ពិសេស ៥០០ដុល្លារ ហើយកាតព្វកិច្ចដែលត្រូវធ្វើសន្តតិកម្មមានចំនួន ៣០០ដុល្លារ ក្រៅពីនេះមាននារីកំណាន់ម្នាក់បានទទួលនូវប្រទានកម្ម ចំនួន១០០០ដុល្លាមុនមតកជនស្លាប់។ ក្នុងករណីនេះទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងគឺ ១០០០+៥០០+១០០០-៣០០=២២០០ដុល្លារ។ ដោយយោងតាមមាត្រា ១២៣០នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ២២០០៖២៖៣=៣៦៧ដុល្លារ (ចែកនឹង២ដោយសារតែស្ថិតក្នុងលក្ខខណ្ឌកូននិងសហព័ទ្ធជាសន្តតិជន ហើយចែកនឹង៣ ដោយសារមានសហសន្តតិជនចំនួន៣នាក់) គឺជាទ្រព្យសុទ្ធដែលជាភាគបម្រុងរបស់សន្តតិជនម្នាក់ៗ។

### ក. ប្រទានកម្មដែលជាមូលដ្ឋាននៃការគណនាភាគបម្រុង

យោងតាមមាត្រា១២៣២នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ប្រទានកម្មខាងក្រោមនេះ នឹងក្លាយជាមូលដ្ឋានក្នុងការគណនាភាគបម្រុង លើកលែងតែផលប្រយោជន៍

[55] មាត្រា១២៣៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[56] មាត្រា១២៣១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ពិសេសខាងក្រោមៈ

- ប្រទានកម្ម ដែលធ្វើឡើងក្នុងអំឡុងពេល ០១ (មួយ)ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម។ ការកំណត់នេះគឺដោយសារ ដើម្បីកុំឱ្យមានការបំពានមិនត្រឹមត្រូវដល់ផលប្រយោជន៍របស់អច្ច័យលាភី និងដើម្បីឱ្យមានសុវត្ថិភាពក្នុងកិច្ចការជំនួញ។
- ប្រទានកម្មដែលបានធ្វើឡើងដោយភាគីទាំងសងខាង ដោយបានដឹងថានឹងប៉ះពាល់ដល់ផលប្រយោជន៍ របស់អ្នកមានសិទ្ធិលើភាគបម្រុង។ អំពើនៃការបំពាននេះមិនត្រូវបានកំណត់អំឡុងពេលនោះទេ ហើយចំពោះវិធីនៃការដឹងថាតើមានការបំពាន ឬមិនបំពាននោះ ត្រូវប្រៀបធៀបទ្រព្យសម្បត្តិសរុបរបស់មតកជនពេលធ្វើប្រទានកម្ម និងតម្លៃទ្រព្យសម្បត្តិដែលធ្វើប្រទានកម្ម។

ឧទាហរណ៍ទី១: ក្នុងករណីដែលមតកជនបានធ្វើប្រទានកម្ម ៥០០០ដុល្លារ ដល់តតិយជនមួយដែលបានធ្វើវិភាគទានដល់កិច្ចការជំនួញរបស់ខ្លួន ហើយបានបន្សល់ទុកនូវទ្រព្យ ៥០០០០ ដុល្លារ។ ក្នុងករណីនេះទោះបីជាទ្រព្យសម្បត្តិធ្លាក់ចុះដល់២០០០០ដុល្លារក៏មិនមែនជាការបំពានដែរ។

ឧទាហរណ៍ទី២: ក្នុងករណីដែលមតកជនបានធ្វើប្រទានកម្ម ដល់ស្រីកំណាន់របស់ខ្លួននូវទ្រព្យសម្បត្តិរបស់ខ្លួនទាំងអស់ ក្នុងគោលបំណងមិនចែកមត៌កដល់កូនរបស់របស់ខ្លួន ព្រោះកូននោះជាកូនសុំ។ ករណីនេះជាករណីដែលបំពានភាគបម្រុងព្រោះមតកជន និងស្រីកំណាន់របស់ខ្លួនបានដឹងថាវានឹងបំពានភាគបម្រុងរបស់កូនសុំ។ ដូច្នេះកូនសុំមានសិទ្ធិក្នុងការទាមទារភាគបម្រុងរបស់ខ្លួន។

ចំពោះកាតព្វកិច្ចដោយមិនយកតម្លៃវិញ ត្រូវចាត់ទុកជាប្រទានកម្ម[57] ។ ឧទាហរណ៍ក្នុងករណីដែលមតកជនបានឱ្យសន្តតិជនខ្ចីប្រាក់ ១៦០០ដុល្លារ ហើយក្រោយមកមិនចាំបាច់សងវិញនោះ។ ដូចនេះវាជាការបំពានភាគបម្រុង ដែលនាំឱ្យប្រទានកម្មនេះក្លាយជាកម្មវត្ថុនៃភាគបម្រុង។

**ខ. ទ្រព្យដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្រ្គប់ភាគបម្រុង**

កម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងគឺ អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និងប្រទានកម្ម ដែលបានកំណត់ក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង)[58]។ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដែលជាអច្ច័យទានរបស់សន្តតិជន ការកំណត់ចំណែកមត៌ក និងការទទួលផលប្រយោជន៍ពិសេសនោះ ប្រសិនបើសន្តតិជន ដែលត្រូវបានគេកាត់បន្ថយនោះ

[57] មាត្រា១២៣២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[58] មាត្រា១២៣៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ត្រូវបានបំពានភាគបម្រុងនោះទៅវិញដោយសារតែការកាត់បន្ថយនោះ សន្តតិជនដែលត្រូវទទួលការបំពានភាគបម្រុងរបស់ខ្លួននោះអាចបដិសេធការទាមទារនេះបាន។

**គ. ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង**

ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនាដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និងចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម[59]។

**២.៤.២.២ លំដាប់នៃការកាត់បន្ថយ**

ក្នុងករណីដែលមានការបំពានភាគបម្រុង ទ្រព្យដែលជាកម្មវត្ថុ ដែលត្រូវបានកាត់បន្ថយក្នុងលំដាប់ទី១គឺ អច្ច័យទាន ទី២ ចំណែកមតិកដែលបានកំណត់តាមមតកសាសន៍ ទី៣ ប្រទានកម្ម និងទី៤ ការទទួលផលប្រយោជន៍ពិសេស[60]។ ការកំណត់ដូចនេះគឺដោយសារតែគោលគំនិតនៃរបបភាគបម្រុង គឺធានាទុកនូវមតិកមួយភាគសម្រាប់ឱ្យជនដែលមានសិទ្ធិលើភាគបម្រុង ប៉ុន្តែប្រសិនបើកម្រិតនូវកម្មវត្ថុនៃការកាត់បន្ថយត្រឹមតែមតិកអាចទៅជាបំពានភាគបម្រុងវិញ ដោយសារការធ្វើប្រទានកម្មរបស់មតកជនពេលនៅរស់។ ហេតុនេះធ្វើឱ្យប្រទានកម្មក៏ក្លាយជាកម្មវត្ថុនៃការកាត់បន្ថយផងដែរ។ ការយកប្រទានកម្ម និងផលប្រយោជន៍ពិសេស ធ្វើជាកម្មវត្ថុនៃការកាត់បន្ថយគឺដើម្បីឱ្យមានសមភាពគ្នារវាងសហសន្តតិជន។ ផ្ទុយទៅវិញ បើនៅពេលចាប់ផ្តើមសន្តតិកម្ម មតិកមានគ្រប់គ្រាន់សម្រាប់បង្គ្រប់ភាគបម្រុងនោះមិនចាំបាច់ពិចារណាក្នុងការចាត់ចែងសកម្មភាពរបស់មតកជនដូចជា ប្រទានកម្ម មកបង្គ្រប់ភាគបម្រុងនោះទេ។

**ក. លំដាប់នៃការកាត់បន្ថយប្រទានកម្មជាអាទិ៍**

ក្នុងករណីដែលមតកជនបានធ្វើប្រទានកម្មនូវទ្រព្យជាច្រើន ទៅឱ្យជនដែលត្រូវបានសន្មតជាសន្តតិជនជាអាទិ៍ នាពេលនៅរស់ ការកាត់បន្ថយប្រទានកម្ម ឬផលប្រយោជន៍ពិសេស ត្រូវធ្វើឡើងចំពោះប្រទានកម្ម ឬផលប្រយោជន៍ដែលបានធ្វើក្រោយគេ ហើយបន្ទាប់មកត្រូវធ្វើចំពោះប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនជាបន្តបន្ទាប់[61]។ ប៉ុន្តែប្រសិនបើជន ដែលត្រូវបានធ្វើការកាត់បន្ថយដែលជាសន្តតិជន ហើយត្រូវបានបំពានដោយសារការកាត

[59] មាត្រា១២៣៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[60] មាត្រា ១២៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជណាចក្រកម្ពុជា

[61] មាត្រា១២៣៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

បន្ថយនេះ ការកាត់បន្ថយត្រូវធ្វើឡើងត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះតែប៉ុណ្ណោះ[62]។

ឧទាហរណ៍: មតកជនមានសន្តតិជនជា សហព័ទ្ធ ក និងកូន ខ និង គ ។ មុនពេលទទួលមរណភាព ៣ឆ្នាំ មតកជនបានធ្វើប្រទានកម្មឱ្យ ខ ចំនួន ២២០០ដុល្លារសម្រាប់រកស៊ី និងកន្លះឆ្នាំមុនទទួលមរណភាពបានធ្វើប្រទានកម្មឱ្យ ក ចំនួន ៦០០ដុល្លារ។ ហើយមតិកសល់តែ ២០០ដុល្លារតែប៉ុណ្ណោះ។ ទោះបីជា គ ត្រូវទទួលបានមតិកទាំងអស់ក៏ នៅតែត្រូវបានបំពានភាគបម្រុងរបស់ខ្លួន ៣០០ដុល្លារទៀត។ ហេតុនេះ គ នឹងទាមទារពី ក ដែលបានទទួលប្រទានកម្មចំនួន៦០០ដុល្លារដើម្បីបង្គ្រប់ភាគបម្រុង។ តែការកាត់បន្ថយអាចបានតែ ១០០ដុល្លារទេ ដោយដកពីភាគបម្រុងរបស់ ក ដោយហេតុថាបើកាត់លើសពីនេះនឹងបំពានដល់ចំណែករបស់ ក វិញ។ នៅសល់ ២០០ដុល្លារទៀតត្រូវទាមទារពី ខ បាន។

មួយវិញទៀត នៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជន ដែលបានទទួលផលប្រយោជន៍ពិសេស អាចធ្វើការបដិសេធការទាមទារការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាននៅពេលដែលប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសនោះបានធ្វើឡើងលើស ២០(ម្ភៃ)ឆ្នាំ[63]។ករណីនេះជាគោលគំនិតនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ដែលវាជាការបន្ថែមចំនួនឆ្នាំ ដោយគិតថាប្រសិនបើយកអំឡុងពេល១០ឆ្នាំ ដែលជាគោលគំនិតនៃការរលត់សិទ្ធិ មកអនុវត្តគឺខ្លីពេក។

**ខ. ការសងផលមកវិញ និងបន្ទុកនៃការខាតបង់ដោយអសាធនភាព**

អសាធនភាពសំដៅទៅលើភាពដែលខ្វះលទ្ធភាពក្នុងការសងនូវបំណុល។ ក្នុងករណីដែលអ្នកដែលមានសិទ្ធិលើភាគបម្រុងទាមទារឱ្យអ្នក ដែលត្រូវទទួលការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដូចជា សហសន្តតិជន អច្ច័យលាភី ឬបដិគ្គាហក ជាដើម ត្រូវសងមកវិញនូវផលដែលបានកើតឡើងក្រោយពីថ្ងៃដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ [64] មានន័យថាត្រូវសងនូវផលដែលបានកើតឡើង ដោយគិតពីកាលបរិច្ឆេទដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ ដោយរាប់ចូលទាំងប្រាក់សំណងផងដែរ។

ផ្ទុយទៅវិញប្រសិនបើជនដែលទទួលការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង មិនអាចសងនូវនូវតម្លៃនៃទ្រព្យទាំងនោះបានទេ ឬទ្រព្យដែលទទួលបានពីមតកជនវិញបានទេ ដោយសារតែអសាធនភាព ការខាតបង់នេះត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ដោយយោងតាមមាត្រា ១២៤០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧។ ជាគោលការណ៍អ្នក

[62] មាត្រា១២៣៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[63] មាត្រា១២៣៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[64] មាត្រា១២៣៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ដែលមានសិទ្ធិលើភាគបម្រុងជាអ្នកទទួលបន្ទុក ហើយមិនអាចទាមទារឱ្យអ្នកដែលមានកាតព្វកិច្ចក្នុងលំដាប់បន្ទាប់ សងនូវចំណែកដែលខ្លួនមានសិទ្ធិ តែមិនអាចទាមទារមិនបានគ្រប់នោះទេ។

**គ. ការកាត់បន្ថយប្រទានកម្មដែលមានភ្ជាប់បន្ទុក**

ប្រទានកម្មដែលមានភ្ជាប់បន្ទុក ដែលតម្លៃនៃកម្មវត្ថុដកចេញនូវតម្លៃនៃបន្ទុក ជាកម្មវត្ថុនៃការធ្វើការកាត់បន្ថយបានដើម្បីបង្គ្រប់ភាគបម្រុង[65]។

ឧទាហរណ៍ : នៅពេលនៅរស់មតកជន បានធ្វើប្រទានកម្មជាប្រាក់ចំនួន ២០០០ដុល្លារដល់ ក ដើម្បីឱ្យ ក ជួយផ្គត់ផ្គង់ថ្លៃសិក្សាដល់ ខ ចំនួន ១០០ដុល្លារ ក្នុងមួយខែ រយៈពេល១ឆ្នាំ។ ក្នុងករណីនេះប្រសិនប្រទានកម្មដែលមានភ្ជាប់បន្ទុក ក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះ ត្រូវដកនូវបន្ទុកចេញ ដោយ ២០០០-១០០x១២= ៨០០ដុល្លារ មានន័យថា ៨០០នេះជាកម្មវត្ថុនៃការកាត់បន្ថយ។

**ឃ. ការកាត់បន្ថយចំពោះកិច្ចសន្យា ដែលត្រូវបានចាត់ទុកជាប្រទានកម្ម**

កិច្ចសន្យាដែលបានធ្វើឡើងដោយយកតម្លៃមិនត្រឹមត្រូវ ត្រូវចាត់ទុកជាប្រទានកម្ម តែក្នុងករណីដែលបានធ្វើឡើង ដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិទៅលើភាគបម្រុងប៉ុណ្ណោះ[66]។ កិច្ចសន្យាប្រភេទនេះ ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុង។ ការចាត់ទុកប្រភេទកិច្ចសន្យាដែលមិនយកតម្លៃត្រឹមត្រូវមកកាត់បន្ថយដោយគោលគំនិតចម្បងថា របបភាគបម្រុងគឺជារបបនៃការការពារអ្នកដែលមានសិទ្ធិលើភាគបម្រុងពីការចាត់ចែងដោយគ្មានកម្រៃ។

ឧទាហរណ៍ : នៅពេលដែលនៅរស់ មតកជនបានលក់របស់មួយដែលមានតម្លៃ ១០០០ដុល្លារក្នុងតម្លៃតែ ២៥០ដុល្លារប៉ុណ្ណោះ។ ប្រសិនបើភាគីទាំងសងខាងបានដឹងថាវាបានប៉ះពាល់ដល់ភាគបម្រុងរបស់សន្តតិជន កិច្ចសន្យានេះនឹងចាត់ទុកជាប្រទានកម្ម ហើយនឹងក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។ ប៉ុន្តែនៅពេលកាត់បន្ថយការទិញលក់នេះ ត្រូវសងឱ្យអ្នកទិញវិញនូវប្រាក់ ២៥០ដុល្លារដើម្បីជាការរក្សាសមភាពរវាងភាគី។

ការអនុវត្តបែបនេះក៏ត្រូវយកមកចាត់ចែងដូចគ្នាទៅលើការលើកលែងកាតព្វកិច្ចដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ។

**ង. ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម**

ក្នុងករណីដែលសហសន្តតិជន អច្ច័យលាភី ឬបដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដទៃ ជនដែលជាអនុ

[65] មាត្រា១២៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[66] មាត្រា១២៤២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ប្បទាន(អនុប្បទាយី)ត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតដែលបានចាត់ចែង ទៅឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង[67]។ ក្នុងករណីដែលបានបង្កើតផលុបភោគ ឬសិទ្ធិប្រាតិភោគប្រត្យក្ស ក៏ស្ថិតក្នុងស្ថានភាពនេះដែរ។ ដោយសារតែសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងគឺជា សិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត នាំឱ្យ អច្ច័យទាន ឬប្រទានកម្ម ជាដើមត្រូវបាត់បង់នូវអានុភាពជាស្វ័យប្រវត្តិក្នុងកម្រិតដែលបំពានទៅលើភាគបម្រុង ដោយសារការអនុវត្តសិទ្ធិរបស់អ្នកមានសិទ្ធិលើភាគបម្រុងនោះ ដែលបណ្តាលឱ្យសិទ្ធិរបស់អច្ច័យលាភីទទួលបាន ត្រូវធ្លាក់ទៅលើអ្នកដែលមានសិទ្ធិលើភាគបម្រុង ដែលទទួលនូវចំណែកមត៌កពីមតកជនក្នុងកម្រិតនោះ។ ប្រសិនបើចាត់ទុកនូវអនុប្បទាននោះថាគ្មានសុពលភាពនោះទេ នឹងធ្វើឱ្យមានការបាត់បង់សុវត្ថិភាពជំនួញ ហេតុនេះហើយបានជាគ្រាន់តែសងនូវតម្លៃបានហើយ លើកលែងតែកម្មវត្ថុនៃការកាត់បន្ថយនោះត្រូវបានផ្ទេរទៅកាន់ជនទុច្ចរិត និងមានកំហុស នោះយើងអាចចាត់ទុកថាការផ្ទេរនោះគ្មានសុពលភាព ចំណែកឯអ្នកដែលមានសិទ្ធិលើភាគបម្រុងអាចទាមទារវត្ថុនោះពីអនុប្បទានិកបាន។

**ច. សំណងដោយបង់តម្លៃ**

សហសន្តតិជន អច្ច័យលាភី ឬបដិគ្គាហក ដែលជាអ្នកទទួលកាតព្វកិច្ចក្នុងការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អាចរួចពីកាតព្វកិច្ចនៃការសងបាន ដោយបង់តម្លៃនៃចំណែកមត៌កដែលបានកំណត់ តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬតម្លៃនៃកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវទទួលការកាត់បន្ថយ[68]។ ក្នុងករណីនេះគឺមិនចាំបាច់សងដល់អ្នកដែលមានសិទ្ធិលើភាគបម្រុងជាវត្ថុទេ គ្រាន់តែសងថ្លៃនោះវិញក៏បានហើយ ដោយគេគិតអំពីជីវភាពរស់នៅរបស់អ្នកដែលមានសិទ្ធិលើភាគបម្រុង។ តែបើអ្នកដែលមានកាតព្វកិច្ចមិនបានអះអាងថានឹងសងជាតម្លៃ នោះអ្នកដែលមានសិទ្ធិលើភាគបម្រុងមិនអាចទាមទារឱ្យសងជាប្រាក់នោះទេ គឺបានត្រឹមតែសងជាវត្ថុតែប៉ុណ្ណោះ។ ម៉្យាងទៀត ប្រសិនបើអ្នកដែលមានកាតព្វកិច្ចបានអះអាងថានឹងសងថ្លៃ ហើយមានការព្រមព្រៀងគ្នារួចហើយលើតម្លៃ ហើយបានសងហើយ នោះបណ្តាលឱ្យសិទ្ធិទាមទារឱ្យកាត់បន្ថយរលត់ដោយស្វ័យប្រវត្តិដែរ។

**២.៤.៣ ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយចំណែកដើម្បីបង្គ្រប់ភាគបម្រុង**

ជនដែលមានសិទ្ធិលើការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ក្រោយការបែងចែកនឹងត្រូវរលត់សិទ្ធិរបស់ខ្លួន ដោយអាជ្ញាយុកាល បើអំឡុងពេលមួយ(០១)ឆ្នាំ បានកន្លងហួស ដោយគិតចាប់ពីពេលដែលអ្នកដែលមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងការ

[67] មាត្រា១២៤៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[68] មាត្រា១២៤២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

កំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬការទទួលផលប្រយោជន៍ដែលត្រូវកាត់បន្ថយ ឬក្នុងករណីអំឡុងពេល៥(ប្រាំ)ឆ្នាំ បានកន្លងផុតទៅគិតចាប់ពីពេលចាប់ផ្ដើមសន្តតិកម្ម។

**២.៤.៣.១ ការបោះបង់ចោលភាគបម្រុង**

ភាគបម្រុងអាចបោះបង់ចោលមួយផ្នែក ឬទាំងស្រុងបាន។ការបោះបង់នេះគឺអាចធ្វើបានដោយការបង្ហាញឆន្ទៈតែម្ខាង ចំពោះអ្នកមានកាតព្វកិច្ច។ ប៉ុន្តែការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្ដើមសន្តតិកម្ម មានអានុភាព លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ[69] ។ ការសុំឱ្យតុលាការត្រួតពិនិត្យនេះគឺ ក្នុងគោលបំណងកុំឱ្យក្រោមហេតុផលនៃការចាញ់ប្រៀបឪពុកម្ដាយ ជាអាទិ៍ ហើយតុលាការត្រូវវិនិច្ឆ័យមើលថា តើវាជាឆន្ទៈរបស់អ្នកដែលមានសិទ្ធិក្នុងការបោះបង់ទេ ឬតើមានសមភាពនៃហេតុផលដែរឬទេ។ មួយវិញទៀត ក្នុងករណីដែល មានការបោះបង់ចោលសិទ្ធិមុនពេលចាប់ផ្ដើមសន្តតិកម្ម ហើយទទួលបានការអនុញ្ញាតពីតុលាការក៏ដោយ តែមានការផ្លាស់ប្ដូរចិត្តមុនពេលចាប់ផ្ដើមសន្តតិកម្ម អ្នកមានសិទ្ធិលើភាគបម្រុងនោះអាចដាក់ពាក្យស្នើសុំឱ្យតុលាការលុបចោលនូវសេចក្ដីសម្រេចមុនបាន ប្រសិនបើមានស្ថានភាពផ្សេងៗក្រោយពេលបោះបង់។

**២.៤.៣.២ ករណីជាសហសន្តតិជន**

ការរលត់សិទ្ធិដោយអាជ្ញាយុកាល នៃសិទ្ធិនៃការទាមទារឱ្យកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ ឬការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ។ មានន័យថាភាគបម្រុងរបស់ម្នាក់ៗមានផ្សេងៗពីគ្នា នោះទោះបីជាការរលត់ដោយអាជ្ញាយុកាលលើការបោះបង់សិទ្ធិរបស់សន្តតិជនណាម្នាក់ពុំមានការប៉ះពាល់ដល់សិទ្ធិ លើភាគបម្រុងរបស់សហសន្តតិជនដទៃទេ។

[69] មាត្រា១២៤៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី៣
# ការអនុវត្តនៃសន្តតិកម្មតាមច្បាប់

# ជំពូកទី៣
# ការអនុវត្តនៃសន្តតិកម្មតាមច្បាប់

នៅក្នុងជំពូកទី៣ នេះយើងនឹងបកស្រាយអំពីការអនុវត្តផ្សេង ដែលទាក់ទងទៅនឹងសន្តតិកម្មតាមច្បាប់ ដែលនៅក្នុងចំណុច៣.១ "ការយល់ព្រមទទួលយក និងការបោះបង់ចោលសន្តតិកម្ម" ចំណុច៣.២ "របបនៃការគ្រប់គ្រង និងនីតិវិធីនៃការបែងចែកសន្តតិកម្មតាមច្បាប់" រួមទាំងស្ថានភាពពិសេសផ្សេងៗដែលអាចកើតមានឡើងក្នុងសន្តតិកម្មតាមច្បាប់។

សន្តតិកម្មគឺជារបត់មួយ ដែលធ្វើឱ្យផ្លាស់ប្តូរនូវទំនាក់ទំនងគតិយុត្តរវាងមតកជន ដែលបានទទួលមរណភាព និងញាតិរបស់មតកជននោះ ព្រមទាំងឋានៈរបស់ជនទាំងនោះ។ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានទទួលយកនូវគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិក្នុងសន្តតិកម្ម ដូចនេះសន្តតិជនមានសិទ្ធិក្នុងការសម្រេចចិត្តក្នុងការទទួលយក ឬមិនទទួលយកនូវចំណែកមត៌ក ទៅតាមការពិចារណារបស់ខ្លួន។ ការទទួលយកនូវគោលការណ៍នេះគឺដើម្បីធានានៃជីវភាពរបស់អ្នកជំនាន់ក្រោយ ដោយផ្តល់អាទិភាពដល់សន្តតិជនក្នុងការពិចារណា ក្នុងករណីដែលកាតព្វកិច្ចមានច្រើនជាងសិទ្ធិ និងផលប្រយោជន៍។

## ៣.១ ការយល់ព្រមទទួលយក និងការបោះបង់ចោលសន្តតិកម្ម

នៅក្នុងផ្នែកទី១ នេះយើងនឹងបកស្រាយអំពី ករណីការយល់ព្រមទទួលយកសន្តតិកម្មរបស់សន្តតិជន ដោយមានការទទួលយកមានកម្រិត និងទទួលយកទាំងស្រុង នៅក្នុងកថាខណ្ឌទី១។ ចំណែកឯកថាខណ្ឌទី២វិញ នឹងបរិយាយអំពីការបោះបង់ចោលសន្តតិកម្មរបស់សន្តតិជន។ ថាតើក្នុងការទទួលយក និងការបោះបង់មានករណីណាខ្លះ?

### ៣.១.១ ការយល់ព្រមទទួលយកសន្តតិកម្ម

សន្តតិជនត្រូវធ្វើការយល់ព្រម ឬបោះបង់ចោលសន្តតិកម្ម ទាំងស្រុង ឬដោយកម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម[70]។ ចំពោះអំឡុងពេលនេះអាចពន្យារពេលបាន តាមការដាក់ពាក្យស្នើសុំទៅកាន់តុលាការ ដើម្បីជាការទុកពេលក្នុងការពិចារណានូវលទ្ធភាពផ្សេងៗ ដល់សន្តតិជនក្នុងការបង្ហាញឆន្ទៈថា បោះបង់ឬយល់ព្រមទទួលយកសន្តតិកម្ម។ នេះជាបញ្ញត្តិសម្រមសម្រួលមួយ ចំពោះសន្តតិជនណាដែលគ្រាន់តែទទួលសន្តតិកម្មនឹងធ្វើឱ្យខ្លួនក្ស័យធន ដោយសារតែកាតព្វកិច្ច ឬបំណុលធ្ងន់ធ្ងរ ដែលជាការធ្វើឱ្យមានការលើកលែង ដល់សន្តតិជនទាំងនោះក្នុងការបោះបង់សិទ្ធិរបស់ខ្លួនតែម្តង ហើយទោះបីជាក្នុងករណីគ្មានបំណុលឬកាតព្វកិច្ចក៏ដោយ ក៏អនុញ្ញាតឱ្យមានការបោះបង់ ក្នុងករណី

[70] មាត្រា១២៤២ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

សន្តតិជនមិនចង់ទទួលនូវចំណែកមតិកជាមួយជន ដែលខ្លួនមិនពេញចិត្ត ឬមានទំនាក់ទំនងល្អក់កករជាមួយគ្នា។ បន្ថែមពីនេះទៅទៀត ការកំណត់នូវការពន្យារពេលតាមរយៈការដាក់ពាក្យមកតុលាការ គឺជាស្ថានភាពដែលមតិករបស់មតកជនមានច្រើនកន្លែង ជាអាទិ៍ និងអាចធ្វើឱ្យតុលាការពិចារណាទៅលើលក្ខខណ្ឌគុណភាពនៃមតិក កាតព្វកិច្ច ដែលទទួលដោយសន្តតិកម្ម ឬការធ្វើបញ្ជីសារពើភណ្ឌជាអាទិ៍។

ប្រសិនបើសន្តតិជនបានទទួលមរណភាពនៅមុនពេលធ្វើការយល់ព្រម ឬបោះបង់ នៅក្នុងអំឡុងពេល ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា១២៤៨ ដែលបានបកស្រាយខាងលើការគណនាត្រូវធ្វើឡើងដោយគិតចាប់តាំងពីពេល ដែលសន្តតិជនរបស់ជននោះបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម[71]។ ឧទាហរណ៍ថា មតកជន ក មានសន្តតិជនចំនួន ២នាក់ គឺ ខ និង គ។ ប្រសិនបើ ខ បានទទួលមរណភាពដោយមិនទាន់យល់ព្រម ឬបោះបង់មតិកនៅឡើយ ដោយមាន ឃ ជាសន្តតិជនជំនួស។ អំឡុងពេលបានជិតដល់សម្រាប់ ឃ ក៏ត្រូវធ្វើការយល់ព្រមឬបោះបង់សន្តតិកម្មចំពោះមតិករបស់ ខ ដែរ ប៉ុន្តែប្រសិនបើ ឃ បានបោះបង់នូវសន្តតិកម្មរបស់ ខ នោះ ឃ មិនអាចធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្មចំពោះមតិករបស់ ក បានទេ មានន័យថា ឃ បានបោះបង់ចោលមតិកទាំងរបស់ ខ និង ក។ ឃ អាចធ្វើការយល់ព្រម ឬបោះបង់ចោលនូវសន្តតិកម្មចំពោះមតិករបស់ ក បានតែក្នុងករណីដែលបានយល់ព្រមនូវសន្តតិកម្មចំពោះមតិករបស់ ខ ប៉ុណ្ណោះ។ ម៉្យាងវិញទៀតបើសិនសន្តតិជនជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅវិញ អំឡុងពេលនៃការកំណត់ក្នុងមាត្រា១២៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា ត្រូវគណនាដោយគិតចាប់ពីពេល ដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះបានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅចាប់ផ្តើម[72]។ នេះមានន័យថាដើម្បីឱ្យសន្តតិជនដែលជា អនីតិជន ឬជនស្ថិតក្រោមអាណាព្យាបាលទូទៅ ធ្វើការបង្ហាញឆន្ទៈថាយល់ព្រម ឬបោះបង់មតិក ចាំបាច់ត្រូវមានការធ្វើការសម្រេចចិត្តពីអ្នកដែលមានសិទ្ធិអំណាចមេបា ឬអាណាព្យាបាល។

បន្ថែមពីនេះទៅទៀត នៅពេលដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើនដោយមិនអាចយកមតិកទៅសងគ្រប់គ្រាន់ទេ ដោយសន្តតិជនមិនដឹងពីអត្ថិភាពនៃកាតព្វកិច្ចនេះទេ នោះតាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលច្បាប់បានកំណត់ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ដោយពិចារណាលើស្ថានភាព ដែលសន្តតិជនជឿជាក់ថា

[71] មាត្រា១២៤៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[72] មាត្រា១២៥០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

មតកជនគ្មានមតិកសកម្មទេ ដោយការជឿជាក់នេះមានហេតុផលសមរម្យ (គោលការណ៍សុចរិតភាព និងភាពស្មោះត្រង់)។ ជាគោលការណ៍ ការយល់ព្រម ឬការបោះបង់ចោលសន្តតិកម្ម មិនអាចលុបចោលបានឡើយ[73]។ ការកំណត់មិនអាចលុបបានដូច្នេះ ដោយគេគិតអំពីផលនៃការប៉ះពាល់ទៅលើផលប្រយោជន៍របស់បុគ្គលពាក់ពន្ធ័នឹងសន្តតិកម្ម ដូចជាសហសន្តតិជន ឬតតិយជនដែលជាម្ចាស់បំណុលជាអាទិ៍។ ប៉ុន្តែមានអញ្ញត្តិកម្ម ដែលអាចឱ្យលុបចោលការយល់ព្រម ឬការបោះបង់ដោយមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈ ច្បាប់ក៏បានកម្រិតពេលវេលាក្នុងការអនុវត្តសិទ្ធិលុបចោលនេះ នៅអំឡុងពេល៦(ប្រាំមួយ)ខែ ដោយគិតពីពេលដែលអាចផ្តល់សច្ចានុមតិ ឬក្នុងអំឡុងពេល៥(ប្រាំ)ឆ្នាំគិតចាប់ពីពេលផ្តើមធ្វើសន្តតិកម្ម តាមការដាក់ពាក្យស្នើសុំទៅតុលាការ។ ចំណែកឯសិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកក្នុងបណ្តឹងចំពោះសន្តតិជននៅមុនពេលយល់ព្រមលើសន្តតិកម្មឡើយ មានន័យថានៅពេលដែលសន្តតិជនមិនទាន់បានយល់ព្រមឬបោះបង់សន្តតិកម្មទេ អ្នកទទួលបន្តក៏មិនទាន់ច្បាស់លាស់ ដូច្នេះប្រសិនបើមានបណ្តឹងត្រូវទាមទារឱ្យជ្រើសតាំងអ្នកគ្រប់គ្រងមតិកជាបណ្តោះអាសន្ន ដើម្បីអាចចាប់ផ្តើមធ្វើសកម្មភាពបណ្តឹងទៅលើអ្នកគ្រប់គ្រងនោះ។ ហើយនីតិវិធីនោះត្រូវបានផ្អាករហូតដល់ពេលសន្តតិជនយល់ព្រមសន្តតិកម្ម។

### ៣.១.១.១ ទទួលយកទាំងស្រុង

ការយល់ព្រមទាំងស្រុង គឺជាករណីដែលសន្តតិជនបានយល់ព្រមទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន[74] មានន័យថាសន្តតិជនទទួលយកទាំងស្រុងនូវសន្តតិកម្ម។ ការយល់ព្រមទាំងស្រុងតម្រូវឱ្យមានការបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ហើយ ដោយមិនបាច់ដាក់ពាក្យស្នើសុំទៅកាន់តុលាការ ដូចករណីយល់ព្រមដោយកម្រិត ឬការបោះបង់សន្តតិកម្មនោះទេ។ មួយវិញទៀត ទោះបីជាក្នុងករណីសន្តតិជនបានធ្វើការយល់ព្រមទទួលដោយមានកម្រិត ឬបោះបង់សន្តតិកម្មក៏ដោយ ប្រសិនបើសន្តតិជនបានធ្វើសកម្មភាពណាមួយក្នុងចំណោមសកម្មភាពខាងក្រោមនេះ ត្រូវចាត់ទុកថាបានយល់ព្រមទាំងស្រុងតាមផ្លូវច្បាប់[75] :

- សន្តតិជនបានចាត់ចែងមតិកទាំងអស់ ឬមួយភាគ លើកលែងតែសកម្មភាពរក្សា និងត្រឹមជាគ្រប់គ្រង។
- បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬបោះបង់ ក្នុងអំឡុងពេល ០៣ (បី) ខែគិតចាប់ពីពេល ដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម លើកលែងតែមានពាក្យសុំពន្យារពេលទៅកាន់តុលាការ។

[73] កថាខណ្ឌទី១ មាត្រា១២៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[74] មាត្រា១២៥៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា
[75] មាត្រា១២៥៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

- ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬបោះបង់ ក៏ដោយ បើសន្តតិជន បានលាក់មតិកទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មតិកទាំងនោះដើម្បីខ្លួនលើកលែងតែក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម។

### ៣.១.១.២ ទទួលយកមានកម្រិត

ការទទួលយកមានកម្រិតគឺជាករណីដែលសន្តតិជនយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម[76] មានន័យថាសន្តតិជនក្លាយទៅជាកូនបំណុល ដោយទទួលនូវសន្តតិកម្មនៃកាតព្វកិច្ចទាំងអស់របស់មតកជន ប៉ុន្តែសន្តតិជនអាចកម្រិតនូវការទទួលខុសត្រូវរបស់ខ្លួនបានត្រឹមកម្រិតនៃមតិក វៀរលែងតែសន្តតិកម្មស្ម័គ្រចិត្តសងដោយខ្លួនឯង។ ប៉ុន្តែនៅក្នុងករណីដែលមានសហសន្តតិជន ការយល់ព្រមដោយមានកម្រិតនេះត្រូវធ្វើឡើងរួមគ្នាទាំងអស់។ ទៀតសោតការយល់ព្រមដោយមានកម្រិតតម្រូវឱ្យមាននីតិវិធីនៃការជម្រះបញ្ជី ដើម្បីឱ្យមានសមភាពក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន ហើយសហសន្តតិជនត្រូវយល់ស្រមជាមួយគ្នាចំពោះការសង ដោយហេតុថាប្រសិនមានតែសន្តតិជនមួយចំនួនយល់ព្រម ហើយបានអះអាងនូវចំណែកមតិក នោះធ្វើឱ្យការជម្រះបញ្ជីទៅលើមតិកទាំងអស់ នឹងមិនអាចធ្វើបានទៅរួច។ ក្នុងករណីមានការបោះបង់សន្តតិកម្ម នោះគេត្រូវការតែការយល់ព្រមតែពីសន្តតិជន ដែលនៅសល់តែប៉ុណ្ណោះ ដោយសារថាជនដែលបានបោះបង់សន្តតិកម្មមិនត្រូវបានចាត់ទុកជាសន្តតិជនពីដំបូងមកម្លេះ។ ខាងក្រោមនេះគឺជាវិធី និងអានុភាពនៃការយល់ព្រមដោយមានកម្រិតៈ

#### ក. វិធី

វិធីក្នុងការធ្វើការយល់ព្រមដោយកម្រិត សន្តតិជនត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យស្នើសុំអំពីការយល់ព្រមដោយកម្រិត ទៅកាន់តុលាការ ក្នុងអំឡុងពេលដែលមានចែងក្នុងមាត្រា ១២៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជា[77] ពោលគឺ ០៣(បី)ខែដោយគិតចាប់ពីថ្ងៃ ដែលសន្តតិជនដឹងអំពីការចាប់ផ្ដើមសន្តតិកម្មរបស់ខ្លួន។ ក្នុងករណីមានសហសន្តតិជន តម្រូវឱ្យសហសន្តតិជនទាំងអស់ដាក់ពាក្យស្នើសុំទៅកាន់តុលាការ ដើម្បីយល់ព្រមដោយកម្រិត ហើយទោះបីជាផុតអំឡុងពេលសម្រាប់សន្តតិជនណាមួយក៏ដោយ ក៏គេអាចគិតចាប់ពីពេលដែលសន្តតិជនក្រោយគេបានដឹងពីការចាប់ផ្ដើមសន្តតិកម្ម មកធ្វើជាមូលដ្ឋាន[78]។ នៅពេល

[76] កថាខណ្ឌទី១ មាត្រា១២៥៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[77] មាត្រា១២៥៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

[78] ទំព័រទី១១៨ សេចក្ដីកំនត់ក្រមរដ្ឋប្បវេណី ភាគ៦ : គន្លឹះទី៨ និង៩ ក្រសួងយុត្តិធម៌

ដែលដាក់ពាក្យសុំទៅកាន់តុលាការសន្តតិជន ត្រូវដាក់នូវបញ្ជីសារពើភ័ណ្ឌនៃមតិក ដោយអមជាមួយនូវ មតិកសកម្ម និងមតិកអកម្ម ដែលសន្តតិជនទទួលបន្តពីមតកជន នៅពេលចាប់ផ្តើមសន្តតិកម្ម ក្នុងកម្រិតមួយដែលសន្តតិជនខ្លួនឯងអាចដឹង ដោយមូលហេតុថា ប្រសិនបើមិនមានការបញ្ជាក់ឱ្យច្បាស់លាស់នោះទេ នោះនឹងត្រូវបានចាត់ទុកជាការយល់ព្រមទាំងស្រុងដូចដែលមានចែងក្នុងមាត្រា១២៥៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ។

**ខ. អានុភាព**

ក្នុងករណីដែលមានការយល់ព្រមដោយកម្រិត បណ្តាលឱ្យមានអានុភាពដូចខាងក្រោម៖

- ម្ចាស់បំណុលរបស់មតកជន ពុំអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិរបស់សន្តតិជននោះបានឡើយ
- ទោះបីជាយ៉ាងនេះក៏ដោយ សិទ្ធិនិងកាតព្វកិច្ចរបស់សន្តតិជនទៅលើមតកជនមិនអាចរលត់បានដោយព្យាកុលភាព[79]ទេ ដោយហេតុថាទោះបីជាទទួលស្គាល់ដោយកម្រិតក៏ដោយ ក៏មតិកត្រូវធ្លាក់ទៅលើសន្តតិជន ហើយទ្រព្យសម្បត្តិត្រូវធ្វើការឆ្លងកាត់ការជម្រះបញ្ជីផ្សេងៗពីទ្រព្យសម្បត្តិរបស់មតកជនសិន។

### ៣.១.២ ការបោះបង់ចោលសន្តតិកម្ម

ក្នុងករណីដែលសន្តតិជនមានឆន្ទៈ ក្នុងការបោះបង់ចោលចំណែកមតិក របស់ខ្លួននោះ សន្តតិជនរូបនោះត្រូវធ្វើការដាក់ពាក្យស្នើសុំទៅកាន់តុលាការ មិនឱ្យលើសពីអំឡុងពេល ០៣(បី) ខែឡើយ ដោយគិតចាប់ពីពេលដែលដឹងអំពីពេលវេលានៃការចាប់ផ្តើមសន្តតិកម្ម។ បុគ្គលដែលបានធ្វើការបោះបង់ចោលនូវសន្តតិកម្មគឺត្រូវបានចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមកម្លេះ[80]។ សន្តតិជនដែលបានបោះបង់ចោលសន្តតិកម្មគឺមិនមានសន្តតិជនជំនួសទេដូចក្នុងករណីអភ័ព្វបុគ្គល ឬមរណភាពរបស់សន្តតិជនមុនពេលចាប់ផ្តើមសន្តតិកម្មឡើយ។ ប៉ុន្តែអ្នកដែលមានលំដាប់បន្តបន្ទាប់អាចទទួលសន្តតិកម្មបាន ក្នុងករណីដែលសហសន្តតិជនលំដាប់មុនទាំងអស់បានបោះបង់ចំណែករបស់ខ្លួនអស់។

## ៣.២ របបនៃការគ្រប់គ្រង និងនីតិវិធីនៃការបែងចែកសន្តតិកម្មតាមច្បាប់

មុននឹងទទួលបានការសម្រេចចិត្តរបស់សន្តតិជនថា យល់ព្រមទទួលយក ឬក៏ធ្វើការបោះបង់ចោលនូវសន្តតិកម្មនោះ យើងត្រូវមានការគ្រប់គ្រងទៅលើកម្មវត្ថុនៃសន្តតិកម្មនោះ ដែល

[79] សន្ធានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ៖ ករណី ដែលកម្មសិទ្ធ ឬសិទ្ធិប្រត្យក្សផ្សេងទៀត ដែលមានលើវត្ថុតែមួយធ្លាក់ទៅលើបុគ្គលតែម្នាក់ឬករណីដែលសិទ្ធិប្រត្យក្ស ក្រៅពីកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀត ដែលមានកម្មវត្ថុជាសិទ្ធិប្រត្យក្សនោះ ធ្លាក់ទៅលើបុគ្គលតែម្នាក់។

[80] មាត្រា១២៦១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា

ជា "ការគ្រប់គ្រងមតិក" ជាមុនសិន ដែលនឹងបកស្រាយក្នុងចំណុច៣.២.១។ បន្ទាប់មកទៀត "ការបែងចែកចំណែកមតិក" ទៅឱ្យសន្តតិជននីមួយៗទៅតាមច្បាប់ ឬតាមការព្រមព្រៀង ឬតាមតុលាការក្នុងចំណុច៣.២។ ជាចុងក្រោយ យើងនឹងសិក្សាទៅលើ "អានុភាព និងការធានាកាតព្វកិច្ច" នៃសន្តតិកម្ម។

### ៣.២.១ ការគ្រប់គ្រងមត៌ក

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសន្តតិកម្មមិនអាចមិនមានការគ្រប់គ្រងនោះទេ នៅមុនពេលដែលសន្តតិជនសម្រេចចិត្តក្នុងការទទួលយក ឬធ្វើការបោះបង់ចោលនូវសិទ្ធិក្នុងការទទួលបានចំណែកមតិករបស់ខ្លួន។ ដោយយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិអំពីអ្នកទទួលបន្ទុកគ្រប់គ្រងចំណែកមតិកនោះដូចខាងក្រោមនេះ៖

ទី១ ការរក្សាទុក និងការគ្រប់គ្រងដោយសន្តតិជន មានន័យថា ក្រោយពេលមតកជនបានទទួលមរណភាពទៅ សន្តតិជនរូបណាដែលបានធ្វើការកាន់កាប់ទ្រព្យសម្បត្តិរបស់មតកជននោះ នឹងធ្វើការរក្សាទុក និងគ្រប់គ្រងមតិករហូតបានធ្វើការបែងចែករួចហើយ ក្នុងឋានៈជាអ្នកគ្រប់គ្រងសុចរិត[81]។ មួយវិញទៀត ទោះបីជាសន្តតិជនរូបនោះបានបោះបង់ចំណែកមតិករបស់ខ្លួនក៏ដោយក៏កាតព្វកិច្ចនេះមិនអាចទម្លាក់ចោលបានដែរ[82]។ ក្នុងករណី ចំណែកមតិកដែលជាចំណែកសហសន្តតិជននោះ ត្រូវមានការរក្សា និងគ្រប់គ្រងចំណែកមតិកជាមួយគ្នា មិនមែនជាកាតព្វកិច្ចរបស់សន្តតិជនតែម្នាក់នោះទេ[83]។

ទី២ ក្នុងករណី មានអ្នកប្រតិបត្តិមតកសាសន៍ ដែលជាអ្នករក្សាគ្រប់គ្រងលិខិតមតកសាសន៍ ដោយអនុលោមតាមមាត្រា១២១៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ អ្នកប្រតិបត្តិមតកសាសន៍នោះជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់មតកជននោះ។ ក្នុងចំណុចនេះ ដោយវាផ្តោតទៅលើចំពោះតែករណីដែលមានមតកសាសន៍ ហើយបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ប៉ុណ្ណោះ ដូច្នេះ អ្នកគ្រប់គ្រងនោះ គឺត្រូវតែជាអ្នកប្រតិបត្តិមតកសាសន៍នោះតែប៉ុណ្ណោះ ប៉ុន្តែប្រសិនបើមតកសាសន៍បានបញ្ញត្តិផ្សេង ឬមានលក្ខណៈច្បាស់លាស់ទៅលើទ្រព្យសម្បត្តិណាមួយដែលបានកំណត់ឱ្យអ្នកប្រតិបត្តិមតកសាសន៍មានសិទ្ធិក្នុងការរក្សាត្រឹមកម្រិតណា[84]។

ទី៣ ការគ្រប់គ្រងមតិក ដែលចាត់តាំងដោយតុលាការ ប្រសិនបើ គ្មានករណីទាំងពីរខាងលើនោះទេ ពោលគឺគ្មានអ្នកគ្រប់គ្រងមតិក និងគ្មានអ្នកប្រតិបត្តិមតកសាសន៍ តុលាការមានឆន្ទានុ

[81] មាត្រា ១២៦២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[82] មាត្រា ១២៦២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[83] មាត្រា ១២៦២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[84] មាត្រា ១២៦៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

សិទ្ធិក្នុងការកំណត់អ្នកគ្រប់គ្រង លុះត្រាតែបានបែងចែកចំណែកមតិករួចរាល់ហើយ ឬក៏មានការព្រមព្រៀងចំពោះមតិក តាមរយៈពាក្យស្នើសុំពីសន្តតិជន ឬអច្ច័យលាភី ឬម្ចាស់បំណុលរបស់មតកជន ប៉ុន្តែការគ្រប់គ្រងរបៀបនេះ ជាការគ្រប់គ្រងបណ្តោះអាសន្ន[85]។ រាល់សោហ៊ុយក្នុងការគ្រប់គ្រងនេះ ត្រូវកាត់ពីទ្រព្យសម្បត្តិរបស់មតកជននោះ ប៉ុន្តែបើជាកំហុសរបស់សន្តតិជន សន្តតិជននោះត្រូវទទួលខុសត្រូវដោយខ្លួនឯង[86]។

### ៣.២.២ ការបែងចែកមត៌ក

ការបែងចែកចំណែកមតិក អាចត្រូវបានធ្វើឡើងដោយមានការព្រមព្រៀងគ្នាពីសំណាក់សន្តតិជន ៣.២.២.១ និងការបែងចែកចំណែកមតិកដែលធ្វើឡើងដោយតុលាការ ៣.២.២.២។ ការបែងចែកនេះ ជាចំណុចក្នុងការកំណត់ចំណែករបស់សន្តតិជននីមួយៗ ដែលទទួលស្គាល់ដោយច្បាប់ ហើយបង្កើតបានជាអានុភាពគតិយុត្តមួយក្នុងការយកមកអនុវត្ត។

#### ៣.២.២.១ តាមការព្រមព្រៀងគ្នា

យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧នៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា ការបែងចែកចំណែកមតិកត្រូវធ្វើឡើងតាមការពិភាក្សាគ្នា និងព្រមព្រៀងគ្នានៃសន្តតិជនទាំងអស់ នាពេលណាក៏បានដែរ ក្រោយពីផុតរយៈពេល ១ (មួយ) ខែគិតចាប់ពីពេលបើកសន្តតិកម្ម[87]។ ការកំណត់អំឡុងពេល ១ខែ ហាមមិនឱ្យបែងចែកទ្រព្យសម្បត្តិនេះដោយសារតែ ចាំបាច់ត្រូវការគោរពចំពោះវិញ្ញាណក្ខន្ធរបស់មតកជន និងត្រូវស្វែងរកសហសន្តតិជន (ករណីមានអាពាហ៍ពិពាហ៍មុន ឬមានការទទួលស្គាល់កូនឬអត់) និងកំណត់នូវទំហំសហសន្តតិជនឱ្យបានច្បាស់លាស់ ដោយហេតុថាតើសហសន្តតិជនបានបោះបង់ ឬយល់ព្រមទទួលសន្តតិកម្មឬអត់។ ប៉ុន្តែ ការផ្លាស់ប្តូរម្ចាស់សិទ្ធិលើមតិកពីមតកជនទៅឱ្យសន្តតិជន ឬអច្ច័យលាភី ដោយការព្រមព្រៀងរវាងសហសន្តតិជន គឺគ្មានប្រសិទ្ធភាពឡើយ លុះត្រាតែផុតអំឡុងពេល ៣ (បី) ខែ នៃការបង្ហាញឆន្ទៈទទួលយក ឬបោះបង់ចោលសន្តតិកម្មនៃសន្តតិជន[88]។ ករណីលើកលែងក្នុងការផ្លាស់ប្តូរម្ចាស់សិទ្ធិអំឡុងពេល ៣ (បី)ខែខាងលើនេះទៅបាន គឺលុះត្រាតែមានភាពចាំបាច់ដើម្បីសងកាតព្វកិច្ចរបស់មតកជន ឬមតកជនបានបង្ហាញឆន្ទៈក្នុងមតកសាសន៍ទៅលើអំឡុងពេលនៃការបែងចែកនោះ [89] ។ គួរឱ្យកត់សម្គាល់នោះ គឺការផ្ទេរសិទ្ធិនៃការបែងចែកចំណែកមតិកដែលបានរៀបរាប់ខាងលើត្រូវធ្វើឡើងដោយមាន

[85] មាត្រា ១២៦៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[86] មាត្រា ១២៦៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[87] មាត្រា ១២៦៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[88] មាត្រា ១២៦៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[89] មាត្រា ១២៧៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

លិខិតគតិយុត្ត ដូចជាកម្មវត្ថុនៃសន្តតិកម្មដែលជាដីធ្លីត្រូវមានលិខិតយថាភូត រីឯការផ្ទេរសិទ្ធិផ្សេងទៀត ត្រូវមានលិខិតជាលាយលក្ខណ៍អក្សរដែរ[90]។

ប្រសិនជាសហព័ទ្ធជាសន្តតិជន ហើយទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសន្តតិកម្ម ជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជននាពេលមានចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធរូបនេះមានអាទិភាពជាងសន្តតិជនដទៃទៀត ក្នុងការទទួលបានទ្រព្យសម្បត្តិនោះមកធ្វើជាកម្មសិទ្ធិ រហូតដល់គ្រប់ចំនួននៃចំណែកមតិករបស់ខ្លួន[91]។ ជាការពិតណាស់ ដោយមូលហេតុនៃចំណងអាពាហ៍ពិពាហ៍ សហព័ទ្ធដែលនៅរស់ត្រូវទទួលបាននូវទ្រព្យសម្បត្តិរួមចំនួនពាក់កណ្តាលដែលជាចំណែករបស់ខ្លួន រីឯទ្រព្យសម្បត្តិរួមពាក់កណ្តាលទៀតត្រូវបូកនឹងទ្រព្យសម្បត្តិដោយឡែករបស់មតកជន នឹងក្លាយទៅជាកម្មវត្ថុមតិករបស់សន្តតិជន [92] ។ ក្នុងការបែងចែកចំណែកមតិក ត្រូវបានពិចារណាទាក់ទងទៅលើប្រភេទ លក្ខណៈនៃវត្ថុ សិទ្ធិដែលមានលើមតិក អាយុ មុខរបរ ទាំងស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត និងស្ថានភាពជីវភាពបច្ចុប្បន្នរបស់សន្តតិជននីមួយៗផងដែរ[93]។ ការរៀបរាប់ខាងលើក៏អាចត្រូវបានពិចារណាដោយសន្តតិជនទាំងអស់គ្នា ក្នុងការបែងចែកចំណែកមតិកដោយមានការព្រមព្រៀងគ្នាដោយមិនមានផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អជាដាច់ខាត។ ក្នុងករណីការបែងចែកបង្កឱ្យមានការប៉ះពាល់ ដល់តម្លៃនៃចំណែកមតិកខ្លាំង សហសន្តតិជនអាចឱ្យសន្តតិជនម្នាក់ក្នុងការទទួលលទ្ធកម្មនៃទ្រព្យសម្បត្តិនោះ តែមានលក្ខខណ្ឌក្នុងការបង់សំណងតាមការពិភាក្សាគ្នា[94]។ ឧទាហរណ៍៖ មតកជនមានដីមួយកន្លែងជាកម្មវត្ថុនៃសន្តតិកម្ម ដែលត្រូវបែងចែកឱ្យសន្តតិជនចំនួនពីរនាក់ តែដោយសារតែការបែងចែកនេះអាចធ្វើឱ្យតម្លៃដីនោះមានការធ្លាក់ចុះយ៉ាងខ្លាំង ឬដោយសារការបែងចែកនេះធ្វើឱ្យមានភាពមិនស្មើគ្នានៃចំណែកនីមួយៗរបស់សន្តតិជនទាំងពីរ។ សន្តតិជនណាម្ខាងអាចស្នើសុំឱ្យសន្តតិជនម្ខាងទៀតធ្វើលទ្ធកម្មលើដីនោះទាំងអស់បានដោយធ្វើការបង់នូវសំណងជាប្រាក់ទៅឱ្យសន្តតិជនដែលផ្តល់លទ្ធកម្មដីនោះតាមការពិភាក្សាគ្នា ឬតាមតម្លៃជាក់ស្តែង។

ដោយហេតុថា ប្រទេសកម្ពុជាជ្រើសយកគោលការណ៍ទទួលយកដោយស្វ័យប្រវត្តិ ដូច្នេះនាំឱ្យ ការបែងចែកចំណែកមតិកក៏ធ្វើការបែងចែកទាំងកាតព្វកិច្ចរបស់មតកជនដែរ តាមសមាមាត្ររបស់សន្តតិជននីមួយៗ ហើយមិនអាចធ្វើការផ្លាស់ប្តូរភាគបន្ទុកនៃកាតព្វកិច្ចដោយគ្មានការយល់ព្រមពីម្ចាស់បំណុលនៃមតកជនបានឡើយ។ ឃ្លាដែលបញ្ញត្តិថា "មិនអាចផ្លាស់ប្តូរភាគបន្ទុកនៃ

[90] មាត្រា ១២៦៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[91] មាត្រា ១២៦៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[92] មាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[93] មាត្រា ១២៦៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[94] មាត្រា ១២៦៧ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

កាតព្វកិច្ច ដោយគ្មានការយល់ព្រមពីម្ចាស់បំណុល” ចង់មានន័យថា ទោះបីជាមានការព្រមព្រៀងគ្នាពីសំណាក់សហសន្តតិជនទាំងអស់ក៏ដោយ ក៏សន្តតិជនទាំងអស់នោះមិនអាចផ្លាស់ប្តូរចំណែកកាតព្វកិច្ចដែលត្រូវបានបែងចែកដោយស្វ័យប្រវត្តិ ទៅតាមចំណែកសន្តតិកម្មរបស់ខ្លួនបានដែរ។ ឧទាហរណ៍៖ ក្នុងករណីមតកជនបានធ្វើអាជីវកម្ម ដោយសន្តតិជនម្នាក់ចង់បន្តវេនពីមតកជនក្នុងការទទួលបន្ទុកលើអាជីវកម្ម ការព្រមព្រៀងនៃសហសន្តតិជនគឺមិនគ្រប់គ្រាន់ទេ ទាល់តែមានការយល់ព្រមពីម្ចាស់បំណុលផង ដែលជាបញ្ហាចោទនោះគឺ ម្ចាស់បំណុលជឿជាក់ថា សន្តតិជនដែលទទួលបន្ទុកលើអាជីវកម្មនោះ ពិតជាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបន្តឬទេ និងមូលហេតុដទៃទៀត[95]។

**៣.២.២.២ តាមផ្លូវតុលាការ**

ក្នុងករណីដែលមិនមានការព្រមព្រៀងលើការបែងចែកចំណែកមតិក ឬមិនអាចពិភាក្សាគ្នាបានពីសំណាក់សន្តតិជនទាំងអស់ សន្តតិជនណាម្នាក់អាចធ្វើការប្តឹងទៅតុលាការឱ្យសុំធ្វើការបែងចែកមតិកនោះ[96]។ តុលាការត្រូវពិចារណាទៅលើស្ថានភាពមួយចំនួនដូចជា ប្រភេទ លក្ខណៈនៃវត្ថុសិទ្ធិដែលមាននៅក្នុងមតិក សំណាងនៃកាតព្វកិច្ចរបស់មតកជន ទម្លាប់នៅក្នុងតំបន់ និងមតិលើសពីពាក់កណ្តាលរបស់សន្តតិជនទាំងអស់[97]។ តុលាការមានឆន្ទានុសិទ្ធិលក់ចំណែកមតិករបស់សហសន្តតិជន ដើម្បីទទួលបានប្រាក់ ហើយធ្វើការបែងចែកទៅឱ្យសន្តតិជនម្នាក់ៗតាមសមាមាត្ររៀងៗខ្លួន ប្រសិនបើគ្មានការព្រមព្រៀងគ្នា ឬការយល់ព្រមអំពីបុគ្គលដែលត្រូវទទួលសន្តតិកម្មនោះ[98]។

ជាងនេះទៅទៀត ទ្រព្យដែលជាកម្មវត្ថុនៃសន្តតិកម្ម ត្រូវបានរាប់ទាំងទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម គឺផលធម្មជាតិ ឬផលស៊ីវិលដែលកើតឡើងពីមតិក ដូចជាការប្រាក់ដែលកើតឡើងក្រោយពេលសន្តតិកម្ម ឬផលដំណាំដែលទទួលបានពីដីមតិក។ មួយវិញទៀត ចំពោះទ្រព្យដែលបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ការបំពានយកកម្មវត្ថុមតិក ឬតាមកិច្ចសន្យាដែលយកមតិកជាកម្មវត្ថុ មានដូចជាសិទ្ធិលើបំណុលដែលអាចទាមទារសំណងនៃការខូចខាត ឬប្រាក់សំណងនៃការខូចខាត ក្នុងករណីដែលសន្តតិជនណាមួយ ឬតតិយជនណាមួយ ទទួលបន្ទុកលើកាតព្វកិច្ចសងសំណងនៃការខូចខាត ដោយសារធ្វើឱ្យបាត់បង់មតិកជាដើម ដូច្នេះទ្រព្យទាំងអស់ដែលបានរៀបរាប់ខាងលើ ត្រូវរាប់បញ្ចូលជាមតិក[99]។

[95] មាត្រា ១២៦៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[96] មាត្រា ១២៧០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[97] មាត្រា ១២៧០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[98] មាត្រា ១២៧១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[99] មាត្រា ១២៧២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

### ៣.២.៣ អានុភាព និងការធានាកាតព្វកិច្ច

ក្រោយពីបានសិក្សាអំពីការគ្រប់គ្រង និងការបែងចែកចំណែកមត៌ករួចរាល់អស់ហើយ ត្រង់កថាខណ្ឌនេះ យើងនឹងសិក្សាទៅលើ "អានុភាពនៃសន្តតិកម្ម" ក្នុងចំណុច ៣.២.៣.១ និង "ការធានាកាតព្វកិច្ចនៃសន្តតិកម្ម" ក្នុងចំណុច ៣.២.៣.២។

#### ៣.២.៣.១ អានុភាពនៃសន្តតិកម្ម

ការបែងចែកមត៌កនឹងមានអានុភាពប្រតិសកម្ម ដែលគិតចាប់ពីពេលបើកសន្តតិកម្មមកម្ល៉េះ ប៉ុន្តែវាមិនអាចតតាំងនឹងតតិយជនទាំងឡាយណាដែលបានចុះបញ្ជី ឬមានលក្ខខណ្ឌតតាំងនោះឡើយ[100]។ លក្ខខណ្ឌនៃការចុះបញ្ជីខាងលើ បង្កើតឡើងក្នុងគោលដៅដើម្បីការពារផលប្រយោជន៍របស់តតិយជនក្នុងកិច្ចការជំនួញ ព្រោះបើប្រើតែអានុភាពប្រតិសកម្មដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់ វាបណ្ដាលឱ្យបាត់បង់សុវត្ថិភាពក្នុងកិច្ចការជំនួញ។

សហសន្តតិជនម្នាក់ៗ នឹងបានទទួលលិខិតបញ្ជាក់សិទ្ធិអំពីទ្រព្យដែលបានលទ្ធកម្មហើយនោះ[101]។ មួយវិញទៀត បើមានការទទួលស្គាល់ថា ជាសន្តតិជន ក្រោយពេលមតកជនបានស្លាប់ហើយសន្តតិជននោះមិនបានចូលរួមក្នុងការពិភាក្សាក្នុងការបែងចែកចំណែកមត៌ក ដោយសារមានការបែងចែកសន្តតិកម្មហើយ សន្តតិជននោះអាចធ្វើការទាមទារបានត្រឹមតែតំលៃមកវិញ [102] ។ ដូច្នេះ ក្នុងការការពារផលប្រយោជន៍របស់សន្តតិជនរូបនោះ ច្បាប់បានផ្ដល់សិទ្ធិឱ្យសន្តតិជននោះធ្វើការទាមទារឱ្យទទួលចំណែកមត៌ករបស់ខ្លួនបានក្នុងរយៈពេល៥ (ប្រាំ) ឆ្នាំគិតចាប់ពីថ្ងៃដែលបានបែងចែកមត៌កនោះ[103]។ ប៉ុន្តែ ក្នុងករណីដែលការពិភាក្សានោះគ្មានសុពលភាព ព្រោះថាមតកជនបានទទួលស្គាល់សន្តតិជនរូបនោះជាកូន កាលមតកជននៅរស់ ប៉ុន្តែសន្តតិជនផ្សេងទៀតពុំបានដឹង ជាហេតុធ្វើឱ្យសន្តតិជនរូបនោះមិនបានចូលរួមពិភាក្សាក្នុងការបែងចែកមត៌ក ឬករណីដែលសន្តតិជនត្រូវបានទទួលស្គាល់ក្រោយពេលមរណភាពរបស់មតកជន មុនការបែងចែកមត៌ក ប៉ុន្តែសន្តតិជនផ្សេងទៀតមិនបានយកចិត្តទុកដាក់ដែលធ្វើឱ្យការបែងចែកនោះមិនមានវត្តមានរបស់សហសន្តតិជនទាំងអស់ ដូច្នេះការបែងចែកនោះចាត់ទុកជាមោឃភាព[104]។ សន្តតិជនរូបនោះនៅតែមានសិទ្ធិជាសន្តតិជនដដែល ព្រោះមានអានុភាពប្រតិសកម្ម តែមិនអាចទាមទារឱ្យមានការបែង

[100] មាត្រា ១២៧៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[101] មាត្រា ១២៧៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[102] មាត្រា ១២៧៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[103] មាត្រា ១៣០៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[104] ទំព័រទី១៣៧ សេចក្ដីកំនត់ក្រមរដ្ឋប្បវេណី ភាគ៦ : គន្ថីទី៨ និង៩ ក្រសួងយុត្តិធម៌

ចែកមត៌កសារជាថ្មីនោះទេ តាមការទាមទារនោះ សន្តតិជនរូបនោះនឹងទទួលបានត្រឹមតែតម្លៃប៉ុណ្ណោះ ដែលហៅថាការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម[105]។

សិទ្ធិលើបំណុលរបស់មតកជននឹងត្រូវធ្វើការបែងចែក ទៅឱ្យសន្តតិជនទៅតាមសមាមាត្រដែលច្បាប់បានកំណត់ដោយស្វ័យប្រវត្តិ ហើយករណីមានការព្រមព្រៀងពីសំណាក់សហសន្តតិជន សិទ្ធិលើបំណុលនោះអាចយកមកធ្វើការបែងចែកជាមត៌កបានទៅតាមភាគ ក្រៅពីចំណែកមត៌កកំណត់ដោយច្បាប់ ការបែងចែកចំណែកមត៌កដោយលិខិតយថាភូតត្រូវធ្វើការបង្ហាញលិខិតនោះទៅឱ្យកូនបំណុលនៃមតកជន ដើម្បីទុកជាវិធីសាស្ត្រតតាំងនឹងកូនបំណុល[106]។ ប៉ុន្តែ កូនបំណុលដែលបានសងបំណុលតាមចំណែកមត៌កនៃសន្តតិជននោះហើយ ដោយសងមុនពេលទទួលបានការជូនដំណឹងនៃការបែងចែក គឺអាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មលើបំណុលតាមការបែងចែកមត៌កនោះបាន[107]។

**៣.២.៣.២ ការធានាភាគព្វកិច្ច**

ជាទូទៅ ការបែងចែកចំណែកមត៌ក សំដៅលើការបំលែងឱ្យកម្មសិទ្ធិអវិភាគរបស់សន្តតិជនទាំងអស់ឱ្យទៅជាកម្មសិទ្ធិសន្តតិជនតែមួយតាមរយៈការព្រមព្រៀងគ្នា ក្នុងរូបភាពម៉្យាងទៀតដូចជាការលក់ទិញ ឬការដូរតែប៉ុណ្ណោះ ក្នុងន័យដើម្បីធ្វើការជួយដល់ការបែងចែកចំណែកមត៌ក [108] ។ ដោយសារតែវាមានរូបភាពដូចជាការទិញលក់ ឬការដូរ ដែលអ្នកលក់មានកាតព្វកិច្ចចំពោះអ្នកទិញ នាំឱ្យសន្តតិជនដែលមានសិទ្ធិក្នុងការគ្រប់គ្រងចំណែកមត៌កនេះ ត្រូវមានកាតព្វកិច្ចក្នុងការធានាចំពោះសន្តតិជនទាំងអស់តាមសមាមាត្រនៃចំណែកមត៌កដែលខ្លួនត្រូវទទួលបាន ទោះបី ជាសន្តតិជនស្ថិតនៅក្នុងស្ថានការណ៍ពិចារណាលើការទទួលយល់ព្រម ឬបោះបង់ចោលចំណែកនោះ។

ក្នុងការធានានេះ នាំឱ្យមានការបែងចែកសារជាថ្មី ប្រសិនបើមានការភ័ន្តច្រឡំក្នុងការបែងចែកចំណែកមត៌ក សន្តតិជនរូបនោះអាចធ្វើការទាមទារនោះបាន។ ឧទាហរណ៍៖ ក្រោយពីឪពុកស្លាប់ទៅ កម្មវត្ថុនៃសន្តតិកម្មគឺមានឡាន និងប្រាក់១០០០០ (មួយម៉ឺន) ដុល្លារ សន្តតិជនទាំងពីរមាន"ក" និង"ខ" បានព្រមព្រៀងគ្នាក្នុងការបែងចែក ឱ្យឡានជាចំណែកមត៌ករបស់ "ក" រីឯ ប្រាក់ ១០០០០ (មួយម៉ឺន) ដុល្លារជាចំណែកមត៌ករបស់ "ខ"។ ប៉ុន្តែ ក្រោយពីបានមើលប័ណ្ណសម្គាល់ម្ចាស់យានយន្តហើយ ទើបដឹងថាម្ចាស់យានយន្តនោះ គឺរបស់ម្តាយរបស់ខ្លួនដែលជាអនីតិសង្វាសជន ដូច្នេះ "ក" ទាមទារឱ្យមានការបែងចែកមត៌កសារជាថ្មី។

[105] មាត្រា ១២៧៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[106] មាត្រា ១២៧៥ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[107] មាត្រា ១២៧៥ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[108] មាត្រា ១២៧៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

### ៣.២.៤ ការសម្រួលខាងម្ចាស់បំណុល

ទោះបីជាមតកជនបានទទួលមរណភាពហើយក៏ដោយ ក៏កាតព្វកិច្ចរបស់មតកជន នៅតែបន្តមានដដែល ហើយបានបន្តទៅឱ្យសន្តតិជនទាំងអស់ ទៅតាមសមាមាត្រនៃចំណែកមតិកដែលសន្តតិជននីមួយៗបានទទួលនោះ ដែលគោលការណ៍មួយនេះហៅថា គោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះ ម្ចាស់បំណុលនៃមតកជនមានសិទ្ធិអនុវត្តលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសន្តតិកម្ម តាមរយៈការហាមឃាត់មិនឱ្យសន្តតិជនផ្ទេរកម្មសិទ្ធិវាបាន ដោយម្ចាស់បំណុលអាចទាមទារឱ្យជ្រើសតាំងអ្នកគ្រប់គ្រងបណ្ដោះអាសន្នក្នុងការរក្សាគ្រប់គ្រងមតិកទាំងអស់នោះ លុះត្រាតែគ្មានអ្នកប្រតិបត្តិមតកសាសន៍ ក៏បញ្ជាក់ឱ្យឃើញបានដែលថា ម្ចាស់បំណុលគ្មានសិទ្ធិក្នុងការគ្រប់គ្រងផ្ទាល់ទៅលើមតិករបស់មតកជននោះទេ។

វិធានសម្របសម្រួលនេះ សំដៅការពារផលប្រយោជន៍របស់ម្ចាស់បំណុល ប៉ុន្តែប្រសិនបើសន្តតិជនបានបោះបង់សន្តតិកម្ម ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ដូចដែលបានរៀបរាប់ខាងលើនោះទេ ហើយសន្តតិជនក៏មិនអាចទទួលចំណែកមតិកបាននោះដែរ។ មួយវិញទៀត ក្នុងករណីសន្តតិជនបានយល់ព្រមដោយកម្រិត សន្តតិជនត្រូវជូនដំណឹងជាសាធារណៈ អំពីការយល់ព្រមដោយកម្រិតនេះទៅម្ចាស់បំណុលក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ដោយកំណត់ផងដែរនូវអំឡុងពេលជាក់លាក់មួយសម្រាប់ម្ចាស់បំណុលដាក់ពាក្យស្នើសុំ និងចាប់ផ្ដើមឱ្យមាននីតិវិធីជម្រះបញ្ជី[109] ដែលតម្រូវឱ្យសន្តតិជននោះ នឹងមានកាតព្វកិច្ចគ្រប់គ្រងមតិកឱ្យបានល្អ ព្រមទាំងនឹងបានទទួលចំណែកមតិកសកម្មដែលបាននៅសល់ក្រោយការជម្រះបញ្ជី [110] ។ ផ្ទុយទៅវិញ ក្នុងករណីមិនបានស្នើសុំនោះ ក្នុងអំឡុងពេលដែលបានកំណត់នោះទេ ម្ចាស់បំណុលនោះនឹងត្រូវបាត់បង់ផលប្រយោជន៍អំពីបំណុលរបស់ខ្លួន ព្រោះសន្តតិជនអាចមិនសងលើបំណុលនោះ ព្រោះខ្លួនមិនមានឈ្មោះក្នុងការជម្រះបញ្ជីនោះទេ [111] ។ គួរបញ្ជាក់ផងដែរថា ករណីខាងលើមិនមានប្រសិទ្ធភាព ទៅលើម្ចាស់បំណុលដែលបានភ្ជាប់សិទ្ធិប្រាតិភោគប្រត្យក្ស ដូចជា ហ៊ីប៉ូតែក ជាអាទិ៍។ ក្រោយពីអំឡុងពេលដែលបានដាក់នោះផុតកំណត់ហើយ សន្តតិជនដែលយល់ព្រមដោយកម្រិតនោះ មានកាតព្វកិច្ចសងឱ្យម្ចាស់បំណុលទាំងអស់ដែលខ្លួនបានដឹងលឺ តាមសមាមាត្រនៃចំណែកមតិកដែលខ្លួនបានទទួលធៀបនឹងបំណុលនោះ[112]។ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិអំពីម្ចាស់បំណុលដែលមានសិទ្ធិអាទិភាពមានលំដាប់ដូចខាងក្រោមនេះ៖

[109] មាត្រា ១២៨១ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[110] មាត្រា ១២៨០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[111] មាត្រា ១៣០៤ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[112] មាត្រា ១២៨៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ទី១ ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាព។ ទី២ ម្ចាស់បំណុលដែលបានដាក់ពាក្យស្នើសុំនៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ។ ទី៣ អច្ច័យលាភីដែលបានដាក់ពាក្យស្នើសុំនៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ។ ទី៤ ម្ចាស់បំណុល និងអច្ច័យលាភី ដែលមិនបានស្នើសុំនៅក្នុងអំឡុងពេលនៃការជូនដំណឹងជាសាធារណៈ[113]។

ក្នុងករណីដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មដោយកម្រិតហើយ វាបង្កើតឱ្យម្ចាស់បំណុលបង្កើតនូវសិទ្ធិទទួលបានសំណងក្នុងពេលដែលជម្រះបញ្ជីនោះ ទោះបីជាមិនទាន់ដល់ពេលកំណត់សងក៏ដោយ[114]។ ការសងបំណុលត្រូវធ្វើការសងទៅឱ្យម្ចាស់បំណុលមុននឹងសងទៅឱ្យអច្ច័យលាភី[115]។ ក្នុងករណីដែលតម្រូវឱ្យសងតាមរយៈការលក់មតិកដោយបង្ខំ ឬលក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែលត្រូវបានជ្រើសតាំងដោយតុលាការ ម្ចាស់បំណុល និងអច្ច័យលាភីមានសិទ្ធិក្នុងការទិញមតិកនោះ[116]។ បើក្នុងករណី សន្តតិជនជាច្រើនបានយល់ព្រមដោយមានកម្រិតចំពោះសន្តតិកម្មនោះ វាជាតួនាទីរបស់តុលាការ ក្នុងការជ្រើសតាំងសន្តតិជនម្នាក់ក្នុងចំណោមអ្នកទាំងនោះជាអ្នកគ្រប់គ្រងចំណែកមតិក ដោយរួមទាំងការសងបំណុលក្នុងជាផលប្រយោជន៍របស់ខ្លួនឯង និងសន្តតិជនទាំងអស់ផងដែរ[117]។

## ៣.៣ អំពីស្ថានភាពពិសេសនៃសន្តតិកម្មតាមច្បាប់

ក្នុងករណីមួយចំនួន សន្តតិកម្មខ្លះគ្មានសន្តតិជននោះទេ ដែលនាំឱ្យត្រូវការស្វែងរកសន្តតិជនមកស្នងមតិកទាំងអស់នោះ និងករណីមួយផ្សេងទៀតនោះ គឺគ្មានសន្តតិជនតែម្តង ដែលធ្វើឱ្យមតិកទាំងអស់ធ្លាក់ទៅលើជនមាននិស្ស័យពិសេស (នត្ថិភាពនៃសន្តតិជន) ដែលសិក្សាក្នុងចំណុច ៣.៣.១។ ជាងនេះទៅទៀត ប្រសិនជាមានជនដទៃដែលហាក់ដូចជាសន្តតិជន ហើយបានទទួលមតិករួច តែគ្មានមូលហេតុគតិយុត្តណាមួយក្នុងការទទួលសន្តតិកម្មនោះទេ ដែលនាំឱ្យសន្តតិជនទាមទារឱ្យធ្វើបដិទានសន្តតិកម្មមកវិញ ដែលសិក្សាក្នុងចំណុច ៣.៣.២ ករណីខាងអស់ខាងលើនេះ គេហៅថាស្ថានភាពពិសេសនៃសន្តតិកម្ម។

### ៣.៣.១ អំពីនត្ថិភាពនៃសន្តតិជន

#### ៣.៣.១.១ នីតិបុគ្គលមតិក

ដោយសារគ្មានសន្តតិជនក្នុងការទទួលមតិកនោះទេ នាំឱ្យម្ចាស់បំណុលមានការលំបាកក្នុងការទាមទារមកវិញនូវបំណុលនោះ ធ្វើឱ្យម្ចាស់បំណុលត្រូវចាត់ទុកមតិកជានីតិបុគ្គល ដែលដើរតួជា

[113] មាត្រា ១២៨៣ វាក្យខណ្ឌទី ២ និងមាត្រា ១២៨៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[114] មាត្រា ១២៨៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[115] មាត្រា ១២៨៥ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[116] មាត្រា ១២៨៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[117] មាត្រា ១២៨៩ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

ប្រធាននៃសិទ្ធិ និងកាតព្វកិច្ចក្នុងសន្តតិកម្មនេះ ក្នុងការសងបំណុលក្នុងនីតិវិធីជម្រះបញ្ជី[118]។ នីតិបុគ្គលនេះត្រូវមានអ្នកគ្រប់គ្រងជាដាច់ខាត ដែលអាចត្រូវបានជ្រើសរើស តាមការស្នើសុំទៅតុលាការដោយអ្នកមានផលប្រយោជន៍ពាក់ព័ន្ធនឹងវា មេឃុំ ចៅសង្កាត់នៃលំនៅឋានចុងក្រោយរបស់មតកជន ឬតំណាងអយ្យការ[119]។ តុលាការត្រូវធ្វើការជ្រើសតាំង អ្នកគ្រប់គ្រងមតិកនៃនីតិបុគ្គលនោះ បើគិតចាប់ពីពេលបើកសន្តតិកម្មហើយ ២ (ពីរ) ខែយ៉ាងតិច នៅតែមិនបានដឹងថាមានសន្តតិជនក្នុងការស្នងមតិក[120]។ ក្នុងករណីដែលអំឡុងពេលឱ្យប្រកាសជាសាធារណៈក្នុងការរកសន្តតិជនដែលមានថេរវេលាយ៉ាងតិច ៦ (ប្រាំមួយ) ខែហើយគិតចាប់ពីជ្រើសតាំងអ្នកគ្រប់គ្រង មិនមានសន្តតិជនមកទទួលសិទ្ធិទៀត សន្តតិជនទាំងអស់នោះនឹងត្រូវបានបាត់បង់សិទ្ធិនោះ ហើយអ្នកគ្រប់គ្រងមានកាតព្វកិច្ចសងបំណុល និងបែងចែកមតិកទៅឱ្យជនដែលមាននិស្ស័យពិសេស ឬឱ្យក្លាយទៅជាសម្បត្តិរដ្ឋ[121]។ មួយវិញទៀត ប្រសិនបើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មហើយ អ្នកគ្រប់គ្រងក៏អស់កាតព្វកិច្ចផងដែរ ដោយសារកាតព្វកិច្ចខាងលើត្រូវបានផ្ទេរទៅឱ្យសន្តតិជនរូបនោះហើយ[122]។

### ៣.៣.១.២ ចំណែកចំពោះជនដែលមាននិស្ស័យពិសេស

ជនដែលមានជីវភាពរស់នៅជាមួយមតកជន ជនដែលបានខិតខំមើលថែ ព្យាបាលមតកជន ត្រូវចាត់ទុកថាជាជនមាននិស្ស័យពិសេស ទោះបីជាគ្មានទំនាក់ទំនងញាតិជាមួយមតកជនក៏ដោយ។ ក្នុងករណីអ្នកដែលជាជនមាននិស្ស័យពិសេសចង់បែងចែកចំណែកមតិក ជននោះត្រូវធ្វើការស្នើសុំទៅតុលាការ ទាមទារចំណែកមតិកដែលមិនលើសពីពាក់កណ្តាលនៃចំណែកមតិកទាំងអស់ក្រោយពីជម្រះបញ្ជីនោះទេ[123]។ ថេរវេលានៃការស្នើសុំរបស់ជនដែលមាននិស្ស័យពិសេសគឺ៣ (បី) ខែគិតចាប់ពីពេលស្វែងរកសន្តតិជនបានផុតទៅ[124]។

### ៣.៣.១.៣ មតិកដែលក្លាយជារបស់រដ្ឋ

ចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃសន្តតិកម្ម ហើយពុំមានសន្តតិជនស្នងលើអចលនវត្ថុនោះទេ វានឹងក្លាយជាសម្បត្តិរបស់រដ្ឋ ចំណែកមតិកសល់ពីការបែងចែកទៅឱ្យជនដែលមាននិស្ស័យពិសេស នឹងក្លាយជារបស់រដ្ឋផងដែរ[125]។

---

[118] មាត្រា ១២៩០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[119] មាត្រា ១២៩១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[120] មាត្រា ១២៩៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[121] មាត្រា ១២៩៩ និងមាត្រា ១៣០០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[122] មាត្រា ១២៩៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[123] មាត្រា ១២៩៩ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[124] មាត្រា ១២៩៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[125] មាត្រា ១៣០០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

### ៣.៣.២ អំពីបដិទាននៃសន្តតិកម្ម

បដិទានសន្តតិកម្ម សំដៅលើការទាមទារមួយដែលជាសិទ្ធិរបស់សន្តតិជនពិតប្រាកដ ធ្វើការទាមទារចំណែកមត៌កនៃសន្តតិកម្ម ពីបុគ្គលដែលត្រូវបានគេយល់ឃើញថាជាសន្តតិជន តែការពិតពុំមែនជារបស់សន្តតិជនពិតប្រាកដនោះទេ ដូច្នេះសន្តតិជនពិតប្រាកដអាចទាមទារឱ្យជននោះប្រគល់ចំណែកមត៌កនៃសន្តតិកម្មនោះមកវិញ[126]។ ស្ថានភាពនៃបដិទានសន្តតិកម្មនេះ អាចកើតឡើងដោយៈ

ទី១ តាមរយៈសំបុត្រកំណើត អាចជាការក្លែងបន្លំ ឬការធ្វេសប្រហែស នាំឱ្យបុគ្គលដែលមិនមែនជាកូនរបស់មតកជន ហើយមានឈ្មោះក្នុងសំបុត្រកំណើតនោះអាចទទួលបានចំណែកមត៌កនៃសន្តតិកម្មនោះបាន។

ទី២ មតកជនមានកូនជាមួយអ្នកផ្សេង ប៉ុន្តែមិនមានទំនាក់ទំនងគ្នាជាយូរហើយ ហើយបែរជាមានសន្តតិកម្មតែក្នុងរង្វង់គ្រួសារថ្មីនោះធ្វើឱ្យកូនខាងលើមានសិទ្ធិក្នុងការទាមទារធ្វើបដិទាននៃសន្តតិកម្មនោះ។

ទី៣ សន្តតិជនណាមួយបានទទួលចំណែកមត៌កលើសពីចំណែកដែលខ្លួនត្រូវទទួលបាន។ ជាគោលការណ៍ ក្នុងករណីដែលជនដែលមិនមែនជាសន្តតិជនបានទទួល ចំណែកមត៌កនៃសន្តតិកម្ម ហើយធ្វើការលក់ទ្រព្យនោះទៅឱ្យតតិយជនបាត់ហើយ សន្តតិជនពិតប្រាកដមានសិទ្ធិទាមទារបាន ប៉ុន្តែមិនមែនទាមទារឱ្យជនមិនមានសិទ្ធិនោះ ឬអ្នកទិញធ្វើបដិទានទ្រព្យនោះមកវិញទេ គឺអាចទាមទារបានតែថ្លៃលក់នៃទ្រព្យនោះមកវិញប៉ុណ្ណោះ[127]។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទិញមានបំណងទុច្ចរិត ឬមានកំហុសដោយបានដឹងហើយថា ជនដែលជាអ្នកលក់នោះមិនមានសិទ្ធិជាសន្តតិជននោះទេ តែនៅតែធ្វើការទិញពីជននោះទៀត សន្តតិជនពិតប្រាកដអាចធ្វើការទាមទារទ្រព្យទាំងនោះមកវិញបាន[128]។ ជនដែលមិនមានសិទ្ធិជាសន្តតិជននោះ ត្រូវធ្វើការប្រគល់មកវិញនូវទ្រព្យដែលជាកម្មវត្ថុនៃសន្តតិកម្មទៅឱ្យសន្តតិជនពិតប្រាកដវិញ ដោយប្រគល់ទាំងផល និងការប្រាក់ដែលបានទទួលពីទ្រព្យនោះ និងមិនអាចទាមទារសំណង និងសោហ៊ុយបង្កើតតម្លៃនៃទ្រព្យនោះបានទេ បើជននោះជាបុគ្គលទុច្ចរិត[129]។ ផ្ទុយទៅវិញ ក្នុងករណីដែលជនមិនមានសិទ្ធិនោះជាបុគ្គលសុចរិតវិញ ផល ឬការប្រាក់ដែលកើតចេញពីទ្រព្យនោះនឹងធ្លាក់ទៅជារបស់បុគ្គលនោះ មិនត្រឹមតែប៉ុណ្ណោះ បុគ្គលនោះនៅមានសិទ្ធិទាមទារឱ្យសន្តតិជនសងសោហ៊ុយដែលបានបង្កើនតម្លៃនៃទ្រព្យ

[126] មាត្រា ១៣០២ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[127] មាត្រា ១៣០៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[128] មាត្រា ១៣០៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧
[129] មាត្រា ១៣០៣ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

នោះ និងសំណងទៅលើកាតព្វកិច្ចដែលខ្លួនបានសងតាមសន្តតិកម្មនោះ[130]។ ការទាមទារខាងលើមានអំឡុងពេល៥ (ប្រាំ) ឆ្នាំគិតចាប់ពីពេលដែលបានផ្ទេរនោះ សម្រាប់ឱ្យសន្តតិជនពិតប្រាកដធ្វើការទាមទារ បើចំណែកមត៌កនៃសន្តតិកម្មនោះបានផ្ទេរទៅឱ្យជនគ្មានសិទ្ធិនោះតាមមតកសាសន៍ ឬការបែងចែកមត៌ក ប៉ុន្តែ បើជាក្នុងករណីដែលជនដែលគ្មានសិទ្ធិតែម្នាក់ទទួលសន្តតិកម្មក្នុងនាមជាសន្តតិជនវិញ អំឡុងពេលនៃការទាមទារក៏មាន៥ (ប្រាំ) ឆ្នាំដែរ តែគិតចាប់ពីពេលដែលមតកជនបានទទួលមរណភាពទៅវិញ[131]។

130 មាត្រា ១៣០៣ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

131 មាត្រា ១៣០៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ដែលយើងបានសិក្សាខាងដើមនេះ បានបញ្ញត្តិយ៉ាងលម្អិតចំពោះសន្តតិកម្មតាមច្បាប់ ធ្វើឱ្យការអនុវត្តទាក់ទងនឹងផ្នែកនេះមានលក្ខណៈងាយស្រួល និងមានប្រសិទ្ធភាព។ ទោះបីជាក្រមរដ្ឋប្បវេណីបានបញ្ញត្តិទាំងសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍យ៉ាងណាក្តី ប៉ុន្តែក្នុងវិសាលភាពនៃប្រធាននេះ យើងសិក្សាទៅលើតែសន្តតិកម្មតាមច្បាប់តែប៉ុណ្ណោះ។ ក្នុងន័យសន្តតិកម្មតាមច្បាប់ គឺសំដៅនូវការផ្ទេរទ្រព្យសម្បត្តិ(មតិក)របស់អ្នកស្លាប់(មតកជន) ទៅឱ្យអ្នកស្នងមតិក(សន្តតិជន)ម្នាក់ ឬច្រើននាក់ដោយអនុលោមតាមច្បាប់ដែលបានកំណត់ទុកជាមុនជាស្រេច ដោយខុសពីសន្តតិកម្មតាមមតកសាសន៍ត្រង់ការអនុវត្តសន្តតិកម្មតាមច្បាប់ទៅបាន ព្រោះគ្មានមតកសាសន៍ ឬមតកសាសន៍គ្មានសុពលភាពក្នុងការអនុវត្ត។

ក្នុងសង្គមជាក់ស្តែង ដោយសារកង្វះការយល់ដឹងផ្នែកនេះបានធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនមានទំនាស់ក្នុងការចែកមតិករបស់មតកជន ជាហេតុបណ្តាលឱ្យកើតជារឿងទំនាស់គ្រួសារថែមទៀត ព្រោះតែសន្តតិជនម្នាក់ៗតែងចង់ទទួលបានចំណែកមតិករបស់ខ្លួនកាន់តែច្រើនកាន់តែល្អ។ អាស្រ័យហេតុនេះ សន្តតិកម្មតាមច្បាប់នេះបានដើរតួនាទីយ៉ាងមានប្រសិទ្ធភាពក្នុងការការពារផលប្រយោជន៍របស់សន្តតិជន ក៏ដូចជាធ្វើឱ្យប្រទេសជាតិមានស្ថេរភាពផងដែរ។

ម្យ៉ាងវិញទៀត សន្តតិកម្មដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីនេះ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទរឿងក្តីស្នងមតិក ព្រោះរឿងកើត ចាស់ ឈឺ និងស្លាប់គឺជារឿងដែលមនុស្សម្នាក់ៗត្រូវឆ្លងកាត់ ហើយបើកាលណាមានការស្លាប់ រឿងសន្តតិកម្មគឺត្រូវតែចូលមកពាក់ព័ន្ធជាដាច់ខាត។ អាស្រ័យហេតុនេះ ប្រជាពលរដ្ឋទាំងឡាយគប្បីធ្វើការស្វែងយល់អំពីវាឱ្យបានច្រើនដើម្បីទុកជាប្រយោជន៍ទៅថ្ងៃមុខ។

ទោះបីជាយ៉ាងនេះក្តី ការតាក់តែងច្បាប់នីមួយៗមិនអាចបំពេញតម្រូវការ និងសមស្របតាមបរិបទនៃការអនុវត្តល្អឥតខ្ចោះនោះទេ ទោះបីជាការតាក់តែងនោះមានភាពល្អយ៉ាងណាក្តីនាពេលតាក់តែងនោះ ក៏មិនមានន័យថា ការអនុវត្តរបស់វាមានប្រសិទ្ធភាពគ្រប់ពេលវេលា និងកាលៈទេសៈនោះដែរ ព្រោះតែបរិបទសង្គមតែងតែមានការអភិវឌ្ឍន៍ទៅមុខជានិច្ច ធ្វើឱ្យការតាក់តែងច្បាប់ក៏ត្រូវទាមទារឱ្យមានការអភិវឌ្ឍន៍ឱ្យទាន់សង្គមផងដែរ។

សរុបរួមមក សន្តតិកម្មតាមច្បាប់នេះបានជួយធ្វើឱ្យការបែងចែក ក៏ដូចជាការគ្រប់គ្រងមតិករបស់មតកជនមានសមភាព និងយុត្តិធម៌ ដោយធ្វើឱ្យវិវាទទាក់ទងនឹងសន្តតិកម្មមានការថយចុះ ដើម្បីឱ្យប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលផ្តោតសំខាន់ទៅលើការអភិវឌ្ឍន៍ប្រទេសជាតិយើងឱ្យកាន់តែមានភាពរីកចម្រើន និងរុងរឿងបន្ថែមទៀត។ ជាការពិតណាស់ ចំនុចសំខាន់ពិតប្រាកដនោះ

នូវតែជាការចូលរួមចំណែករបស់ប្រជាពលរដ្ឋដដែល ដូច្នេះក្នុងកិត្តិយសជាកូនខ្មែរទាំងអស់គ្នា គប្បីស្វែងយល់អំពីផ្នែកនេះទុកជាចំណេះដឹង និងផលប្រយោជន៍នាពេលខាងមុខ៕

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីយើងខ្ញុំបានបកស្រាយនូវប្រធានបទខាងលើរួចមកហើយ យើងអាចសន្និដ្ឋានបាន ថាបញ្ញត្តិមាត្រាទាំងឡាយដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការយកមកអនុវត្តជាក់ស្តែង ក្នុងព្រះរាជាណាចក្រកម្ពុជានាពេលនេះ ប៉ុន្តែប្រសិនបើក្រឡេកមើលអនាគតវិញ សង្គមនឹងមានការផ្លាស់ប្តូរបរិបទយ៉ាងច្រើនទៅមុខទៀត ជាហេតុដែលតម្រូវឱ្យមានការកែតម្រូវច្បាប់ និងបទបញ្ញត្តិនានាឱ្យមានភាពសមស្របនឹងការវិវឌ្ឍរបស់សង្គម។

ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ យើងខ្ញុំសូមចូលរួមជាយោបល់ និងអនុសាសន៍មួយចំនួនដូចខាងក្រោមដើម្បីចូលរួមជាចំណែកមួយ ក្នុងការធ្វើឱ្យប្រសើរឡើងនូវសន្តិកម្ម នៃប្រទេសកម្ពុជា។ យើងខ្ញុំ សូមឱ្យស្ថាប័នផ្សេងៗដែលទាក់ទងទៅនឹងវិស័យច្បាប់ ជាពិសេសស្ថាប័ននីតិបញ្ញត្តិ ពិនិត្យ និងអនុម័តនូវច្បាប់ ដើម្បីឱ្យតាមទាន់នូវការវិវឌ្ឍប្រែប្រួលនៃសង្គម។ ជាពិសេសទៅទៀតគឺយើងសូមធ្វើការអំពាវនាវដល់អាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ រួមទាំងរាជរដ្ឋាភិបាលធ្វើការផ្សព្វផ្សាយនូវបទបញ្ញត្តិច្បាប់ផ្សេងៗជាពិសេសទាក់ទងនឹងសន្តិកម្ម ដើម្បីឱ្យប្រជាពលរដ្ឋមានការជ្រួតជ្រាបនិងយល់ដឹងក្នុងន័យចូលរួមកាត់បន្ថយ និងលុបបំបាត់ចោលនូវទំនាស់ផ្សេងៗនៅក្នុងសង្គមគ្រួសាររួមទាំងសង្គមជាតិ ដោយហេតុថាសង្គមដែលមានការអភិវឌ្ឍគឺអាស្រ័យទៅលើចំណេះដឹង និងការអនុវត្តរបស់ប្រជាជន។ ម៉្យាងវិញទៀត ប្រជាពលរដ្ឋទៀតសោតក៏ត្រូវស្វែងយល់នូវព័ត៌មានផ្សេងៗទាក់ទងនឹងបញ្ញត្តិច្បាប់ ដើម្បីជាការយល់ដឹងមុននឹងសម្រេចចិត្តប្តឹងផ្តល់គ្នា ជាពិសេសក្នុងរង្វង់គ្រួសារខ្លួន ដើម្បីតែទទួលបាននូវមតិកតែប៉ុណ្ណោះ ដោយគ្មានការយោគយល់ អធ្យាស្រ័យគ្នាក្នុងរង្វង់គ្រួសាររបស់ខ្លួន។

ត្បិតតែអនុសាសន៍ខាងលើមានភាពមិនគ្រប់គ្រាន់ និងស៊ីជម្រៅក៏ដោយ ក៏វាអាចជាកត្តាមួយជួយជម្រុញដល់ ការចូលរួមកាត់បន្ថយនូវវិវាទផ្សេងៗ ដែលទាក់ទងទៅនឹងការបែងចែកមតិករបស់មតកជន រួមទាំងធ្វើឱ្យមានភាពសុខសាន្ត និងសុខដុមរមនានៅក្នុងសង្គមគ្រួសារ និងសង្គមជាតិផងដែរ។

# ឯកសារយោង

# ឯកសារយោង

I. **ច្បាប់ និងបទបញ្ញត្តិ**

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។

២. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

៣. អនុក្រឹត្យលេខ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០

II. **សៀវភៅ**

១. សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគ៦: គន្ថីទី៨-គន្ថីទី៩ រៀបចំដោយក្រុមការងារជប៉ុន ដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១០។

២. សៀវភៅសន្តតិកម្ម រៀបរៀងដោយ មេធាវី "**អ៊ីវ ប៉ូលី**" ឆ្នាំ២០១០។

៣. សៀវភៅ នីតិគ្រួសារ រៀបរៀងដោយ សាស្ត្រាចារ្យ "**រុន ពណ្ណារិទ្ធ**" និងសាស្ត្រាចារ្យ "**ចាំង ស៊ីណាត**" ឆ្នាំ២០១៧។

៤. នីតិគ្រួសារ និងអាពាហ៍ពិពាហ៍ ភាគ២ រៀបរៀងដោយ លោក "**ឥន យឿន**" ឆ្នាំ២០១៣។

៥. នីតិសន្តតិកម្ម រៀបរៀងដោយ សាស្ត្រាចារ្យ "**ជ័យ រិទ្ធី**"។

# ឧបសម្ព័ន្ធ

# ដីកាសម្រេច

# សេចក្តីសម្រេច
# របស់
# តុលាការ

# គំរូសេចក្ដីសម្រេច
# របស់
# តុលាការ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

**សំណុំរឿងរដ្ឋប្បវេណី**

លេខ

ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៨

**សាលដីកា**

លេខ: ក្រVII(ធ)

ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៩

ក្រុមប្រឹក្សាទីVII នៃសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ បានបញ្ចប់ការទាញ ហេតុផលដោយផ្ទាល់មាត់នារសៀលថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៩ ដែលមាន:

**<u>សមាសភាពក្រុមប្រឹក្សា</u>**

| | |
|---|---|
| លោក | ជាប្រធានក្រុមប្រឹក្សា |
| លោក | ជាចៅក្រមប្រឹក្សា |
| លោក | ជាចៅក្រមប្រឹក្សា |

**<u>ក្រឡាបញ្ជី</u>**

លោក

**១-អត្តសញ្ញាណគូភាគី**

**<u>សហដើមចោទ:</u>**

១-ឈ្មោះ ............. ភេទប្រុស អាយុ៥៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ២០៧ ផ្លូវវត្តចាស់ ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ជា(ចុងបណ្តឹងឧទ្ធរណ៍)

២-ឈ្មោះ ............. ភេទប្រុស អាយុ៥៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ២០៧ ផ្លូវវត្តចាស់ ភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ជា(ចុងបណ្តឹងឧទ្ធរណ៍)

មានមេធាវី ............. ជាអ្នកតំណាងដោយអាណត្តិ។

**<u>សហចុងចម្លើយ:</u>**

១-ឈ្មោះ ............. ភេទស្រី សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ២ ក្រុមទី១៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

២-ឈ្មោះ ............ ............ ហៅ ............ ភេទស្រី អាយុ៦៦ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ២៤ ផ្លូវវត្តចាស់ ភូមិ២ ក្រុមទី១៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

៣-ឈ្មោះ ............ ភេទប្រុស អាយុ៥៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ២ ក្រុមទី១៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

៤-ឈ្មោះ ............ ភេទស្រី អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៦៣ ផ្លូវវត្តចាស់ភូមិ២ ក្រុមទី១៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

៥-ឈ្មោះ ............ ភេទស្រី អាយុ៦៣ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ៦៧ ផ្លូវលេខ១៥ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ជា(ដើមបណ្តឹងឧទ្ធរណ៍)

មេធាវី ............ ជាអ្នកតំណាងដោយអាណត្តិ។

## ២-ខ្លឹមសារសាលក្រមដែលដើមចោទប្តឹងទាមទារ:

១-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ២៤១ ល.ប ចុះថ្ងៃទី០៨-៩-២០១៤ របស់ចៅសង្កាត់ជ្រោយចង្វារ ទុកជាត្រឹមត្រូវ។

២-ចុះបញ្ជីផ្ទេរកម្មសិទ្ធិដី ដែលមានទីតាំងស្ថិតនៅឡូត៍លេខ៦៣A ផ្លូវវត្តចាស់ ក្រុមទី១៣ ភូមិ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ពីឈ្មោះ ............, ឈ្មោះ ............ ............, ឈ្មោះ ............, ឈ្មោះ ............ និងឈ្មោះ ............(ជាសន្តតិជនរបស់អ្នកលក់ឈ្មោះ ............) ឲ្យទៅដើមចោទឈ្មោះ ............ និងឈ្មោះ ............។

៣-បង្គាប់មកស្ថាប័នមានសមត្ថកិច្ច ឲ្យចុះបញ្ជីកម្មសិទ្ធិលើដីដែលមានទីតាំងស្ថិតនៅឡូត៍លេខ ៦៣A ផ្លូវវត្តចាស់ ក្រុមទី១៣ ភូមិ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឲ្យទៅដើមចោទឈ្មោះ ............ និងឈ្មោះ ............។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## <u>អង្គហេតុ និងចំណុចវិវាទ:</u>

កាលពីថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១៤ ភាគីដើមចោទបានទិញដីទំហំ ១.៣០៨,៣៦ម៉ែត្រក្រឡា ពីឈ្មោះ ............ ភេទស្រី អាយុ៩៤ឆ្នាំ មានព្រំប្រទល់ខាងជើងទល់នឹងតា ............ ខាងត្បូងទល់នឹង ផ្លូវវត្តចាស់ ខាងកើតទល់នឹង ............ ខាងលិចទល់នឹង ............ មានទីតាំង

ស្ថិតនៅឡូតិ៍លេខ៦៣A ផ្លូវវត្តចាស់ ក្រុមទី១៣ ភូមិ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដោយមានសាក្សីលោក ............ ជាមេភូមិ និងអាជ្ញាធរសង្កាត់ដឹងឮផង។ ក្នុងដំណាក់កាលនៃការទិញលក់នេះ ឈ្មោះ ............ តាម រយៈកូន១បានទទួលប្រាក់ពីដើមចោទចំនួន ៤០.០០០(បួនម៉ឺន)ដុល្លាអាមេរិក ប៉ុន្តែការទិញលក់នៅពេលនេះធ្វើឡើងត្រឹមសមត្ថកិច្ចអាជ្ញាធរសង្កាត់ជ្រោយចង្វារ មិនទាន់ធ្វើការផ្ទេរកម្មសិទ្ធិដល់អាជ្ញាធរសាលាខណ្ឌជ្រោយចង្វារ ឬនៅចំពោះមុខមន្ត្រីជំនាញសុរិយោដីទេ ស្រាប់តែឈ្មោះ ............ ជាភាគីអ្នកលក់បានទទួលមរណៈភាព ធ្វើឲ្យការផ្ទេរកម្មសិទ្ធិនេះ មិនទាន់បញ្ចប់ពេញលេញនៅឡើយទេ។ ដូច្នេះដើម្បីបានភាពស្របច្បាប់ពេញលេញ គឺចាំបាច់ត្រូវមានការសម្រេចពីតុលាការ។ ដោយសារតែភាគីឈ្មោះ ............ (អ្នកលក់)មានកូនចំនួន ០៥នាក់ជាសន្តតិជន ដូច្នេះសូមជ្រើសរើសពួកគេជាសហចុងចម្លើយក្នុងសំណុំរឿងនេះ។

សាលាដំបូងរាជធានីភ្នំពេញ បានសំរេចសេចក្តីតាមអំណាចសាលក្រមលេខ ២០១២“ធ” ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានខ្លឹមសារសម្រេចដូចតទៅ:

១-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី និងផ្ទះសម្បែងលេខ ២៤១ ល.ប ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ របស់ចៅសង្កាត់ជ្រោយចង្វារ ទុកជាត្រឹមត្រូវតាមច្បាប់។

២-បង្គាប់ឲ្យសហដើមចោទឈ្មោះ ............ និងឈ្មោះ ............ បង់ប្រាក់បង្គ្រប់ថ្លៃដីចំនួន ១១០.០០០(ដប់មួយម៉ឺន)ដុល្លាសហរដ្ឋអាមេរិក ឲ្យទៅសហចុងចម្លើយឈ្មោះ, ............ ហៅ ............, ............, ............ និងឈ្មោះ ............(ជាសន្តតិជនរបស់អ្នកលក់ឈ្មោះ ............) តាមកិច្ចសន្យាលក់ដីមិនកែប្រែ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ ចាប់ពីពេលដែលសាលក្រមចូលជាស្ថាពរ។

៣-លើកចោលការស្នើសុំត្រង់ចំណុចទី២ និងទី៣។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

-បានឃើញ សេចក្តីចម្លងនៃលិខិតបណ្តឹងឧទ្ធរណ៍លេខ ១៧៨ ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៧របស់ឈ្មោះ ............ ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ២០១២“ធ” ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

**-បានឃើញ** របាយការណ៍រឿងរដ្ឋប្បវេណីចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

បានឃើញ សេចក្តីថ្លែងការណ៍របស់មេធាវី ............ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១៩។

## នាពេលទាញហេតុផលដោយផ្ទាល់មាត់

## ប្រធានក្រុមប្រឹក្សាអានរបាយការណ៍រឿងសង្ខេប

-មេធាវី ............ ជាអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយឈ្មោះ ............ ធ្វើសេចក្តីថ្លែងការណ៍ នៅក្នុងរឿងនេះដូចលោកប្រធានក្រុមប្រឹក្សាលើកឡើងនូវអង្គហេតុនេះហើយ ហើយខ្លួនក៏មិនចាំ បាច់លើកឡើងអំពីអង្គហេតុនេះដដែល ដោយសារមានសេចក្តីថ្លែងការណ៍ក៏ដូចជាសំណុំរឿងនៅក្នុងសំណុំរឿងតាំងពីសាលាដំបូងរហូតមកដល់សាលាឧទ្ធរណ៍នេះតែម្តង ដោយឡែកវត្តមានរបស់សហចុងចម្លើយ ៣នាក់ដែលកំពុងអង្គុយនេះតាមពិតទៅគាត់មិនបានប្តឹងឧទ្ធរណ៍ទេ ប្តឹងឧទ្ធរណ៍តែកូនក្តីខ្លួនទេ ហើយសូមជម្រាបជូនលោកចៅក្រមថា នៅក្នុងក្រុមគ្រួសារនេះមិនមែនមានតែកូនប៉ុណ្ណឹងទេ លោកស្រីខាងនោះក៏ជាកូនបង្កើតដែរ ប៉ុន្តែគាត់ធ្លាប់ធ្វើលិខិតបំភ្លឺជូនតុលាការពាក់ព័ន្ធនឹងដីនេះគឺជាដីរបស់កូនក្តីខ្លួន លោកស្រីខាងនោះគឺជាវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យបង្អែកក្រុងភ្នំពេញ ដែលគាត់មិនបានចូលរួមនៅក្នុងភាគីនេះទេ។ នេះមានន័យថា មិនមែនកូនទាំងអស់គឺឯកភាពថា ដីនោះជាដីរបស់ម្តាយទេ នៅមានកូនមួយចំនួនទៀត ឈ្មោះ ............ ក៏ឯកភាពថា ជាដីរបស់កូនក្តីខ្លួន លោកស្រីអង្គុយនៅទីនេះក៏ឯកភាពថា ជាដីរបស់កូនក្តីខ្លួនលើកលែងតែកូន០២នាក់ទេ គឺកូនប្រសារប្រពន្ធរបស់ឈ្មោះ ............ ឈ្មោះ ............ ហើយការពិតមិនទាន់មានការប្រកាសអំពីដែលគេហៅថា ការទទួលតួនាទីទៀតទេ ឈ្មោះ ............ បានស្លាប់ដោយ សារសម្បថ មានកូន០១នៅខាងក្រៅសាលសវនាការ ហើយមិនទទួលស្គាល់កូនបង្កើតជិះបុកដើមដូងស្លាប់ ហើយមកយកគាត់ក្រោយ នេះជាចំណុចសំខាន់។ ចំណុចដែលកូនក្តីខ្លួនបានប្តឹងឧទ្ធរណ៍នៅក្នុងសំណុំរឿងនេះ ដោយសារទី១ សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ គាត់បានសម្រេចដោយមិនបានពិនិត្យទៅលើអង្គហេតុឲ្យបានគ្រប់ជ្រុងជ្រោយ ព្រោះថា យោងតាមពាក្យសុំជូនពិនិត្យភស្តុតាងរបស់មេធាវី ... ដែលតំណាងឲ្យកូនក្តីរបស់ខ្លួនកាលពីសាលាដំបូងឈ្មោះ ............ នោះ គឺគាត់បានបញ្ចូល ភស្តុតាងជាបង្កាន់ដៃកាន់កាប់ដែលមាន

ឈ្មោះ ............ ហើយការសុំជូនពិនិត្យភស្តុតាងគឺចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៥ គឺកំពុងស្ថិតនៅក្នុងសមត្ថកិច្ចនៃសំណុំរឿងរដ្ឋប្បវេណី របស់សាលាដំបូងរាជធានីភ្នំពេញដែរ។ ប៉ុន្តែនៅក្នុងសាលក្រម តុលាការពុំបានពិចារណាទៅលើភស្តុតាងនោះទេ ហើយភស្តុតាងនេះគឺជា ភស្តុតាងថ្មីដែលទើបតែបានរកឃើញបង្កាន់ដៃ ព្រោះថា នៅក្នុងសំណុំរឿងនោះសហចុងចម្លើយឈ្មោះ ............ គឺជាសាក្សីរស់ ហើយក៏ធ្លាប់បានធ្វើការបំភ្លឺនៅក្នុងកំណត់ហេតុត្រៀម កាលដែលនៅសាលាដំបូងដែលបញ្ជាក់ថា ពីដើមគាត់ស្មានតែដីនេះជាដីរបស់ម្តាយឈ្មោះ ............ ប៉ុន្តែពេលក្រោយដែលម្តាយស្លាប់នោះ គឺគេគាស់ទូររកឃើញមានបង្កាន់ដៃឈ្មោះ ............ បន្ទាប់មកទៀតបងប្អូនគាត់មានឈ្មោះ ............ នេះគឺបានឲ្យគាត់ដុតចោលដើម្បីបំផ្លាញភស្តុតាង គឺបំបាត់ភស្តុតាងតាំងពីនោះ មក។ ទាក់ទងនឹងរឿងនេះមានសំណុំរឿងមួយទៀតនៅសាលាដំបូងរាជធានីភ្នំពេញ គឺឈ្មោះ ............ កូនក្តីខ្លួនបានប្តឹងសុំបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិម្តងហើយនៅសាលាដំបូង តាំងពីឆ្នាំ២០១២ ហើយមកដល់ពេលនេះមិនទាន់សម្រេចចេញជាសាលក្រមនៅឡើយទេ នីតិវិធីត្រៀមមកដល់ពេលនេះឆ្នាំ២០១២ មកដល់ ឆ្នាំ២០១៩ វា ០៧ឆ្នាំហើយ បញ្ជាក់អត្ថិភាពនៃសិទ្ធិរបស់គាត់មិនទាន់ចេញបានទេ។ អ៊ីចឹងកូនក្តីខ្លួនបានដាក់ពាក្យស្នើសុំទៅសុរិយោដី ។ គេបានបញ្ជាក់ថា បង្កាន់ដៃឈ្មោះ ............ លេខ ១៧៩៤ ពិតជាមានតម្កល់នៅការិយាល័យសុរិយោដីខណ្ឌឫស្សីកែវពិតប្រាកដមែន។ ដូច្នេះហើយបានជាខ្លួនស្នើសុំមកតុលាការនៅក្នុងសេចក្តីថ្លែងការណ៍របស់ខ្លួន សុំបង្វិលសំណុំរឿងនេះទៅវិញដោយសារថា សាលាដំបូងគាត់ពិចារណាទៅលើលិខិតបញ្ជាក់របស់លោកមេភូមិដែលបញ្ជាក់ថា លោកស្រី ............ គឺជាម្ចាស់សិទ្ធិនៃដីនោះ ហើយព្រមលក់ទៅឲ្យទៅខាងដើមចោទ។ អ៊ីចឹងក្រោយពីឃើញថា មានភស្តុតាងបង្កាន់ដៃយើងឃើញថា ការលក់ដីរបស់លោកស្រី ............ គឺមិនមែនយកដីខ្លួនឯងទៅលក់ទេគឺយកដីកូនឈ្មោះ ............ ទៅលក់ឲ្យអ្នកដទៃ អ៊ីចឹងវាស្មើនឹងការយកដីអ្នកដទៃទៅលក់ឱ្យតតិយជនដែរ ដូច្នេះតាមច្បាប់មិនទទួលស្គាល់ទេ។ ហើយសាលាដំបូងទទួលស្គាល់លិខិតផ្ទេរសិទ្ធិ លិខិតទិញ-លក់នេះក៏មិនត្រឹមត្រូវដែរ ហើយការបញ្ជាក់របស់មេភូមិក៏ជាការបញ្ជាក់ដើម្បីគាំទ្រទៅដល់ការដែលគាត់ចុះហត្ថលេខាលើលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤។ ជារួមខ្លួនចង់បញ្ជាក់ថា នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ ឈ្មោះ ............ ស្លាប់ ហើយនៅពេលឈ្មោះ ............ ស្លាប់នោះអាយុ៩៤ឆ្នាំ ហើយគាត់មិនមែនស្លាប់ភ្លាមៗទេ គាត់ឈឺជរាដេកនឹងកន្ទេលរាប់ឆ្នាំមកហើយ អ៊ីចឹងនៅថ្ងៃទី០៨ ជាថ្ងៃគាត់ស្លាប់នោះគេទាញមេដៃគាត់មកផ្តិត បើយើងនិយាយអំពីឆន្ទះរបស់គាត់អត់

មានទេ។ ហើយពេលនោះបញ្ជាក់ថា ពិតជាបានកាន់កាប់រស់នៅលើដីនោះ ទទួលស្គាល់ថា គាត់រស់នៅ ប៉ុន្តែគាត់មិនមែនម្ចាស់ដី ព្រោះកូនឲ្យនៅទេ កូនយកពីខេត្តឲ្យមកចាំដីទេ ព្រោះកូនគាត់ចេញចូលដីកំពុងមានវិវាទនោះ ហើយផ្ទះគាត់មួយទៀតគាត់រកស៊ីនៅផ្សារចាស់ជាជាងកាត់ដេរ គាត់ចេញចូលៗទេ។ អ៊ីចឹងការបញ្ជាក់របស់មេភូមិនោះវាអត់ផ្លូវការទេ ទី១ បញ្ជាក់នោះសួរថា មេភូមិមាន ឯកសារអីសំខាន់ ចៃដន្យគាត់ទៅបញ្ជាក់នៅលើដីអ្នកដទៃ ទៅថាជារបស់អ្នកនេះអ្នកនោះ អ៊ីចឹងមិនគួរយកជាការទេ ការបញ្ជាក់នេះមិនត្រឹមត្រូវទៅតាមផ្លូវច្បាប់ទេ វាអត់មានឯកសារយោង អត់មានឯកសារសំអាងបញ្ជាក់ថា ............ ជាភោគីស្របច្បាប់នៃដីវិវាទ ទី១។ ទី២ ការបញ្ជាក់របស់មេភូមិនេះគឺឲ្យរួចពីការទទួលខុសត្រូវរបស់គាត់ត្រង់ថា គាត់បានផ្តិតមេដៃជាសាក្សីលើលិខិតផ្ទេរសិទ្ធិ គាត់បានធ្វើជាសាក្សីហើយ គាត់ក៏បានចូលរួមចំណែកនៅក្នុងការដឹងរឿងយកដីអ្នកដទៃដែរ។ ដូច្នេះ ខ្លួនសូមបដិសេធដាច់ខាតចំពោះលិខិតបញ្ជាក់របស់មេភូមិ ហើយនឹងលិខិតផ្ទេរសិទ្ធិនេះ។ មួយទៀតខ្លួនចង់បញ្ជាក់អំពីសារបាននៃការទិញ-លក់ ៗនេះមិនទាន់បានចប់ជាស្ថាពរទេ ពីព្រោះទើបតែកក់ប្រាក់បានត្រឹមតែចំនួន ៥០,០០០(ប្អូនម៉ឺន)ដុល្លា នៅសល់ ១១០,០០០(ដប់មួយម៉ឺន)ដុល្លាទៀត អ៊ីចឹងបើសិនជាតុលាការបង្វិលរឿងនេះទៅសាលាដំបូងដើម្បីរកកម្មសិទ្ធិ បញ្ជាក់អត្ថិភាពនៃសិទ្ធិវិញ ភាគីដើមចោទក៏មិនទាន់ខាតប្រយោជន៍ដែររឿងនេះ រកឲ្យឃើញថា នរណាជាម្ចាស់កម្មសិទ្ធិអ្នកណាពិតជាមានសិទ្ធិដើម្បីលក់-ទិញដីនេះបាន។ ហើយភាគីសហចុងចម្លើយដែលមាន ............ ............ ដែលមានប៉ុន្មានអ្នកនេះគឺជាទូទៅពួកគាត់អត់មានដឹងអីទេ ថាដីនេះជារបស់អ្នកណា ហេតុអី ព្រោះគាត់មិនបានរស់នៅលើដីនោះ គាត់មិនបាននៅជាមួយម្តាយ ឪពុករបស់គាត់ ព្រោះគាត់បែកហើយពួកគាត់ទៅរកស៊ីរៀងៗខ្លួន គាត់ចាស់ៗអស់ហើយ អ៊ីចឹងសម័យប៉ុលពតបែកមកគាត់រកស៊ីរៀងៗខ្លួន ចំណែកតែកូនក្តីខ្លួនទេដែលគាត់រកស៊ីនៅជ្រោយចង្វារនោះ បន្ទាប់មកទៀតគាត់ឡើងមករកស៊ីនៅផ្សារចាស់ ហើយគាត់ទិញផ្ទះបាននៅផ្សារចាស់គាត់ក៏ចេញ-ចូលៗ ដែលមានឪពុកម្តាយនៅឃាមចាំផ្ទះ។ អ៊ីចឹងហើយបានជាឈ្មោះបង្កាន់ដៃមានឈ្មោះគាត់ដោយសារដីរបស់គាត់ ហើយប្រវត្តិដីគឺគាត់ទិញពីឈ្មោះ ............ ............ ៥ហ៊ុន ហើយដោះដូរដីដែលទិញនោះគឺដីវិទ្យាល័យ ជ្រោយចង្វារ សាលានៅរាល់ថ្ងៃ ប៉ុន្តែគាត់ដូរមកគាត់កំពុងកាន់កាប់រាល់ថ្ងៃនេះ ហើយសូមបញ្ជាក់ថា ............ ដែលជាបងប្អូនរបស់ ............ ............ បងប្អូនរបស់ ............ នេះ គឺគាត់បញ្ជាក់ច្បាស់ហើយបញ្ជាក់ហើយបញ្ជាក់ទៀតសូម្បីតែក្នុងសាលក្រមសាលាដំបូងក៏គាត់បាននិយាយដែរ ដីនេះជាដី

របស់ ............ ហើយត្រូវបានបងប្អូនផ្សេងៗយកបង្គាន់ដៃទៅដុតចោលអស់ហើយ ចម្លើយគាត់ស៊ីចង្វាក់នឹងការបញ្ជាក់របស់សុរិយោដីដែលបញ្ជាក់ថា បង្កាន់ដៃពិតជាមានតម្កល់នៅខាងការិយាល័យភូមិបាលពិតប្រាកដមែន។ អ៊ីចឹងតាមមាត្រា ២៨០ ឃើញថា ការសម្រេចរបស់សាលាដំបូងគឺទាក់ទងនឹងអង្គហេតុនេះ មិនទាន់បានគ្រប់គ្រាន់ទេ ហើយវាបានប៉ះពាល់ដល់សិទ្ធិកម្មសិទ្ធិរបស់កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរ ដែលត្រូវបានម្តាយដែលជាអ្នកដទៃ មានន័យថា តាមផ្លូវច្បាប់គាត់មិនមែនជាម្ចាស់កម្មសិទ្ធិទេ យកដីរបស់គាត់ព្រោះគាត់តតិយជន អ៊ីចឹងរឿងនេះប៉ះពាល់ដល់សិទ្ធិអ្នកដទៃយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះស្នើសុំឲ្យសាលាឧទ្ធរណ៍ពិនិត្យ និងសម្រេចដោយច្រានចោលសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ចោលជាអសារបង់ ហើយបង្វិលសំណុំរឿងនេះទៅសាលាដំបូងឲ្យធ្វើការពិនិត្យ និងពិចារណាឡើងវិញ ហើយម៉្យាងទៀតដើម្បីស្វែងរកកម្មសិទ្ធិ ជាពិសេសពាក់ព័ន្ធនឹងសំណុំរឿងមួយទៀតដែលសាលាដំបូងរាជធានីភ្នំពេញ កំពុងចាត់ការ។

-មេធាវី ............ ជាអ្នកតំណាងដោយអាណត្តិឲ្យសហដើមចោទឈ្មោះ ............ និង ............ ធ្វើសេចក្តីថ្លែងការណ៍ថា ចំពោះអង្គហេតុវាមិនមានអ្វីលើសពីការលើកឡើងរបស់លោកប្រធានលើកឡើងអម្បាញ់មិញទេ អ៊ីចឹងខ្លួនសូមមិនធ្វើការលើកពីអង្គហេតុទេ។ តាមអំណាចសាលក្រមលេខ ២០១២ ចុះថ្ងៃទី១៤ ខែកញ្ញា ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចទទួលស្គាល់លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង លេខ ២៤១ ល.ប របស់ចៅសង្កាត់ជ្រោយចង្វារ ទុកជាត្រឹមត្រូវតាមច្បាប់ និងបង្គាប់ឲ្យសហដើមចោទដែលជាកូនក្តីរបស់ខ្លួនទាំងពីរប្រគល់លុយបន្តចំនួន ១១០,០០០(ដប់មួយម៉ឺន)ដុល្លា ដែលនៅសល់ឲ្យសន្តតិជន ខ្លួនយល់ឃើញថា ការសម្រេចសេចក្តីនេះវាមានភាពយុត្តិធម៌នឹងត្រឹមត្រូវហើយ បើតាមលិខិតបញ្ជាក់ប្រវត្តិដីលេខ ២៤១ ល.ប របស់លោកចៅសង្កាត់ជ្រោយចង្វារ គាត់បានបញ្ជាក់ថា លោកយាយ ............ ពិតជាបានកាន់កាប់ដីធ្លីខាងលើនោះតាំងពីឆ្នាំ១៩៧៩ រហូតមកដល់ឆ្នាំ២០១៤ ពិតប្រាកដ ហើយបើតាមមាត្រា ១៦២ នៃក្រមរដ្ឋប្បវេណី បានចែងយ៉ាងច្បាស់ថា ជនដែលបានកាន់កាប់អចលនវត្ថុដោយសន្តិវិធី និងដឹងឮជាសាធារណៈដែលមានឆន្ទៈជាកម្មសិទ្ធិក្នុងអំឡុង២០ឆ្នាំ ត្រូវធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុនោះ ហើយវាស្របជាមួយនឹងភស្តុតាងបង្កាន់ដៃបង់វិភាគទានស្នេហាជាតិដែលខាងលោកយាយ ............ គាត់បានបង់តាំងពីឆ្នាំ១៩៨៤មក គឺបញ្ជាក់ឲ្យឃើញថា លោកយាយ ............ មិនមែនទើបរស់នៅតែ២០ឆ្នាំនោះទេ គឺរស់នៅវាលើសពី៣០ឆ្នាំទៅទៀត ដូច្នេះគាត់អាចធ្វើលទ្ធកម្មនៃកម្មសិទ្ធិដីរបស់គាត់បានហើយ។ ពាក់ព័ន្ធ

ជាមួយនឹងការលើកឡើងរបស់សហភាតា ដែលបានលើកឡើងថា លោកស្រី ............ គាត់បានទិញដីដែលកំពុងមានទំនាស់តម្លៃ ៥ហ៊ុនមាសទឹកដប់ពីលោកស្រី ............ ............ នេះគឺត្រូវបានលោកស្រី ............ ............ គាត់បានអះអាងតាំងពីតុលាការថ្នាក់ក្រោមម្តងហើយ មិនមែនទិញនៅទីតាំងដីនោះទេ គឺទិញទីតាំងដីលក់ស្ករគ្រាប់នៅសាលារៀនទេ ហើយចំពោះភស្តុតាងជាឯកសារដែលគាត់ដាក់ជូនតុលាការទៀត គឺពាក្យសុំកាន់កាប់ប្រើប្រាស់ដីធ្លីចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ១៩៨៩ អ៊ីចឹងត្រូវបានអ្នកមីង ............ អះអាងផ្ទាល់នៅសាលាដំបូងដោយផ្ទាល់ទៀតថា ឈ្មោះនឹងគាត់សរសេរមែន តែមេដៃគឺរបស់ឪពុកគាត់ ដូច្នេះឯកសារដែលលើកឡើងយកមកបញ្ជាក់តុលាការនេះមិនអាចឲ្យតុលាការលោកពិចារណាបានទេ ព្រោះគាត់សរសេរឈ្មោះហើយហេតុអីគាត់មិនផ្តិតមេដៃខ្លួនឯង ចាំបាច់ឲ្យឪពុកផ្តិតធ្វើអី? ការអះអាងបែបនេះមិនសមស្របទេ ហើយពាក់ព័ន្ធនឹងថាហេតុអីផ្តិតមេដៃហើយអត់សរសេរឈ្មោះខ្លួនឯង ខ្លួនមានមូលហេតុគ្រប់គ្រាន់ គឺដោយសារតានឹងយាយអត់ចេះអក្សរអ៊ីចឹងប្រាកដជាមានអ្នកផ្សេងសរសេរឲ្យហើយ តែអ្នកមីង ............ គាត់មានសមត្ថភាពគ្រប់គ្រាន់ ហេតុអីគាត់មិនព្រមផ្តិតមេដៃតែម្តងចាំបាច់ឲ្យតាផ្តិតធ្វើអី? អ៊ីចឹងហើយការអះអាងបែបនេះគ្មានមូលដ្ឋានគតិយុត្តអីដើម្បីឲ្យតុលាការលោកពិចារណាទេ ហើយពាក់ព័ន្ធជាមួយនឹងការលើកឡើងរបស់សហភាតាអំពីរឿងទំនាស់ផ្ទៃក្នុងរឿងគ្រួសាររបស់គាត់ ខ្លួនជាភាគីខាងដើមបណ្តឹង ជាភាគីអ្នកទិញនេះគឺដូចជាមិនមានអ្វីឆ្លើយតបទេ ព្រោះថារឿងនេះគឺជារឿងផ្ទៃក្នុងរបស់គាត់ ហើយការលើកឡើងរបស់គាត់ គាត់ជាភាគីចាញ់ក្តីគាត់មិនសប្បាយចិត្តគាត់ចេះតែលើកទៅ ហើយភស្តុតាងរបស់គាត់មិនមានអ្វីក្រៅពីនេះផង ហើយការលើកឡើងរបស់លោក ............ ទៀត លោក ............ គាត់និយាយម្តងចេះម្តងចុះត្រលប់ត្រលិន ក្នុងរឿងនេះមានសំណុំរឿងព្រហ្មទណ្ឌមួយទៀតដែលលោក ............ ធ្លាប់ប្តឹងអ្នកមីង ............ ពាក់ព័ន្ធនឹងរឿងក្លែងស្នាមមេដៃនោះ ហើយឥឡូវគាត់មកជួយឆ្លើយចម្លើយមកជួយអ្នកមីង ............ ទៅវិញ ដូច្នេះការបំភ្លឺរបស់ ............ និងអ្នកមីង ............ គឺអត់មានភស្តុតាងជាឯកសារដែលដាក់ឲ្យតុលាការធ្វើការពិចារណាបាន ដូច្នេះហើយខ្លួនសូមសំណូមពរជាចុងក្រោយ គឺសូមឲ្យតុលាការតម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការដដែល។

-មេធាវី ............ ជាអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍តបថា ខ្លួនសូមតបបន្តិចដោយសារការលើកឡើងរបស់គាត់មានលេចនូវអង្គហេតុថ្មី ពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌដែលគាត់បានលើកឡើងអម្បាញ់មិញរឿងក្លែងមិនក្លែងនេះ នេះជាសាលដីការបស់

តុលាការកំពូល ដែលស្ថាពរ ហើយបានសម្រេចឲ្យ ............ រួចពីបទចោទប្រកាន់ នេះចំណុចសំខាន់។ ចំណុចមួយទៀតសហភាគាបានលើកឡើងថា កូនក្តីខ្លួនគ្មានភស្តុតាងអ្វីក្រៅពីបង្កាន់ដៃ ខ្លួនសួរត្រលប់ទៅវិញថា តើបង្កាន់ដៃនោះបញ្ជាក់អំពីសិទ្ធិកម្មសិទ្ធិ ឬភោគីស្របច្បាប់ ឬក៏យ៉ាងម្តេច។ នេះបញ្ជាក់ពីភោគីស្របច្បាប់ ហើយច្បាប់យើងទទួលស្គាល់ហើយនេះជាភស្តុតាងហើយ ហើយបើអត់យកមកសំអាងឲ្យតុលាការជឿ តើយកអីមក វាខុសអំពីភាគី ............ វាអត់មានអីមកសំអាងផង នេះហើយជាអ្វីដែលត្រូវលើកភស្តុតាងផ្ទុយមកឲ្យតុលាការជឿវិញ។

-ដើមចោទឈ្មោះ ............ ធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមុននឹងទិញដីនោះក៏ខ្លួនមានភស្តុតាងច្បាស់លាស់ដែរ ហើយផ្ទះខ្លួនក៏នៅក្បែរនោះដែរផ្ទះនៅទល់មុខគ្នាតែម្តង តែរឿងផ្ទៃក្នុងដែលលោកមេធាវីនិយាយអម្បាញ់មិញនេះគឺខ្លួនបដិសេធទាំងស្រុង ព្រោះរឿងផ្ទៃក្នុងមិនអាចយកមកនិយាយជាផ្លូវច្បាប់បានទេ ខ្លួនមានភស្តុតាង គាត់មិនមានបង្កាន់ដៃមែន តែគាត់មានបង្កាន់ដៃបង់វិភាគទានស្នេហាជាតិតាំងពី១៩៨៣មកម្ល៉េះ គាត់បង់ពន្ធរហូត លោកតា ............ និងលោកយាយ ដូច្នេះបានខ្លួនចង់បញ្ជាក់ពីលិខិតនេះមិនមែនអត់មានដូចលោកថាទេ ខ្លួនគ្រាន់តែសំណូមពរចុងក្រោយថា សូមលោកប្រធានតុលាការសាលាឧទ្ធរណ៍មេត្តាតម្កល់សាលក្រមរបស់តុលាការដំបូងនេះទុកជាបានការផង ដែលមានលេខ ២០១២ “ធ” ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧។

-ចុងចម្លើយឈ្មោះ ............ ធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួននៅជ្រោយចង្វារតាំងពីបែកប៉ុលពតមកគឺនៅជាមួយម្តាយរហូតនៅតាំងពីឆ្នាំ១៩៧៩ ខ្លួននៅតែកន្លែងហ្នឹងអត់មានទៅណាទេ ដីឡូតិ៍រំលងគ្នាតែ១ឡូតិ៍គត់ ហើយម៉ែឪខ្លួនគាត់នៅធ្វើការជាមួយគាត់រហូត ខ្លួនមានកូនច្រើនខ្លួនទៅណាអត់រួចទេ ខ្លួននិយាយល្អជាមួយអ្នកណាក៏គេមិនស្តាប់ខ្លួនដែរ គេខ្ពើមសម្តីខ្លួនណាស់ ខ្លួនថា ម៉ែខ្លួនគាត់ចាស់ហើយគាត់ឈឺចូលពេទ្យម្តង ២.០០០(ពីរពាន់) ទៅ ៣.០០០(បីពាន់)ដុល្លា ហើយទៅរកលុយឯណាមកមើលគាត់ ព្រោះអីខ្លួនក្រកូនច្រើន និយាយប្រាប់អ្នកណាក៏មិនស្តាប់ដែរ ដល់ពេលអ៊ីចឹងម្តាយខ្លួនគាត់ទាល់ត្រូវតែលក់ដីនោះដើម្បីយកលុយនោះមើលជម្ងឺគាត់ៗមិនមែនលក់ភ្លាមស្តាប់ភ្លាមទេ គាត់លក់ហើយចូលចង់១ខែគាត់ចូលពេទ្យវិសាលសុខទៀត ម្តងប៉ុន្មានពាន់ ចោះទុយោ ចោះថ្លើមយកមកមើលទៀត វេទនាណាស់គ្មាននរណាទៅមើលទេ អ្នកក្រទេដែលចូលទៅមើលទៅបម្រើគាត់ លាងសព្វសារពើដែលមានក្នុងខ្លួនគាត់ ខ្លួនធ្វើឲ្យគាត់ ហើយឡើងរឹងអស់ហើយគ្មាននរណាទៅមើលគាត់ទេ មិនមែនគាត់ទើបតែមកពីព្រែកអំពិល មិនមែនទេ មកពីកំពង់ព្រែកអំពិលទល់មុខកំពង់ចម្លងជំនាន់ប៉ុលពត ក៏ខ្លួននៅទីនោះដែរ មកនៅតាំងពីឆ្នាំ៨១ ពេលនោះកូនខ្លួនកើត គាត់មកតាំងពី

ពេលនោះគេដូរដី ខ្លួនមកនៅទីនោះគាត់ក៏មកនៅទីនោះដែរ មិនមែនទើបមកយូរ ៗទើបមកទេ ហើយសួរភូមិទៅអ្នកណាក៏ស្គាល់ខ្លួនដែរ។

-ចុងចម្លើយឈ្មោះ ............ ............ ធ្វើសេចក្តីថ្លែងការណ៍ថា ប៉ារបស់ខ្លួនមិនមែនមិនមានលុយទៅបង់ទេ ព្រោះចេញមកគាត់លក់ទឹកអំពៅ ម៉ែខ្លួនអ្នកសកអំពៅ គាត់មិនមែនអត់លុយបង់ទេ គាត់លក់ត្របែក មានល្មុត មានស្វាយ ពុទ្រា គាត់មិនមែនអត់លុយហើយត្រូវការលុយគេទេ គាត់មិនមែនលក់ឲ្យគេគាត់ផ្ញើរទៅឲ្យគេទៀតគេអត់ឲ្យគាត់វិញទៀត គាត់មកថ្ងូរប្រាប់ខ្លួនថា "ហ្អែងមើលលុយអញលក់ពុទ្រាលក់អីអត់ឲ្យអញសោះ" ឪពុកកាប់ទាំងកង់ៗ ទាំងឡាន ទាំងម៉ូតូ ទាំងល្ងាច យកឲ្យអ្នកភ្នំពេញជិះ នៅតែបងប្អូនកូនក្មួយគាត់ស្តីឲ្យ "ស្អប់ពូជប៉ាឯងណាស់" ប៉ាខ្លួនទៅប្រាប់ខ្លួនថា "ហ្អែងមើលវាថាអញចឹងហា" ខ្លួនក៏ថា "ប៉ាឯងមិនតទៅវិញទៅថា បើស្អប់ពូជអញកុំនៅជាមួយអញ" ដូច្នេះសូមលោកតុលាការជួយកាត់ក្តីឲ្យម៉ែពុកខ្លួនផង ព្រោះម៉ែពុកខ្លួនស្រលាញ់វាជាងគេអីក៏ជញ្ជូនទៅឲ្យវា តាំងពីត្របែក តាំងពីស្វាយ តាំងពីពុទ្រា ខ្លួនមិនឲ្យលក់ដោយស្រេចចិត្ត លក់ហើយទីបញ្ចប់អត់ឲ្យលុយគាត់ទេ ហើយសូមឲ្យលោកជួយពិចារណាផងម៉ែពុកខ្លួនជាមនុស្សស្លូតបូតទេ នរណាក៏ស្គាល់គាត់ដែរ។

-ចុងចម្លើយឈ្មោះ ............ ធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនចង់បញ្ជាក់ថាខ្លួនការមកតាំងពីឆ្នាំ១៩៩៤ រហូតមកហើយប្តីខ្លួនទៅធ្វើការឆ្ងាយ ដល់ពេលអ៊ីចឹងទៅគាត់គ្រោះថ្នាក់ចរាចរណ៍ដោយគ្មានពាក្យសម្បថអីមួយទេ តែគាត់ស្អប់កូនគាត់ដែលមិនស្តាប់បង្គាប់តាមគាត់។

## **សំអាងហេតុ**

១-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ឈ្មោះ ............ ធ្វើឡើងតាមកំណត់ច្បាប់សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-សហដើមចោទបានប្តឹងសុំឲ្យតុលាការសម្រេច ទទួលស្គាល់លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ២៤១ ល.ប ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ របស់ចៅសង្កាត់ជ្រោយចង្វារ, សុំចុះបញ្ជីផ្ទេរកម្មសិទ្ធិដីដែលមានទីតាំងនៅឡូតិ៍លេខ៦៣A ផ្លូវវត្តចាស់ ភូមិ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ពីឈ្មោះ ............, ............ ............, ............, ............ និងឈ្មោះ ............ ឲ្យទៅសហដើមចោទឈ្មោះ ............ និងឈ្មោះ ............ បង្គាប់ឲ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី

កម្មសិទ្ធិដីទំនាស់នេះឲ្យដើមចោទឈ្មោះ ............ និង ............ និងប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយដោយសំអាងថា ខ្លួនបានទិញដីទំនាស់នេះពីឈ្មោះ ............ ដែលត្រូវជាម្ដាយរបស់សហចុងចម្លើយ តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ២៤១ ល.ប ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១៤ ដោយមានសាក្សីឈ្មោះ ............ ជាមេភូមិ និងអាជ្ញាធរសង្កាត់ដឹងឮផង។ ក្នុងការទិញលក់នេះដើមចោទបានប្រគល់ប្រាក់តាមរយៈកូនរបស់ឈ្មោះ ............ បានចំនួន ៤០០០០ដុល្លា(បួនម៉ឺនដុល្លា)រួចហើយ ប៉ុន្តែការទិញ-លក់នេះពុំបានបានចប់សព្វគ្រប់នៅឡើយដោយឈ្មោះ ............ បានស្លាប់ទៅ។

៣-ចុងចម្លើយឈ្មោះ ............ បានអះអាងថា ដីទំនាស់នេះជាដីរបស់ខ្លួនដែលបានទិញពីឈ្មោះ ............ ............ ពីឆ្នាំ១៩៨០ មកក្នុងតម្លៃប្រាំហ៊ុនមាស។ ក្រោយមករដ្ឋបានយកដីនោះសង់សាលាហើយបានដូរដីទំនាស់នេះឲ្យមកខ្លួន។ ឪពុក-ម្ដាយខ្លួនមករស់នៅលើដីនេះក្នុងឆ្នាំ ១៩៩២។ ឯកសារបង់ពន្ធដីឪពុកខ្លួនជាអ្នកបង់តែប្រាក់បង់ពន្ធជារបស់ខ្លួន។

៤-តាមការអះអាងរបស់សហចុងចម្លើយឈ្មោះ ............ ............, និង ............ បានបញ្ជាក់ថា ដីទំនាស់នេះជាដីរបស់ឪពុក-ម្ដាយពួកខ្លួនឈ្មោះ ............ និង ............ ដែលគាត់កាន់កាប់រស់នៅលើដីនេះតាំងតែពីឆ្នាំ១៩៧៩ រហូតមក គឺពុំមែនជាដីរបស់ឈ្មោះ ............ ឬរបស់សហចុងចម្លើយណាម្នាក់ឡើយ។ ក្រោយមកក្នុងអំឡុងឆ្នាំ២០១៤ ម្ដាយរបស់ពួកខ្លួនបានលក់ដីនេះឲ្យទៅសហដើមចោទក្នុងតម្លៃ ១៥០០០០ដុល្លា(ដប់ប្រាំម៉ឺនដុល្លា) ដោយមានកិច្ចសន្យាទិញលក់ដីមិនកែប្រែចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៤, កិច្ចសន្យាកក់ប្រាក់ថ្លៃទិញដីចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៤ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ២៤១ ល.ប ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១៤ របស់ចៅសង្កាត់ជ្រោយចង្វារពិតប្រាកដមែន។ ប៉ុន្តែការផ្ទេរសិទ្ធិមិនទាន់បានចប់សព្វគ្រប់ផង ម្ដាយរបស់ពួកខ្លួនបានទទួលមរណៈភាពទៅ។

៥-តាមការបំភ្លឺរបស់សហចុងចម្លើយឈ្មោះ ............(ហើយក៏ជាសាក្សីរបស់ចុងចម្លើយឈ្មោះ ............) បានបញ្ជាក់ថា ខ្លួនបានមករស់នៅលើដីនេះនៅឆ្នាំ១៩៧៩។ អ្នករស់នៅទីនោះមានឈ្មោះ.......................... រូបខ្លួន, ............................., ឈ្មោះ ........, ឪពុក-ម្ដាយខ្លួនមកក្រោយខ្លួនបីឆ្នាំ(១៩៨២)។ ដែលការអះអាងនេះផ្ទុយពីការអះអាងរបស់ឈ្មោះ ............ ដែលថា រដ្ឋបានដូរដីនេះឲ្យខ្លួនក្នុងឆ្នាំ១៩៨៣ ឬ១៩៨៤ និងដែលថា ឪពុកម្ដាយឈ្មោះ ............ និង ............ មករស់នៅលើដីនេះក្នុងឆ្នាំ១៩៩២ នោះ។

៦-តាមឯកសារភស្តុតាងបានបញ្ជាក់ឲ្យឃើញថា ឈ្មោះ ............ ............ ជាអ្នកបង់វិភាគទានលើដីទំនាស់នេះជូនរដ្ឋ ដែលអាចបញ្ជាក់បានថា ឈ្មោះ ............ ............ និងប្រពន្ធ ឈ្មោះ ............ ជាអ្នកកាន់កាប់គ្រប់គ្រងលើដីទំនាស់នេះ។

៧-តាមការអះអាងរបស់សហចុងចម្លើយ ឈ្មោះ ............, ............ ............, ............ និង ............ តាមការបំភ្លឺរបស់អាជ្ញាធរមូលដ្ឋាន និងតាមឯកសារភស្តុតាងក្នុងសំណុំរឿងបានបញ្ជាក់ឲ្យឃើញថា ដីទំនាស់នេះជាដីរបស់ ឈ្មោះ ............ ............ និង ............ ដែលជាឪពុក-ម្តាយរបស់សហចុងចម្លើយបានកាន់កាប់គ្រប់គ្រងតាំងពីឆ្នាំ១៩៧៩ រហូតមក ពុំមែនជាដីរបស់ឈ្មោះ ............ ឡើយ។

៨-រឿងក្តីនេះសាលាដំបូងរាជធានីភ្នំពេញ បានធ្វើការអង្កេត និងលើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ ដូច្នេះសាលាឧទ្ធរណ៍ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ។

៩-សាលក្រមលេខ ២០១២"ធ" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល។

១០-តាមបញ្ញត្តិមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ច្រានពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ឈ្មោះ ............ ចោល។

២-តម្កល់សាលក្រមលេខ ២០១២"ធ" ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

៤-សាលដីកានេះប្រកាសជាសាធារណៈនាថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៩។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សា**

ហត្ថលេខា ហត្ថលេខា ហត្ថលេខា

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

ថ្ងៃសុក្រ ៧កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ភ្នំពេញ,ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍ភ្នំពេញ**

**សំណុំរឿងរដ្ឋប្បវេណី**

លេខ

ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៨

**សាលដីកា**

លេខ: (ធ)

ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៩

ក្រុមប្រឹក្សាទីVII នៃសភារដ្ឋប្បវេណីសាលាឧទ្ធរណ៍ បានបញ្ចប់ការទាញ ហេតុផលដោយផ្ទាល់មាត់នាព្រឹកថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៩ ដែលមាន:

**សមាសភាពក្រុមប្រឹក្សា**

| | |
|---|---|
| លោក | ជាប្រធានក្រុមប្រឹក្សា |
| លោក | ជាចៅក្រមប្រឹក្សា |
| លោក | ជាចៅក្រមប្រឹក្សា |

**ក្រឡាបញ្ជី**

លោក

**១-អត្តសញ្ញាណគូភាគី**

**-សហដើមចោទ:**

១-ឈ្មោះ ............ ភេទប្រុស អាយុ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន មានអាសយដ្ឋានសព្វថ្ងៃភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។ **(ដើមបណ្តឹងឧទ្ធរណ៍)**។

២-ឈ្មោះ ............ភេទស្រី អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានអាសយដ្ឋានសព្វថ្ងៃភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៣-ឈ្មោះ ............ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានអាសយដ្ឋានសព្វថ្ងៃភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៤-ឈ្មោះ ............ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានអាសយដ្ឋានសព្វថ្ងៃភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

៥-ឈ្មោះ ............ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានអាសយដ្ឋានសព្វថ្ងៃភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

មានមេធាវី ............., ............... និង ............. ជាអ្នកតំណាងដោយអាណត្តិ។

-**សហចុងចម្លើយ:**

១-ឈ្មោះ ............ភេទប្រុស អាយុ៦៣ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ មានអាសយដ្ឋានសព្វថ្ងៃភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។ **(ចុងបណ្តឹងឧទ្ធរណ៍)**។

២-ឈ្មោះ ............ភេទស្រី អាយុ៥៧ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ មានអាសយដ្ឋានសព្វថ្ងៃភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។ **(ចុងបណ្តឹងឧទ្ធរណ៍)**។

មានមេធាវី ............. និងមេធាវី ............ ជាអ្នកតំណាងដោយអាណត្តិ។

**២-ខ្លឹមសារនៃសាលក្រមដែលដើមចោទប្តឹងទាមទារ:**

-សុំសិទ្ធិគ្រប់គ្រង និងបែងចែកដីជា ០៥ចំណែកស្មើៗគ្នា ដែលជាចំណែករបស់ឪពុកឈ្មោះ ............នូវដីចំនួន០២កន្លែង ៖

ក-ដីទំហំ ១ហិកតា មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លីលេខ $G_{៧}$-១៤៣២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

ខ-ដីទំហំ ៥.៤៤៧,៣៤ម$^{២}$ មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លីលេខ $G_{៧}$-១៤៣២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្ត កណ្តាល។

ឲ្យទៅកូនបង្កើតចំនួន០៥នាក់ មានឈ្មោះ ............, ............, ............, ............, ............។

-ទាមទារយកប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លីលេខ $G_{៧}$-១៤៣២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ របស់ឈ្មោះ ............ពីឈ្មោះ ............មកវិញ។

**៣-ខ្លឹមសារនៃសាលក្រមដែលសហចុងចម្លើយប្តឹងទាមទារនៅក្នុងបណ្តឹងតប:**

-បញ្ជាក់ពីអត្ថិភាពនៃសិទ្ធិជាកម្មសិទ្ធិឲ្យខ្លួននូវដី០២កន្លែងគឺ ៖

១-ដីដែលមានទំហំ ១០.០០០ម$^{២}$ មានព្រំប្រទល់ខាងជើងទល់នឹង ............ ខាងត្បូងទល់នឹងផ្លូវរទេះ ខាងកើតទល់នឹងផ្លូវលំ ខាងលិចទល់នឹង ............ដែលមានទីតាំងស្ថិតនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១២៦២ ។

២-ដីដែលមានទំហំ ៤.៩១៧ម$^{២}$ មានព្រំប្រទល់ខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង ........... ខាងកើតទល់នឹងផ្លូវលំ ខាងលិចទល់នឹង ............ដែលមានទីតាំងស្ថិតនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១៤៣២។

-សុំផ្ទេរការចុះបញ្ជីដីធ្លីពីឈ្មោះ ............និងប្រពន្ធឈ្មោះ .......... ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១២៦២ និងលេខ G៧-១៤៣២ មកឲ្យសហចុងចម្លើយ។

-បង្គាប់ឲ្យសហដើមចោទរួមគ្នាបង់សងការខូចខាតពេលវេលា ចំនួន ១០.០០០(មួយម៉ឺន)ដុល្លា និងជម្ងឺចិត្តចំនួន ២០.០០០(ពីរម៉ឺន)ដុល្លា និងឲ្យរ៉ាប់រងប្រាក់ប្រដាប់ក្ដី។

## **<u>អង្គហេតុ និងចំណុចវិវាទ:</u>**

សហដើមចោទបានប្ដឹងថា ឪពុករបស់សហដើមចោទឈ្មោះ ................ បានទទួលមរណ:ភាពកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៨ ដោយបន្សល់ទុកនូវមរតកជាអចលនវត្ថុចំនួន០២កន្លែង មានដូចក្នុងកម្មវត្ថុ។ សហដើមចោទ គឺជាសន្តតិជនស្របច្បាប់ ដែលត្រូវទទួលបន្តមរតកដែលជាទ្រព្យសម្បត្តិរបស់ឪពុកឈ្មោះ ............ទើបសហដើមចោទដាក់ពាក្យសុំឲ្យតុលាការបែងចែកមរតកជា ០៥ចំណែកស្មើៗគ្នា។ ចំពោះ ប័ណ្ណលេខ G៧-១២៦២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ គឺសហដើមចោទរក្សាទុក ឯប័ណ្ណលេខ G៧-១៤៣២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ ត្រូវបានចុងចម្លើយដែលមិនមែនជាសន្តតិជន ហើយក៏មិនមែនជាកម្មសិទ្ធិករផងនោះ បានគំរាមកំហែងនិងលួងលោមម្ដាយរបស់សហដើមចោទឲ្យយកមកបង្ហាញ ហើយចុងចម្លើយលួចយកទៅបាត់ទោះបីជាសហដើមចោទបានសុំជាច្រើនសារក៏ដោយ ក៏ចុងចម្លើយនៅតែមិនព្រមឲ្យ។

តាមពាក្យបណ្ដឹងតបចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១៦ របស់ឈ្មោះ ............និងប្រពន្ធឈ្មោះ ............ថា កាលពីឆ្នាំ១៩៨៩ រដ្ឋអំណាចបានចែកដីចំនួន ២កន្លែងឱ្យមកខ្លួននិងប្រពន្ធគឺដី

ដែលជាកម្មវត្ថុបានមកពីអតីតលោកមេភូមិឈ្មោះ ............ ជាអ្នកបែងចែកឱ្យ សព្វថ្ងៃរស់នៅភូមិកណ្តាលក្រោម ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។ នៅអំឡុងឆ្នាំ១៩៨២ ឆ្នាំ ១៩៨៣ និងឆ្នាំ១៩៨៤ ខ្លួនបានឱ្យ ឈ្មោះ ............និងប្រពន្ធឈ្មោះ ......... ត្រូវជាបងបង្កើតរបស់ខ្លួនទៅចាំមើលដើមស្វាយ នៅពេលដល់រដូវស្វាយចេញផ្ការហូតដល់ពេលបេះលក់។ នៅលើដីដែលមានទំហំ ១០.០០០ម² មានស្វាយបីបួនដើម និងដីដែលមានទំហំ ៤.៩១៧ម² មានដើមស្វាយប្រហែល ៧ដើមប៉ុណ្ណោះ ហើយផ្នែកដែលនៅសល់ខ្លួនបានជួលឱ្យគេដាំបន្លែ។ ក្រោយមកដោយសារដើមស្វាយមិនឱ្យផលច្រើន ខ្លួនក៏ឱ្យឈ្មោះ ............និងឈ្មោះ .............. កាប់ដើមស្វាយចោល ហើយលក់យកលុយ។ ក្រោយឆ្នាំ១៩៨៤ ខ្លួនបានជួលដីនេះឱ្យគេដាំបន្លែបន្ត រហូតដល់ឆ្នាំ២០០៣ ទើបខ្លួននិងប្រពន្ធចាប់ផ្តើមដាំស្វាយសាជាថ្មី និងមានបោះបង្គោលរបងព័ទ្ធលួសបន្លាថែមទៀតរហូតដល់បច្ចុប្បន្ន។ ស្រាប់តែនៅឆ្នាំ២០១៤ ទើបខ្លួនដឹងថា ដីដែលខ្លួនកាន់កាប់អស់រយៈពេល ២៧ឆ្នាំហើយនោះ មានប័ណ្ណកម្មសិទ្ធិសិទ្ធិឈ្មោះ ............និងជាកម្មសិទ្ធិរួមជាមួយប្រពន្ធឈ្មោះ ................. ដោយសារឈ្មោះ ............បានយកប័ណ្ណកម្មសិទ្ធិទៅដាក់បញ្ចាំឱ្យឈ្មោះ .......... ភេទប្រុស អាយុ ៥៦ឆ្នាំ ត្រូវជាដន្លងរបស់ខ្លួន។ ហើយដល់ឆ្នាំ២០១៦ ស្រាប់តែឈ្មោះ ............, ឈ្មោះ ............, ឈ្មោះ ............, ឈ្មោះ .......... និងឈ្មោះ ............មកប្តឹងឱ្យចែកមរតកទៅវិញ ដោយអះអាងថា ជាដីមរតក ទោះបីជាពួកគាត់បានដឹងយ៉ាងច្បាស់ថា ដីទាំងពីរកន្លែងនេះគឺជាដីរបស់ខ្លួននិងប្រពន្ធក៏ដោយ។ កាលពីឈ្មោះ ............នៅរស់ តាំងពីឆ្នាំ១៩៨៣ ក៏មិនដែលមកប្តឹងទាមទារដីនេះដែរ រហូតដល់ឆ្នាំ ២០០៨ បន្ទាប់ពីឈ្មោះ ............បានស្លាប់ ក៏មិនមានអ្នកណាម្នាក់មកប្តឹងទាមទារដីនេះដែរ ដែលបញ្ហាដីនេះឈ្មោះ ............... ក៏បានដឹងថា ដីនេះជាដីកម្មសិទ្ធិរបស់ខ្លួន និងមិនដែលប្តឹងទាមទារម្តងណាឡើយ ហើយគាត់មិនបានដឹងពីមុនមកដែរថា តើប្តីរបស់គាត់ឈ្មោះ ............បានលួចធ្វើប័ណ្ណសម្គាល់លើដីទាំង២នេះ ពីពេលណាមកនោះទេ? ព្រោះការកាន់កាប់របស់ខ្លួន និងប្រពន្ធ ជាការកាន់កាប់ជាប់លាប់រហូតរៀងមក ដោយដឹងឮជា សាធារណៈ សុចរិត ទៀងត្រង់ គ្មានប្រើហិង្សា ដោយមានអាជ្ញាធរមូលដ្ឋានដឹងឮយ៉ាងពិតប្រាកដ មានសាក្សី ព្រមទាំងភស្តុតាងជាច្រើនបញ្ជាក់ថែមទៀតផង។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៤៣"គ" ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១/.ច្រានចោលការទាមទាររបស់សហដើមចោទឈ្មោះ ............។

២/.បញ្ជាក់ថា សហចុងចម្លើយឈ្មោះ ............និងឈ្មោះ ............មានអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិនៃដីដូចខាងក្រោម ៖

២.១/ដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១២៦២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ មានទំហំ ៩.៥៥២ម២ ដែលព្រំខាងជើងទល់នឹង ............ ខាងត្បូងទល់នឹងផ្លូវរទេះ ខាងកើតទល់នឹងផ្លូវលំ ខាងលិចទល់នឹង ............ស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

២.២/ដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១៤៣២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ មានទំហំ ៥.៧៦៣ម២ ដែលព្រំខាងជើងទល់នឹងផ្លូវ ខាងត្បូងទល់នឹង .......... ខាងកើតទល់នឹងផ្លូវលំ ខាងលិចទល់នឹង .............. ស្ថិតនៅភូមិកណ្តាល ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្ត កណ្តាល។

៣/.បង្គាប់ឲ្យឈ្មោះ .......... និងឈ្មោះ .............(និង/ឬសហដើមចោទ) ធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិនូវដីដែលមានក្នុងចំណុចទី២ នៃសេចក្តីសម្រេចបញ្ចប់ខាងលើ ឲ្យទៅសហចុងចម្លើយឈ្មោះ ............និងឈ្មោះ ...........។

៤/.ច្រានចោលការទាមទារផ្សេងទៀត របស់សហចុងចម្លើយ។

៥/.ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់សហដើមចោទ។

**-បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ០៧៦ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ ............ ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ៤៣"គ" ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចបញ្ចប់ទាំងមូល។

**-បានឃើញ** របាយការណ៍រឿងរដ្ឋប្បវេណីចុះថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៩ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

បានឃើញ សេចក្តីថ្លែងការណ៍ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ របស់មេធាវី .............., មេធាវី ............. និងមេធាវី ..............។

## នាពេលទាញហេតុផលដោយផ្ទាល់មាត់

## ប្រធានក្រុមប្រឹក្សាអានរបាយការណ៍រឿងសង្ខេប

-មេធាវី ................ ជាអ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទឈ្មោះ ............ ធ្វើសេចក្តីថ្លែងការណ៍ថា មូលហេតុចំបងដែលបានធ្វើបណ្តឹងឧទ្ធរណ៍នេះ ចំពោះសាលក្រមរបស់សាលាដំបូងខេត្តកណ្តាល នៅក្នុងសំណុំរឿងលេខ ៦២៦ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍។ ចំណុចសំខាន់ពាក់ព័ន្ធទៅនឹងខ្លឹមសារនៃសាលក្រមដែលទាមទារឲ្យសាលាឧទ្ធរណ៍ ធ្វើសេចក្តីសម្រេចនោះ ទី១ សុំលុបចោលនៃសាលក្រមរបស់សាលាដំបូង ត្រង់ចំណុចសេចក្តីសម្រេចបញ្ចប់ត្រង់ចំណុចទី២ ទាំងមូល ចំណុចទី៣ និងចំណុចទី៥។ ទី២ សុំបង្គាប់ឲ្យសហចុងចម្លើយឈ្មោះ .............និងឈ្មោះ ............ប្រគល់ដី និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីទៅឲ្យកូនក្តីខ្លួនវិញ។ ទី១ ដីដែលមានប័ណ្ណសម្គាល់លេខ G៧-១២៦២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៩៣ ដែលមានទំហំ ៩៥៥២ម៉ែត្រការ៉េ ដែលមានព្រំប្រទល់ខាងជើងទល់នឹង ............ ខាងត្បូងទល់នឹងផ្លូវរទេះ ខាងកើតទល់នឹងផ្លូវលំ ខាងលិចទល់នឹង ............ដែលស្ថិតនៅភូមិ ក ណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល និងប្រភេទប័ណ្ណទី២ ដែលមានប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់លេខ G៧-១៤៣២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ ដែលមានទំហំ ៥៧៦៣ ម៉ែត្រការ៉េ និងចំណុចទី៣ ប្រាប់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។ អង្គហេតុជាមូលហេតុចំបងនៃការទាមទារសុំឲ្យសាលាឧទ្ធរណ៍ធ្វើការពិចារណានោះ គឺថាខ្លឹមសារនៃសាលក្រមត្រង់ចំណុចសេចក្តីសម្រេចទី២ ទាំងមូល, ចំណុចទី៣ និងទី៥ នោះគឺមានភាពអយុត្តិធម៌យ៉ាងខ្លាំងមកដល់កូនក្តីខ្លួន។ ខ្លួនសុំបង្ហាញពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ ទី១ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០០៨ ពេលដែលឪពុកឈ្មោះ ............ដែលបានទទួលមរណភាព គាត់បានបន្សល់នូវទ្រព្យដែលមានដីពីរកន្លែង ដែលមានប័ណ្ណសម្គាល់សិទ្ធិលេខ G៧-១៤៣២ និងលេខ G៧-១២៦២។ ដីទាំងពីរកន្លែងនេះគឺម្តាយរបស់កូនក្តីខ្លួនលោកស្រី ................ លោកស្រីបានកាន់កាប់ និងប្រើប្រាស់តាំងពីឆ្នាំ១៩៨០ មកម្ល៉េះរហូត គឺមានរដ្ឋអំណាចជាមូលដ្ឋានគឺគាត់បានបញ្ជាក់អំពីសិទ្ធិលើការកាន់កាប់នេះតាំងពីមេភូមិរហូតដល់មេឃុំ។ មួយទៀតទី២ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុនៃមូលហេតុចំបងនោះគឺ ពាក់ព័ន្ធទៅនឹងលិខិតរបស់លោកស្រី ................ គឺបានធ្វើលិខិតបដិសេធលើលិខិតប្រទានកម្មមួយថាប្រទានកម្មទៅឱ្យភាគីម្ខាងចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៦ ដែលការធ្វើ

លិខិតប្រទានកម្មនេះ គឺផ្ទុយទៅនឹងឆន្ទៈលោកស្រី ............... ផ្ទាល់ ពីព្រោះគាត់មិនមានអីត្រូវប្រគល់ដីទាំងពីរប្លង់នេះទៅឲ្យប្អូនប្រុសរបស់គាត់នោះទេ។ ត្រង់ចំណុចទី២ នៃសំអាងហេតុរបស់សាលាដំបូងខេត្តកណ្តាល គឺពុំមានលក្ខណៈត្រឹមត្រូវ ខ្លួនសុំលើកពីខ្លឹមសារនេះថា ក៏ប៉ុន្តែតាមភស្តុតាងដែលប្រមូលបានឃើញថា ឈ្មោះ ...........ដែលត្រូវជាម្តាយរបស់សហដើមចោទមិនទទួលស្គាល់ថា ខ្លួន(...........ជាប្រពន្ធរបស់ឈ្មោះ ............និងមតកជនឈ្មោះ ............) មានសិទ្ធិនៅលើដីដែលជាកម្មវត្ថុនោះទេ ហើយបានធ្វើប្រទានកម្មមកឲ្យឈ្មោះ ............វិញ តាមលិខិតប្រទានកម្មថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៦។ កន្លែងនេះយើងមាន ភស្តុតាងតបទៅនឹងសេចក្តីសម្រេចរបស់សាលាដំបូង។ ទាក់ទងទៅនឹងសំអាងហេតុនេះត្រង់ចំណុចទី២ របស់សាលក្រមនេះ គឺពុំមានលក្ខណៈត្រឹមត្រូវ ពីព្រោះលិខិតប្រទានកម្មចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៦ ធ្វើឡើងមិនត្រឹមត្រូវដែលធ្វើប្រទានកម្មរំលោភយ៉ាងធ្ងន់ធ្ងរ ដែលផ្ទុយទៅនឹងឆន្ទៈពិតប្រាកដរបស់លោកស្រី ............ ។ ម្យ៉ាងទៀតលោកស្រី ............ក្រោយពីបានដឹង នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨ លោកស្រីក៏បានធ្វើលិខិតបដិសេធមួយទៀតចំពោះលិខិតប្រទានកម្មនេះ។ ចំពោះលិខិតបដិសេធចុងក្រោយនេះ គឺមានអ្នកភូមិ អ្នកជិតខាង មេភូមិ អតីតមេឃុំបានទទួលស្គាល់ទៅលើការអះអាងនេះដែរ។ ម្យ៉ាងទៀតគាត់ក៏បានធ្វើសេចក្តីថ្លែងការណ៍មួយទៀត ដែលបានបដិសេធចំពោះលិខិតប្រទានកម្មនេះ ដោយ បានដឹងឮពីអតីតមេភូមិបន្ទាយដែក ដែលភូមិឃុំធ្វើសេចក្តីបញ្ជាក់នៅក្នុងហ្នឹងថា ដីនេះជាដីរបស់ឈ្មោះ............ប៉ុន្តែក្រោយមកទៀត ពួកគាត់បានប្រកាសថា ការប្រកាសនេះជាការយល់ខុស។ ពាក់ព័ន្ធសំអាងហេតុត្រង់ចំណុចទីពីរនៃសាលក្រមសាលាដំបូង(សុំលើករឿងក្រៅបន្តិច) ឈ្មោះ ............បានយកធនធានភស្តុតាងផ្សេងៗ(ភស្តុតាងជាសាក្សី) និងបានយកដីដែលជាកម្មវត្ថុ ថាសាក្សីទាំងនោះបានជួលដីពីឈ្មោះ ............ដើម្បីធ្វើកសិកម្ម និងអតីតអាជ្ញាធរភូមិ-ឃុំបានទទួលស្គាល់ថា បានប្រគល់ដីជាកម្មវត្ថុឲ្យឈ្មោះ ............ដែរ។ នៅត្រង់ចំណុចនេះគឺជាការអះអាងដែលផ្ទុយទៅនឹងការពិតទាំងស្រុង ពោលប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់ដីធ្លីលេខ G៧-១២៦២ គឺស្ថិតនៅភូមិកណ្តាលលើ ហើយប័ណ្ណ G៧-១៤៣២ ទី២ វិញគឺស្ថិតនៅភូមិកណ្តាលក្រោម ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលជាដីស្របច្បាប់របស់សពលោក ............និងលោកស្រី ............ដែលបានប្រើប្រាស់ និងអាស្រ័យផលតាំងពីឆ្នាំ១៩៨០ មក។ នៅក្នុងឆ្នាំ១៩៩៣ គឺរដ្ឋអំណាចមូលដ្ឋានបានចាប់ផ្តើមធ្វើប័ណ្ណ គឺប្រជាជននៅក្នុងភូមិឃុំទាំងមូលត្រូវបានធ្វើប័ណ្ណទូ

ទាំងភូមិឃុំទាំងអស់ អ៊ីចឹងមិនអាចលើកជាមូលហេតុថា លោក ............និង ............គាត់ទៅលួចធ្វើប័ណ្ណទេ ក្នុងចំណុចនេះយើងមានសាក្សីជាច្រើនដែលពួកគាត់បានទៅចុះបញ្ជីដែរ។ នៅត្រង់ចំណុចទី៣ នៃសំអាងហេតុ សាលក្រមសាលាដំបូងក៏បានធ្វើសេចក្ដីសន្និដ្ឋាន ក៏មានការភាន់ច្រឡំទៅនឹងអង្គហេតុដែរ។ ទី១ ពាក់ព័ន្ធសំអាងហេតុទី៣ នេះខ្លួនសុំលើកបន្តិច តាមសំអាងហេតុខាងលើតុលាការយល់ឃើញថា ដីដែលជាកម្មវត្ថុគឺជាកម្មសិទ្ធិរបស់ឈ្មោះ ............និងភរិយា និងមិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ ............និងឈ្មោះ ............ទេ។ កន្លែងនេះឃើញថាតុលាការពុំមានមូលដ្ឋានច្បាស់លាស់ក្នុងការធ្វើមោឃភាពប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីរបស់កម្មសិទ្ធិករឈ្មោះ ............និង ............នោះទេ។ នៅក្នុងនេះផ្អែកទៅលើការអះអាងសាក្សីរបស់ឈ្មោះ ............ឈ្មោះ ............ ជាសេដ្ឋកិច្ចឃុំ ដែលមានទំនាក់ទំនងជិតស្និទ្ធគ្នានឹងឈ្មោះ ............ពីព្រោះឈ្មោះ ............ជាសេដ្ឋកិច្ចភូមិនាសម័យនោះ។ ហើយសាក្សីបំភ្លឺដទៃទៀតសុទ្ធតែមានទំនាក់ទំនងជិតស្និតជាមួយឈ្មោះ ............ព្រោះសាក្សីម្នាក់ក៏ជាម៉ែដោះរបស់ឈ្មោះ ............ដែរ។ មូលហេតុក្នុងការទាមទារកន្លែងនេះពាក់ព័ន្ធទៅនឹងដីដែលមានប័ណ្ណកម្មសិទ្ធិនោះ គឺជាចំណុចដែលសំខាន់ ពីព្រោះប័ណ្ណសម្គាល់អចលនវត្ថុទាំងពីរដែលមានលេខ G៧-១៤៣២ និងលេខ G៧-១២៦២ ដែលកូនក្ដីខ្លួនបានលើកឡើងនេះគឺជាកម្មសិទ្ធិរបស់ឪពុកកូនក្ដីខ្លួន។ ពីព្រោះសម័យនោះគេមានការចុះបញ្ជីជាលក្ខណ: ជាប្រព័ន្ធ អ៊ីចឹងបានបង្ហាញអំពីអត្ថិភាពនៃសិទ្ធិហើយ។

-មេធាវី ............ជាអ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទឈ្មោះ ............ ធ្វើសេចក្ដីថ្លែងការណ៍ថា ពាក់ព័ន្ធទៅនឹងសាលក្រមរបស់សាលាដំបូង គឺកូនក្ដីខ្លួនប្ដឹងឧទ្ធរណ៍មិនសុខចិត្តទៅនឹងចំណុចត្រង់សេចក្ដីសម្រេចទាំងមូល ដោយមូលហេតុថា ដីទាំងពីរកន្លែងខាងលើនេះគឺជាកម្មសិទ្ធិរបស់ឪពុកឈ្មោះ ............ដែលបានទទួលមរណភាពនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០៨ ហើយការដែលមានប័ណ្ណសម្គាល់កម្មសិទ្ធិលើដីទាំងពីរកន្លែងនេះគឺឈ្មោះ ............និងកូនក្ដីខ្លួនគាត់បានកាន់កាប់ប្រើប្រាស់ និងអាស្រ័យផល តាំងពីឆ្នាំ១៩៨០មក។ ក្រោយមករដ្ឋអំណាចបានធ្វើការចែកដីឱ្យប្រជាពលរដ្ឋដោយបានប្រកាសនៅក្នុងអាជ្ញាធរភូមិឃុំឱ្យប្រជាពលរដ្ឋដែលបានរស់នៅ និងកាន់កាប់ជាក់ស្ដែងនាំគ្នាទៅធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិ ហើយនៅឆ្នាំ១៩៩៣ ឈ្មោះ ............ក៏បានទទួលបានប័ណ្ណសម្គាល់កម្មសិទ្ធិដែលក្នុងនោះមានអាជ្ញាធរក្រុមចំរុះ ក៏ដូច

ជាមានឈ្មោះ ............ជាសេដ្ឋកិច្ចឃុំ គាត់ក៏ចូលរួមចំណែកដើម្បីធ្វើការ កសាងប្តូង់ឲ្យមក ............ដែលជាឪពុករបស់កូនក្តីខ្លួនដែរ។ ដូច្នេះ កូនក្តីខ្លួនបានប្រើប្រាស់កាន់កាប់ និងអាស្រ័យផលលើដីទាំងពីរកន្លែងខាងលើនេះអស់រយៈពេលជាង ២០ឆ្នាំ គិតចាប់ពីថ្ងៃដែលចេញប័ណ្ណរហូតដល់ថ្ងៃដែលឈ្មោះ ............ដឹងក្នុងឆ្នាំ២០០៨ គឺជិត ២០ឆ្នាំហើយដែលកូនក្តីខ្លួនបានកាន់កាប់ដោយសន្តិវិធី សុចរិត មានការដឹងឮពីអាជ្ញាធរសាធារណៈ ហើយក៏គ្មានការប្តឹងជំទាស់ ពីតតិយជនណាមួយឡើយ។ ផ្ទុយទៅវិញរហូតដល់ឆ្នាំ២០០៨ ក្រោយពេលដែលឪពុករបស់កូនក្តីខ្លួនស្លាប់ទៅទើបឈ្មោះ ............មកប្តឹងតវ៉ាថា ដីទាំងពីរនោះជារបស់ខ្លួនទៅវិញ ហើយក៏បានកសាងនូវឯកសារលិខិតមួយចំនួនដែលធ្វើឡើងក្រៅពីឆន្ទៈរបស់កូនក្តីខ្លួនផ្ទាល់។ ក្នុងនោះមានលិខិតប្រទានកម្មចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៦ ដែលក្នុងនោះចុងចម្លើយបានបង្កើតនូវលិខិតនេះឡើងដែលរំលោភលើទំនុកចិត្តយ៉ាងធ្ងន់ធ្ងរលើកូនក្តីខ្លួន ដោយហេតុថា ការដែលកូនក្តីខ្លួនព្រមផ្តិតមេដៃលើលិខិតប្រទានកម្មនេះ គឺដោយសារមានការជឿជាក់លើប្អូនប្រុសបង្កើតថា ផ្តិតទៅដើម្បីបញ្ចប់ទំនាស់រវាងគ្រួសារ និងកូន ក៏ដូចផ្តិតទៅដើម្បីដោះដូរដីមួយកន្លែងមកឱ្យកូនៗរបស់កូនក្តីខ្លួន។ ដូច្នេះកូនក្តីខ្លួន(............)ក៏បានឯកភាពធ្វើតាមគ្រប់លក្ខខណ្ឌរបស់ឈ្មោះ ............ដើម្បីបញ្ចប់ទំនាស់ដើម្បីឲ្យក្រុមគ្រួសារសុខសាន្ត ដោះដូរយកដីផ្សេងៗទៀត ហើយកុំឱ្យមានទំនាស់នៅក្នុងក្រុមគ្រួសារបន្តទៀត។ ប៉ុន្តែក្រោយមកនៅក្នុងខ្លឹមសារនៃលិខិតប្រទានកម្មនេះមានសរសេរថា ដើម្បីប្រគល់ដីឲ្យកូន តែមិនបានសរសេរដើម្បីបញ្ចប់ទំនាស់នោះទេ ទើបរង់ចាំរហូតមកបច្ចុប្បន្ននេះក៏មិនដែលឃើញមានឈ្មោះ ............បានយកដីណាផ្សេងទៀតដើម្បីដោះដូរនោះទេ ទើបលោកយាយគាត់ដឹងខ្លួនបានធ្វើលិខិតបដិសេធលិខិតប្រទានកម្មចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៦ គាត់វិញ ហើយនៅក្នុងនោះលោកយាយក៏បានធ្វើលិខិតអះអាងបន្ថែមដើម្បីបញ្ជាក់នៅក្នុងអង្គហេតុនេះដែរ

នេះទី១។ ទី២ ទាក់ទងទៅនឹងកម្មសិទ្ធិបើទោះបីជាប័ណ្ណដែលបានធ្វើឡើងនេះខុសត្រង់ទំហំបន្តិចក៏ដោយ គឺពាក់ព័ន្ធទៅនឹងបច្ចេកទេសឧបករណ៍របស់ខាងសុរិយោដី ពាក់ព័ន្ធឧបករណ៍នៅឆ្នាំ១៩៩៣ និងសម័យឆ្នាំ២០១៧ ដែរ ដូច្នេះការដែលមានទំហំខុសគឺពុំមានលក្ខណៈអ្វីដែលជាកត់សម្គាល់នោះទេ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺលិខិតលេខ ០៩៤/១៧ នៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧ ខាងមន្ត្រីជំនាញសុរិយោដីបានបញ្ជាក់ថា ដីនេះគឺជាដីកម្មសិទ្ធិរបស់ឈ្មោះ ............និងយាយ ............ គឺមានពីរចំណែក ដូច្នេះពុំមានភស្តុតាងណាមួយបញ្ជាក់ថា ការកសាងប័ណ្ណនេះ

មានលក្ខណៈមិនប្រក្រតី ធ្វើឡើងមានការលួចលាក់ដែលមិនឲ្យមន្ត្រីជំនាញដឹងឮដែរ។ ការកសាងប័ណ្ណទាំងពីរកន្លែងនេះគឺធ្វើឡើងត្រឹមត្រូវដោយមានឈ្មោះទិន្នន័យនៅខាងមន្ទីរសុរិយោដីផងដែរ ហើយទោះបីគិតពីលទ្ធកម្មនៃកម្មសិទ្ធិ ក៏លោកយាយបានកាន់កាប់ប្រើប្រាស់ដីនេះអស់រយៈពេលជិត ២០ឆ្នាំមកហើយដែរ។ ដូច្នេះ យោងទៅតាមអាជ្ញាយុកាលលទ្ធកម្មនៃកម្មសិទ្ធិអចលនវត្ថុ គឺលោកយាយបានធ្វើកាន់កាប់ដោយមានការដឹងឮ ហើយលើសពីរយៈពេល ១០ឆ្នាំទៅទៀត ដូច្នេះ លោកយាយអាចទទួលបាននូវសិទ្ធិដែលជាកម្មសិទ្ធិលើដីនេះក៏ដូចជាមានប័ណ្ណសម្គាល់កាន់កាប់ដីធ្លីបញ្ជាក់មកជាមួយដែរ។ ក្នុងនាមខ្លួនជាអ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទស្នើសុំក្រុមប្រឹក្សាសាលាឧទ្ធរណ៍មេត្តាពិនិត្យ និងពិចារណា ទៅលើប័ណ្ណសម្គាល់កម្មសិទ្ធិដែលមានឈ្មោះ ............ ជាម្ចាស់កម្មសិទ្ធិពិតប្រាកដ និងស្នើសុំលុបចោលសាលក្រមរបស់សាលាដំបូងខេត្តកណ្ដាល ត្រង់សេចក្ដីសម្រេចទាំងមូល និងសម្រេចឲ្យឈ្មោះ ............ និងឈ្មោះ ............ប្រគល់ដីដែលមាន ប័ណ្ណសម្គាល់កម្មសិទ្ធិទាំងពីរឲ្យមកកូនក្ដីខ្លួនវិញ ដែលមានប័ណ្ណលេខ G៧-១២៦២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ និងប័ណ្ណលេខ G៧-១៤៣២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ មកលោកយាយ ............ ក៏ដូចជាធ្វើការបែកចែងទ្រព្យទៅឲ្យសន្តតិជនស្របច្បាប់។

-មេធាវី ............ថ្លែងការណ៍ថា ខ្លួនពុំមានអ្វីបន្ថែមទេ សុំឯកភាពតាមសហភាគា។

-មេធាវី ............ ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ ............ ធ្វើសេចក្ដីថ្លែងការណ៍ថាៈ យោងទៅតាមអង្គហេតុនៅក្នុងរឿងនេះ ខ្លួនសុំបញ្ជាក់បន្តិចថា ដីទាំងពីរនេះគឺកូនក្ដីខ្លួនកាន់កាប់តាំងពីឆ្នាំ១៩៨៩ ហើយនៅឆ្នាំ១៩៩២ គាត់បានឲ្យបងរបស់គាត់ទៅធ្វើការបេះ មើលស្វាយដែលមានតែប៉ុន្មានដើមនោះទេ ដើម្បីបេះធ្វើការប្រមូលផលលក់។ ប៉ុន្តែនៅឆ្នាំ១៩៩៤ គាត់មើលតែដី ប៉ុន្តែគាត់បានជួលដី ដែលជាចំណែកមិនបានដាំដើមស្វាយ គឺឱ្យអ្នកផ្សេងទៀតដាំបន្លែ ធ្វើស្រែ ស្រូវ និងជួលបន្តឱ្យគេរហូត។ រហូតដល់ឆ្នាំ១៩៩៤ ឈ្មោះ ............និងឈ្មោះ ............ ដែលជាបងគាត់ ដោយសារស្វាយមិនបានផលល្អក៏កាប់ដើមស្វាយនោះចោលលក់ទៅ ហើយពួកបងគាត់ទាំងពីរនាក់ក៏បានចាកចេញទៅ ដោយកូនក្ដីខ្លួនអត់បានដឹងថា អ្នកទាំងពីរបានលួចធ្វើប័ណ្ណនៅលើដីរបស់ខ្លួននោះទេ។ ហើយបន្ទាប់មកទៀតគាត់បានធ្វើការកាន់កាប់រហូតមកដល់បច្ចុប្បន្ននេះ។ ចំពោះការលើកឡើងរបស់មេធាវីដែលគាត់តំណាងឲ្យលោក ............ នោះខ្លួនសូមបញ្ជាក់ថា ពាក្យបណ្ដឹងរបស់គាត់ដែលគាត់បានដាក់ទៅសាលាដំបូងខេត្តកណ្ដាល នោះបើសិនជាដីដែល

គាត់ប្ដឹងសុំឱ្យបែងចែកគឺគាត់កាន់កាប់ អ៊ីចឹងគាត់អត់មានអ្វីត្រូវពាក់ពន្ធ័ទំនាស់ជាមួយកូនក្ដីខ្លួនទេ បើសិនដីគាត់កាន់កាប់ឪពុកគាត់កាន់កាប់កន្លងមក គឺដីហ្នឹងគាត់អាចស្នើសុំបែកចែកសន្តតិកម្មដែល គាត់បានពីឪពុកគាត់បាន មិនចាំបាច់អ្វីដែលត្រូវមកប្ដឹងកូនក្ដីខ្លួននោះទេ។ ប៉ុន្តែដោយសារដីទាំងពីរ កន្លែងនេះគឺជារបស់កូនក្ដីខ្លួនដែលបានកាន់កាប់កន្លងមក ហើយតាំងពីឪពុកគាត់ឈប់ឱ្យនៅ ចាក ចេញទៅគឺតាំងពីឆ្នាំ១៩៩៤ មករហូតទៅនៅកន្លែងផ្សេង ហើយគាត់ក៏មានលិខិតបញ្ជាក់ពីមេភូមិ មេឃុំឱ្យដឹងថា ដីរបស់គាត់ដែរ។ ចំណុចគួរឱ្យចាប់អារម្មណ៍មួយទៀតដែរ គឺទាក់ទងទៅនឹងប័ណ្ណ កម្មសិទ្ធិដែលគាត់លួចទៅធ្វើ ឃើញថា បើគាត់ជាម្ចាស់ដីខ្លួនជឿជាក់ថា គាត់មិនមែនមិនដឹងដីគាត់ នៅភូមិអីទេ ហើយគាត់ធ្វើប័ណ្ណនេះគឺខុសទៀត គឺប័ណ្ណ G៧-១៤៣២ ប័ណ្ណហ្នឹងគឺនៅភូមិកណ្ដា លក្រោម តែគាត់បានបញ្ជាក់នៅក្នុងប័ណ្ណហ្នឹងគឺនៅភូមិកណ្ដាលលើ អ៊ីចឹងសួរថា ទីតាំងដីដែលធ្វើ អាចថាខុសទេបើសិនគាត់ជាអ្នកកាន់កាប់ ហើយដីហ្នឹងជារបស់គាត់ពិតប្រាកដ។ មួយវិញទៀតគឺ នៅក្នុងបណ្ណ័ហ្នឹងគាត់ដាក់ថា មានជាប់ព្រំប្រទល់ជាមួយឈ្មោះ ........... ប៉ុន្តែឈ្មោះ ........... គឺជាប់នៅខាងត្បូង ប៉ុន្តែប័ណ្ណរបស់ឈ្មោះ ........... គឺត្រឹមត្រូវដែលគាត់ដាក់ថានៅភូមិកណ្ដាល ក្រោមពិតមែន ប៉ុន្តែខាងជើងគឺទល់នឹង ............មិនមែនទល់នឹងឈ្មោះ ............នោះទេ គឺគាត់ បានបញ្ជាក់ដោយសារថា ដីហ្នឹងអ្នកណាក៏ដឹងថាជាដីរបស់ឈ្មោះ ............មែន ហើយប័ណ្ណ ដែលឈ្មោះ ...........បានធ្វើនេះនៅឆ្នាំ១៩៩៣ ថ្ងៃទី២០ ខែមីនា ដូចគ្នាទាំងអស់។ ហើយចំពោះ ការកាន់កាប់កន្លងមក គឺកូនក្ដីខ្លួនពេលនេះបានធ្វើការដាំស្វាយលើនៅដីរបស់គាត់ ហើយដីនេះមាន របងមានការថែទាំ ហើយគាត់មិនបានដឹងនោះទេ លុះគេប្ដឹងគាត់មកតុលាការនេះទើបគាត់ដឹងថា គេប្ដឹងគាត់រឿងអី គឺខាងឈ្មោះ ............ នេះប្ដឹងមកតុលាការ។ ប៉ុន្តែមុនដំបូងគាត់ប្ដឹងសុំបែង ចែកសន្តតិកម្ម តែគាត់ចោទថាកូនក្ដីខ្លួនលួចប័ណ្ណរបស់គាត់។ បន្ទាប់មកទៀតទើបគាត់ធ្វើការកែ តម្រូវពាក្យបណ្ដឹង គឺកូនក្ដីខ្លួនជាចុងចម្លើយ ដោយទាមទារយកប័ណ្ណមកវិញ។ ចំពោះកូនរបស់ គាត់បើថាឪពុកគាត់ស្លាប់នៅឆ្នាំ២០០៨ សួរថាតើកូនរបស់គាត់ប៉ុន្មានអ្នកហ្នឹងដែលមកធ្វើផលអ្វីនៅ ដីនោះទេ? គឺមិនដែលមាននោះទេ ដោយសារអ្នកទាំងអស់គ្នាដឹងថារបស់ហ្នឹងមិនមែនជារបស់ខ្លួន។ ប៉ុន្តែក្រោយមកដោយ សារគាត់បានប័ណ្ណទាំងអស់នេះពីម្ដាយរបស់គាត់ទើបគាត់មកប្ដឹងទាមទារដី ពីឈ្មោះ ............ដែលគាត់បានកាន់កាប់កន្លងមក។ អ៊ីចឹងនៅក្នុងរឿងនេះក្នុងនាមខ្លួនជាមេធាវី តំណាងឱ្យលោក ............ខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាមេត្តាពិចារណា និងស្នើសុំតម្កល់សាលក្រម

លេខ ៤៣(គ) ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការដដែល។

-មេធាវី ............ជាអ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ ............ និង ............ធ្វើសេចក្ដីថ្លែងការណ៍ថា: ទាក់ទងទៅនឹងអង្គហេតុនេះសហភាគារបស់ខ្លួនបានលើកឡើងមកច្រើនហើយរួមទាំងភស្តុតាងនានា។ ប៉ុន្តែ សហភាគាខាងដើមបណ្ដឹងគាត់ចេះតែចោទថា លិខិតប្រទានកម្មនៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៦ ធ្វើឡើងមិនត្រឹមត្រូវ នេះសូមក្រុមប្រឹក្សាពិចារណា នេះគាត់ធ្វើនៅមុខខ្លួនហើយមានកូនគាត់ប្រុសគាត់ម្នាក់មកចូលរួមផ្ដិតមេដៃលើឯកសារនេះដែរ។ អ្វីដែលគាត់បដិសេធគាត់ថា ពីរឆ្នាំក្រោយគាត់មានលិខិតឆ្នាំ២០១៨ បដិសេធចម្លើយរបស់គាត់ ត្រង់ហ្នឹងសូមតុលាការពិចារណា។ ប៉ុន្តែមូលហេតុដែលកើតឡើងនេះគឺចេញពីការចង់បានដីរបស់កូនក្ដីខ្លួន ទៅសួរអ្នកស្រុកទៅអ្នកណាក៏ដឹងថា ដីនោះដីសុទ្ធតែជាប់ព្រំគ្នាទាំងអស់។ រឿងហេតុគឺកើតចេញពីឈ្មោះ ............ ទាំងអស់ ............ គាត់បានទៅបង្ហាញនៅក្នុង Page របស់សម្ដេច **ហ៊ុន សែន** ថា កូនក្ដីខ្លួនជាសកម្មជនរបស់គណៈបក្សសង្គ្រោះជាតិ ហើយចោទថាបានសម្លាប់ឪពុករបស់គាត់ តាមការពិតកូនក្ដីខ្លួនមិនបានសម្លាប់នោះទេ។ មានរឿងនេះហើយបានជាអភិបាលខេត្តបានបញ្ជាមកថ្នាក់ស្រុកដើម្បីហៅគាត់មកប្រជុំមានកំណត់ហេតុមួយចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ហៅកូនក្ដីខ្លួនទៅបំភ្លឺ ហៅគាត់ជាម្ដាយទៅបំភ្លឺ ហើយនៅក្នុងកំណត់ហេតុនេះគាត់បានឆ្លើយថា ដីនេះមិនមែនជាដីគាត់នោះទេ គឺជាដីរបស់ប្អូនគាត់ ហើយចម្លើយសារភាពរបស់គាត់នៅឃុំក៏មានទៀត ចម្លើយរបស់ឈ្មោះ ...........ដែលជាម្ដាយ ដែលជាបងស្រីបង្កើតរបស់កូនក្ដីខ្លួនបានឆ្លើយនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ គាត់បានឆ្លើយថា ដីទាំងពីរកន្លែងខាងលើដែលមានឈ្មោះ ............និងឈ្មោះនាងខ្ញុំ ដីនេះជាដីរបស់ប្អូនខ្លួនឈ្មោះ ............ពិតប្រាកដមែន។ គាត់ប្ដឹងកូនក្ដីខ្លួនមិនមែនពីររឿងនោះទេ គាត់ប្ដឹងកូនក្ដីខ្លួនថា សម្លាប់ឪពុកគាត់ ហើយឪពុកគាត់ស្លាប់តាំងពីឆ្នាំ២០០៨ ដោយសារជម្ងឺម្រេញ មួយរឿងទៀតគាត់ប្ដឹងកូនក្ដីខ្លួនថាទៅលួចលក់ដី។ ហើយដីរាល់ថ្ងៃគឺកូនក្ដីខ្លួនបានជួលឲ្យគេដាំស្វាយទាំងពីរកន្លែង មានរបងត្រឹមត្រូវ មានកិច្ចសន្យាជួលឱ្យអ្នកណា ឆ្នាំណា គឺមាននៅក្នុងសំណុំរឿងអស់ហើយ។ ក្នុងនាមខ្លួនជាអ្នកតំណាងដោយអាណត្តិឱ្យឈ្មោះ ............និង ............ខ្លួនស្នើសុំសាលាឧទ្ធរណ៍តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៤៣"គ" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ទុកជាបានការដដែល។

មេធាវី ............ថ្លែងការណ៍បន្ថែមថា បានជាចេញលិខិតប្រទានកម្មពីព្រោះពេលនោះគាត់បានឆ្លើយគ្រប់កន្លែងហើយ កូនក្តីខ្លួនគាត់ចង់បញ្ជាក់ដើម្បីកុំឱ្យគាត់ទាមទារទៀត អ៊ីចឹងឱ្យគាត់ប្រគល់សិទ្ធិក្នុងការទាមទារលើដីនោះមក ពីព្រោះគាត់តែងតែឆ្លើយអះអាងគ្រប់កន្លែងថា ដីនោះមិនមែនជាដីរបស់គាត់ទេ អ៊ីចឹងគាត់អត់ទាមទារទេ។ នៅក្នុងបណ្តឹងសុំបែងចែកមរតកនេះគាត់ក៏មិនទាមទារដែរ ព្រោះបើសិនដីនេះជាដីមរតកមែន អ៊ីចឹងចំណែកពាក់កណ្តាលត្រូវជារបស់គាត់ ហើយពាក់កណ្តាលទៀតគាត់ត្រូវចែកជាមួយកូន០៦នាក់ ពីព្រោះកូនក្នុងបណ្តឹងនេះដាក់តែ០៥នាក់ទេ តែកូនមាន០៦នាក់ ហើយកូន០១នាក់ទៀតអត់ប្តឹងទេ ហើយម្តាយក៏មិនប្តឹងដែរតាំងពីដើមមក។ សូមបញ្ជាក់ថា នេះគ្រាន់តែជាការអះអាងរបស់មេធាវីសហភាតាម្ខាងទៀត ព្រោះការធ្វើលិខិតប្រទានកម្មនេះគឺអត់មានទាក់ទងទៅនឹងការដកពាក្យបណ្តឹងនោះទេ បើសិនគាត់មានឆន្ទៈដកបណ្តឹងមិនមែន គាត់អត់ប្តឹងកូនក្តីខ្លួនរឿងព្រហ្មទណ្ឌទេ តែនេះគាត់ប្តឹងកូនក្តីខ្លួន រហូត។ ឆ្នាំ១៩៩៣ គឺប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់ដីធ្លី នៅក្នុងបណ្តឹងតបខ្លួនមិនបានប្តឹងសុំលុបចោលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីទាំងពីរនោះទេ។ មានតែបណ្តឹងតបសុំឱ្យទទួលស្គាល់អត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិនៅឆ្នាំ២០១៦ ។

មេធាវី ............ ថ្លែងការណ៍បន្ថែមថា ខាងលោក ............ គេប្តឹងមុនប្តឹងនៅឆ្នាំ២០១៥ ប៉ុន្តែសំណុំរឿងតែមួយនោះទេ ហើយបន្ទាប់ពីមានការត្រៀមអីទៅគាត់ក៏បានដាក់បណ្តឹងតប កាលហ្នឹងគាត់មិនទាន់ពឹងពាក់ពួកខ្លួនជាមេធាវី។ គាត់ប្តឹងតបដោយសារគាត់ដឹងថាគេមានប័ណ្ណហ្នឹង បន្ទាប់ពីការដាក់បណ្តឹងតបហើយទើបគាត់មានការចរចារវាងបងប្អូនគាត់ហ្នឹង។ ខ្លួនសុំជម្រាបថា នៅពេលមានការវាស់វែងហ្នឹង សវនាការសាលាដំបូងខេត្តកណ្តាល គឺអ្នកដែលជាប់ហ្នឹងបានបញ្ជាក់ថា ការវាសវែងនៅសម័យហ្នឹងគឺពុំមានធ្វើដូចសម័យយើងដែលមានចាប់ GPS អ៊ីចឹងនោះទេ។ កាលហ្នឹងគឺមានតែការចូលទៅឆ្លើយរបស់អ្នកដែលជាម្ចាស់ដីនោះទេ គឺមិនមានការវាស់វែងថាដីនេះយ៉ាងម៉េចៗគឺពុំមាននោះទេ គឺមានតែការរាយការណ៍ទៅអាជ្ញាធរ ហើយអាជ្ញាធរចេញប័ណ្ណតែម្តង អ៊ីចឹងហើយបានជាគាត់រាយការណ៍ថា គាត់មិនដឹងថាដីគាត់នៅភូមិកណ្តាលក្រោម ឬភូមិកណ្តាលលើ ទើបគាត់រាយការណ៍តាមការជាក់ស្តែង។ ខ្លួនសុំជម្រាបថាសូម្បីតែឈ្មោះ ...........ក៏បានបញ្ជាក់ហើយថា អត់មានផ្តិតមេដៃជាប់ព្រំនោះទេ។ ឈ្មោះ ...........គាត់ធ្វើប័ណ្ណរបស់គាត់ដែរ ប៉ុន្តែឈ្មោះ ............មិនដែលផ្តិតជាប់ព្រំនោះទេ តែគាត់ដាក់នៅក្នុងប័ណ្ណ

ហ្នឹងថា ព្រំនៅជាប់ឈ្មោះ ............កូនក្ដីខ្លួន គឺពុំបានដាក់ថា ជាប់ឈ្មោះ ............នោះទេ ហើយដាក់ថ្ងៃខែជាមួយគ្នាដែរ។ ប៉ុន្តែឈ្មោះ ............ថានៅជាប់ព្រំឈ្មោះ ...........។ ចំពោះរឿងប័ណ្ណកូនក្ដីខ្លួនដឹងពេលគេប្ដឹងគាត់ទេ ហើយមិនទាន់បានប្ដឹងបដិសេធប័ណ្ណនោះទេ គឺមានតែបណ្ដឹងតប។

-ឈ្មោះ ...........បានថ្លែងការណ៍ថា ខ្លួនឈ្មោះ ........... មានអាយុ៧២ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល។ ដីនេះតាំងឆ្នាំ១៩៨០ ខ្លួនរស់នៅជាមួយប្ដីឈ្មោះ ............ដាំបន្លែ ត្រសក់ ដាំស្រូវ នៅលើដីនេះ។ ដីនេះខ្លួនចូលកាន់កាប់តាំងពីឆ្នាំ១៩៨០ រហូតដល់១៩៩០ ហើយនៅឆ្នាំ១៩៩៣ ទើបគេធ្វើប័ណ្ណឲ្យ។ នៅពេលធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់នោះគ្មានអ្នកចេញមកតវ៉ានោះទេ។ ដីជារបស់ខ្លួនជាមួយប្ដីឈ្មោះ ...........។ រឿងមានលិខិតប្រទានកម្មឱ្យទៅប្អូន ដោយសារខ្ជិលមិនចង់មានទំនាស់គ្នា ក៏បានផ្តិតមេដៃលើលិខិត ដោយបែងចែកគ្នា ព្រោះខ្លួនអត់ចេះ អក្សរ។ មិនមែនឲ្យទៅប្អូននោះទេ គឺចង់ឲ្យសម្រុះស្រួលគ្នាកុំឲ្យប្ដឹងគ្នា ចែកគ្នាទៅ ព្រោះបងប្អូនឯង ជាក្មួយ និងមា។ ខ្លួនផ្តិតមេដៃ ០៣ឆ្នាំហើយ ដើម្បីសម្របសម្រួលគ្នា។ ដីប្អូនចែកឲ្យខ្លួនទើបយកមកធ្វើប្លង់ហ្នឹងឱ្យតាំងពីឆ្នាំ ១៩៨០ មកក្នុងនាមរដ្ឋអំណាច ចែកឱ្យដីពីរកន្លែង។ ប្អូនធ្វើសេដ្ឋកិច្ចនៅឃុំ។ ខ្លួនថាឱ្យសម្រួលគ្នាទៅ តែគេមិនព្រមសម្រួល។ ខ្លួនចេញពីដីជាង ១០ឆ្នាំមកហើយ ដីប្អូនឈ្មោះ ............គាត់ដាំស្វាយ។ ខ្លួនឲ្យគាត់ដាំស្វាយដោយសារកាលហ្នឹងគាត់បានព្រមព្រៀងបែងចែកដីហើយខ្លួនថា ដាំអីដាំទៅ។ គេបានសន្យាថានិងចែកដីនៅខាងត្បូងឲ្យខ្លួន គេយកខាងជើង ប៉ុន្តែមកដល់សព្វថ្ងៃគេមិនបានបែងចែកដីឱ្យខ្លួនទេ។

-ចុងចម្លើយឈ្មោះ ............ថ្លែងការណ៍ថា រឿងប្រវត្តិដីខ្លួនសុំបញ្ជាក់ថា មេធាវីលើកឡើងខុសទាំងអស់ តាមការពិតដីបែងចែកនៅឆ្នាំ១៩៨៩ មកពេលកងទ័ពវៀតណាមដកចេញ គឺគេបានបែងចែកដីទូទាំងប្រទេស ហើយនៅពេលគេបានបែងចែកហ្នឹងខ្លួនគ្រាន់បញ្ជាក់ថា បងខ្លួននេះពេលដែលដាំស្វាយប៉ុន្មានដើម ០២ ឬ០៣ ពេលស្វាយផ្លែទេ ខ្លួនបានឲ្យដីគាត់ ០២(ពីរហិកតា) ហើយដីមួយកន្លែងទៀតខ្លួននៅកន្ទ្រកឲ្យទៅគាត់ ហើយគាត់លក់បានជិត ១០,០០០ដុល្លាអាមេរិក។ របបដីរបស់ខ្លួននៅក្នុងក្រុងខ្លួនឱ្យគាត់៣ម៉ែត្រកន្លះ បណ្ដោយ៣៥០ម៉ែត្រ គាត់លក់មើលជម្ងឺបានជាង ៣០០០(បីពាន់)ដុល្លាអាមេរិក។ មួយទៀត ២៥ម៉ែត្រ បណ្ដោយ ១០០ម៉ែត្រ គាត់

ឱ្យទៅឈ្មោះ ............កូនគាត់លក់បាត់ទៀត គិតទៅខ្លួនឱ្យគាត់ច្រើនហើយ។ រឿងព្រំប្រទល់ដីខ្លួនកាន់កាប់តាំងពីឆ្នាំ១៩៨៩មកទាំងអស់ នៅពេលខ្លួនកាន់កាប់ដីនោះមានស្វាយមួយជួរ ហើយខ្លួនបានឲ្យបងខ្លួនទៅមើលថែរក្សាស្វាយដោយសារក្មេងចេះតែបេះ ម្ខាងទៀតខ្លួនជួលឲ្យគេដាំបន្លែរហូតចុងឆ្នាំ១៩៩៤-១៩៩៥ ទើបខ្លួនដកវិញ។ ខ្លួនដាំស្វាយអាមួយមានអាយុ ១៥ឆ្នាំមកហើយ អាមួយទៀតអាយុ១៤ឆ្នាំមានរបងមានអីត្រឹមត្រូវ។ ព្រំប្រទល់ដែលគាត់និយាយថា ........... គាត់ថា មិនមានដីជាប់ឈ្មោះ ...........នោះទេ គឺអ្នកដែលដាក់ហ្នឹងចេះតែប្រាប់ទៅនៅភូមិកណ្ដាល ក្រោម តែដាក់ភូមិកណ្ដាលលើ។ ពួកគាត់អត់ដែលកាន់កាប់នោះទេ ខ្លួនឲ្យដីបីប្អូនហិកតា ទៅគាត់ហើយខ្លួនឲ្យហ្នឹងគឺមានភស្ដុតាងដែលមានបងទាំងអស់បានដឹងឮ ហើយខ្លួនកាន់កាប់មកនេះក៏គាត់មកចោទប្រកាន់ខ្លួនថា សម្លាប់ប្ដីគាត់ហើយតុលាការតម្កល់ចោទ ហើយក៏ប្ដឹងខ្លួនម្ដងទៀតដែលថា ខ្លួនលួចលក់ដីគាត់ ហើយក៏តុលាការតម្កល់ទៀត ហើយឥឡូវមកប្ដឹងរឿងរដ្ឋប្បវេណីទៀត។ តាមការពិតប្លង់នេះគឺមានពាក្យបណ្ដឹងឆ្នាំ២០១៥ នោះទេដោយសារ ............ យកប្លង់ហ្នឹងទៅបញ្ចាំឲ្យគេ គេក៏សួរខ្លួនថា ដីរបស់ខ្លួនមានប្លង់ អ៊ីចឹងខ្លួនក៏សួរគាត់ ហើយគាត់ថាចាំយកប្លង់ឲ្យខ្លួន ហើយគាត់យកប្លង់ឱ្យខ្លួនមែន។ ខ្លួនមិនបានទៅលួចទេ គឺបានទៅយកដល់ផ្ទះគាត់ថា ប្លង់យកឱ្យឯង កុំឱ្យមានរឿង ស្អែកគាត់មកប្រាប់វិញប្អូនអើយ០១ហិចតាឱ្យទៅ ............ បានជាកើតរឿងមក។ រឿងគាត់ថា កាន់កាប់ពីឆ្នាំ១៩៨០ មិនត្រឹមត្រូវទេ ដីរដ្ឋចែកឱ្យនៅឆ្នាំ១៩៨៩ ទេ។ ពេលគាត់ធ្វើប្លង់ខ្លួនពុំបានដឹងនោះទេ។ នៅឆ្នាំ២០១៥ ខ្លួនទើបតែបានដឹងនៅពេលកូនរបស់ឈ្មោះ ............យកប្លង់ទៅដាក់បញ្ចាំឱ្យគេ។ នៅពេលឆ្នាំ២០១៥ ខ្លួនបានដឹងនេះខ្លួនមិនបានតវ៉ាទៅនឹងប្លង់នោះទេ។ ដីហ្នឹងខ្លួនកាន់កាប់ស្របច្បាប់ ព្រោះប្លង់ដែលធ្វើនេះខុសនោះទេ ព្រោះគ្រាន់តែប្រាប់ពីព្រំប្រទល់នោះទេ មិនបានទៅចុះបញ្ជីទេ។ អ្នកដែលនៅជាប់ព្រំប្រទល់គេមិនទទួលស្គាល់ឈ្មោះ ........... ទេ ហើយអ្នកដែលជាប់ព្រំប្រទល់គេក៏បានបញ្ជាក់ដែរ ពួកគេដាក់ព្រំជាប់ខ្លួន។ ខ្លួនធ្វើខាងសេដ្ឋកិច្ច។ ប្រទានកម្មដោយសារបងគាត់ដឹងថា ដីនោះរបស់ខ្លួនទើបគាត់មកធ្វើដោយសារបញ្ចប់វិវាទហើយ។ ពេលគាត់ប្ដឹងទៅសម្ដេច **ហ៊ុន សែន** គាត់បានឆ្លើយថា ដីនោះជាខ្លួនទាំងពីរកន្លែង មួយប្លង់យកមកឱ្យខ្លួន មួយប្លង់ទៀតនៅកូននេះគាត់បំភ្លឺនៅសាលាស្រុក។ ប្រទានកម្ម ដោយសារមេធាវីជាអ្នកសរសេរធ្វើ ពេលទៅគឺខ្លួនមិនបានបង្ខំគាត់នោះទេ គឺគាត់ឯក

ភាពក្នុងការធ្វើលិខិតប្រទានកម្មនោះដែរ ដោយគាត់បានបំភ្លឺនៅសាលាឃុំ សាលាស្រុក នៅតុលាការ។

-មេធាវី ........... បន្ថែមថា ខ្លួនជាអ្នកសរសេរលិខិតប្រទានកម្មនេះ នៅក្នុងបណ្តឹងគឺគាត់មានសិទ្ធិក្នុងការប្តឹងទាមទារ អ៊ីចឹងបើគាត់ប្រគល់សិទ្ធិលើសិទ្ធិហើយ គឺបញ្ចប់ការទាមទាររបស់គាត់។ ឧទាហរណ៍ បើសិនដីនេះជាដីរបស់គាត់ អ៊ីចឹងចំណែកពាក់កណ្តាលគឺជាដីរបស់គាត់ អ៊ីចឹងយកចំណែកពាក់កណ្តាលទៅចែកជា០៧ កូនគាត់មាន០៦នាក់គឺត្រូវចែកជា០៧ នេះជាការបែងចែកមរតកតាមផ្លូវច្បាប់។ នៅពេលចាប់ផ្តើមប្តឹងគាត់ជាម្ចាស់ដី ម្តេចគាត់មិនប្តឹង? អ៊ីចឹងគាត់អះអាងគ្រប់កន្លែងថា ដីនេះជារបស់គាត់ អ៊ីចឹងគាត់ត្រូវធ្វើលិខិតប្រទានកម្មនៃសិទ្ធិដើម្បីបញ្ចប់ការទាមទាររបស់គាត់។ អ៊ីចឹងគាត់អត់មានសិទ្ធិអីទាមទារទៀតទេ។ ប្រទានកម្មសិទ្ធិលើដី ឥឡូវក្នុងបណ្តឹងគាត់អត់ទាមទារផង។

## <u>សំអាងហេតុ</u>

១-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ ............ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-ដើមចោទ(ចុងបណ្តឹងតប) បានប្តឹងទាមទារឲ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារៈសុំសិទ្ធិគ្រប់គ្រង និងបែងចែកដីជា ៥ចំណែកស្មើៗគ្នាដែលជាចំណែករបស់ឪពុកឈ្មោះ ............នូវដីចំនួនពីរកន្លែង គឺដីទំហំ ០១ហិកតា មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១២៦២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ មានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល, ដីដែលមានទំហំ ៤៥៤៧,៣៨ម$^២$ មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១៤៣២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ ដែលមានទីតាំងស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល និងទាមទារយកប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១៤៣២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ ពីឈ្មោះ ........... វិញ។ ដោយសំអាងថា ឪពុករបស់ខ្លួនឈ្មោះ ............បានទទួលមរណៈភាពកាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៨ ដោយបន្សល់ទុកនូវមរតកជាអចលនៈវត្ថុចំនួនពីរកន្លែង ហើយដើមចោទជាសន្តតិជនស្របច្បាប់ដែលត្រូវទទួលមរតកពីសពឪពុកឈ្មោះ ...........។ ចំពោះប័ណ្ណលេខ G៧-១២៦២ ចុះ

ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ គឺសហដើមចោទរក្សាទុក។ រីឯប័ណ្ណលេខ G៧-១៤៣២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ ត្រូវបានចុងចម្លើយគំរាមកំហែង និងលួងលោមម្ដាយរបស់ខ្លួនឲ្យយកមកបង្ហាញ ហើយចុងចម្លើយបានលួចយកទៅបាត់។

៣-ចុងចម្លើយ(ជាដើមបណ្ដឹងតប) បានប្ដឹងតបសុំឲ្យតុលាការសម្រេចបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិជាកម្មសិទ្ធិឲ្យខ្លួន និងប្រពន្ធឈ្មោះ ............លើដីទំនាស់ ទាំងពីរកន្លែងនេះ, សុំឲ្យផ្ទេរការចុះបញ្ជីដីធ្លីពីឈ្មោះ ............និងប្រពន្ធឈ្មោះ ........... ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១៤៣២ និងលេខ G៧-១២៦២ មកឲ្យខ្លួនឈ្មោះ ............និងប្រពន្ធឈ្មោះ ..........., ឲ្យដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី និងទាមទារសំណងខូចខាតពេលវេលាសេវាផ្សេងៗចំនួន ១០០០០(មួយម៉ឺន)ដុល្លា និងសំណងជម្ងឺចិត្តចំនួន ២០០០០(ពីរម៉ឺន)ដុល្លា ដោយសំអាងថា ដីទាំងពីរកន្លែងនេះរដ្ឋអំណាចបានចែកឲ្យខ្លួនកាលពីឆ្នាំ១៩៨៩ ដែលមានប្រធានភូមិកណ្ដាលលើឈ្មោះ........... និងអតីតប្រធានភូមិកណ្ដាលក្រោមឈ្មោះ ........... ជាអ្នកចែកឲ្យហើយខ្លួនបានកាន់កាប់រហូតមក។ ស្រាប់តែនៅឆ្នាំ២០១៦ ដើមចោទបានប្ដឹងសុំចែកកេរ្តិ៍មរតកដោយថា ដីនេះជាដីរបស់ឈ្មោះ ............ទៅវិញ។

៤-ភាគីដើមចោទបានអះអាងថាឈ្មោះ ............និងប្រពន្ធឈ្មោះ ............បានកាន់កាប់គ្រប់គ្រងតាំងតែពីឆ្នាំ១៩៨០ រហូតមកដល់ឆ្នាំ១៩៩៣ អាជ្ញាធរបានធ្វើប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីឱ្យ ហើយបានកាន់កាប់រហូតមកដល់សព្វថ្ងៃ។

៥-តាមការបំភ្លឺរបស់រដ្ឋអំណាចមូលដ្ឋានបានបញ្ជាក់ថា ដីទំនាស់នេះគឺឈ្មោះ ............ និងប្រពន្ធឈ្មោះ ............បានកាន់កាប់គ្រប់គ្រងតាំងតែពីឆ្នាំ១៩៨០រហូតមក ហើយតាមការបំភ្លឺរបស់សាក្សីឈ្មោះ ........... ........... ........... ........... និង ............បានបញ្ជាក់ថា ដីទំនាស់នេះជាដីរបស់ឈ្មោះ ............បានកាន់កាប់ពីឆ្នាំ១៩៨០ មកហើយពួកខ្លួនបានជួលដីនេះពីឈ្មោះ ............ដើម្បីដាំដំណាំដែលអាចបញ្ជាក់បានថា ដីទំនាស់នេះពិតជាដីរបស់ឈ្មោះ ............និងប្រពន្ធឈ្មោះ ............ពិតប្រាកដមែន។

៦-ចុងចម្លើយ(ជាដើមបណ្ដឹងតប) បានអះអាងថា ខ្លួនបានកាន់កាប់ដីទំនាស់នេះតាំងតែពីឆ្នាំ១៩៨៩ មកដែលមានរដ្ឋអំណាចភូមិឃុំទទួលស្គាល់ និងមានសាក្សីដឹងឮ ប៉ុន្តែមេភូមិឈ្មោះ ...........

និង ...........និងមេឃុំឈ្មោះ ...........បានបដិសេធនូវការបំភ្លឺរបស់ខ្លួនកន្លងមក និងបានបញ្ជាក់ថាដីនេះជាដីរបស់ភាគីដើមចោទ។

៧-ភាគីចុងចម្លើយបានអះអាងថា ឈ្មោះ ...........បានប្រគល់ដីទំនាស់នេះមកឱ្យខ្លួនតាមលិខិតប្រទានកម្មចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៦ ប៉ុន្តែឈ្មោះ ...........បានបដិសេធនូវលិខិតប្រទានកម្មនេះវិញតាមលិខិតបដិសេធលើលិខិតប្រទានកម្មចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៨ ដោយហេតុថា ខ្លួនពុំបានផ្តិតមេដៃធ្វើប្រទានកម្មនូវដីនេះឱ្យទៅចុងចម្លើយទេ គឺចុងចម្លើយបានយកលិខិតដែលចុងចម្លើយអះអាងថា ជាលិខិតបញ្ចប់ទំនាស់ ទើបខ្លួនផ្តិតមេដៃឱ្យ ហើយខ្លួនមិនចេះអក្សរទេ។ ហើយតាមចម្លើយរបស់ចុងចម្លើយ និងមេធាវីតំណាងចុងចម្លើយដែលឆ្លើយនាពេលទាញហេតុផលដោយផ្ទាល់មាត់នេះបានបញ្ជាក់ថា ចុងចម្លើយ បានឱ្យមេធាវីរៀបរៀងលិខិតប្រទានកម្មនេះឡើងរួចហើយទើបយកទៅឱ្យឈ្មោះ ...........ផ្តិតមេដៃតែម្តងដោយទៅដល់ផ្ទះរបស់ ...........នោះពេលយប់ទៅហើយ ដូច្នេះឃើញថា ការផ្តិតមេដៃរបស់ឈ្មោះ ........... លើលិខិតប្រទានកម្មចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៦ នេះអាចជាការភ័ន្តច្រឡំថា ជាលិខិតព្រមព្រៀងបញ្ចប់ទំនាស់។

៨-ចុងចម្លើយបានអះអាងថា ខ្លួនបានកាន់កាប់ដីទំនាស់នេះពីឆ្នាំ១៩៨៩ មក។ ប៉ុន្តែពុំមានភស្តុតាងណាដែលបញ្ជាក់ថា ចុងចម្លើយបានកាន់កាប់ដីនេះពីឆ្នាំ១៩៨៩ មកនោះទេ។ ចុងចម្លើយទើបតែបានដាក់ពាក្យស្នើសុំកាន់កាប់ដីនេះនៅថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១១ នេះទេ។ ម៉្យាងទៀតក្នុងឆ្នាំ១៩៨៩ នេះ គឺពុំមានដីណាសល់ដើម្បីបែងចែកឱ្យចុងចម្លើយនោះទេ ព្រោះថា ដីធ្លីត្រូវបានប្រជាជនធ្វើការកាន់កាប់គ្រប់គ្រងបង្កបង្កើនផលតាំងពីអំឡុងឆ្នាំ១៩៧៩-១៩៨០ មកម្លេះ។

៩-នាពេលទាញហេតុផលដោយផ្ទាល់មាត់នេះឈ្មោះ ...........បានអះអាងថា ដីទំនាស់នេះប្តីខ្លួនឈ្មោះ ............និងខ្លួនបានកាន់កាប់តាំងតែពីឆ្នាំ១៩៨០ រហូតមក។ ចំពោះការដែលថា ខ្លួនបានឆ្លើយកន្លងមកថា ដីនេះជារបស់ឈ្មោះ ...........នោះគឺពុំត្រឹមត្រូវឡើយ។

១០-តាមការអះអាងរបស់គូភាគី, តាមការបំភ្លឺរបស់សាក្សី និងតាមឯកសារភស្តុតាងក្នុងសំណុំរឿងបានបញ្ជាក់ឱ្យឃើញថា ឈ្មោះ ............និងប្រពន្ធឈ្មោះ ...........បានកាន់កាប់គ្រប់គ្រងដីទំនាស់តាំងពីឆ្នាំ១៩៨០ រហូតមក។ លុះដល់ឆ្នាំ១៩៩៣ ឈ្មោះ ............និងប្រពន្ធឈ្មោះ ...........បានធ្វើប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដូចមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ $G_{៧}$-១២៦២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៣ និងលេខ $G_{៧}$-១៤៣២ ចុះថ្ងៃទី

២០ ខែមីនា ឆ្នាំ១៩៩៣ បញ្ជាក់ស្រាប់ហើយចាប់ពីពេលនោះមកពុំមានអ្នកណាតវ៉ាឡើយ ដូច្នេះ ឈ្មោះ ............និងប្រពន្ធឈ្មោះ ........... មានសិទ្ធិកាន់កាប់ដីទំនាស់នេះជារបស់ខ្លួន។

១១-ភាគីដើមចោទបានប្តឹងទាមទារដីទំហំ ១០០០០ម² តាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១២៦២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ និងដីទំហំ ៥៥៤៧,៣៨ម² តាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់លេខ G៧-១៤៣២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ ស្ថិតនៅភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ប៉ុន្តែតាមលិខិតលេខ ១៨៨ ដនសស.កណ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៨ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកណ្តាល ដែលបានចុះវាស់វែងទីតាំងដីទំនាស់ជាក់ស្តែងបានបញ្ជាក់ថា ដីដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១២៦២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ មានទំហំតែ ៩៥៥២ម² ប៉ុណ្ណោះ ហើយប័ណ្ណលេខ G៧-១៤៣២ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ១៩៩៤ មានទំហំជាក់ស្តែង ៥៧៦៣ម² ហើយស្ថិតនៅភូមិកណ្តាលក្រោម ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល ដូច្នេះសាលាឧទ្ធរណ៍យកលទ្ធផលនៃការចុះវាស់វែងជាក់ស្តែងនេះជាមូលដ្ឋានក្នុងការសម្រេចសេចក្តី។

១០-សាលក្រមរដ្ឋប្បវេណីលេខ ៤៣(គ) ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្តាល ដែលសម្រេចសេចក្តីមកនេះពុំមានលក្ខណៈត្រឹមត្រូវឡើយ ដែលគប្បីលុបចោលជាអសារបង់។

១១-តាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចាញ់ក្តី។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ ............ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-លុបសាលក្រមរដ្ឋប្បវេណីលេខ ៤៣“គ” ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្តាល ចោលជាអសារបង់។

៣-ច្រានពាក្យបណ្តឹងតបចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១៦ របស់ឈ្មោះ ............ និង ........... ចោល ។

៤-ប្រគល់ដីចំនួនពីរកន្លែងគឺ ៖

ក.ដីទំហំ ៩៥៥២ម² ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១២៦២ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៣ មានទីតាំងស្ថិតនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្ត កណ្ដាល។

ខ.ដីទំហំ ៥៧៦៣ម² ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១៤៣២ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ១៩៩៤ មានទីតាំងស្ថិតនៅភូមិកណ្ដាលក្រោម ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ឲ្យទៅសហដើមចោទ ដែលមានឈ្មោះ ............ ជាតំណាងកាន់កាប់គ្រប់គ្រង។

៥-បង្គាប់ឲ្យចុងចម្លើយឈ្មោះ ............ប្រគល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ G៧-១៤៣២ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ១៩៩៤ ឲ្យទៅសហដើមចោទវិញ។

៦-ប្រាប់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

៧-សាលដីកានេះប្រកាសជាសាធារណៈនាថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៩។ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

**ក្រឡាបញ្ជី** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សា**

ហត្ថលេខា ហត្ថលេខា ហត្ថលេខា

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ២កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ភ្នំពេញ,ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សា**